ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការជ្រើសរើសអនាគតរបស់អ្នក



## បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ
## គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៣៩ ...... **អយក.**ប្រក

# ប្រកាស
# ស្ដីពី
# ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
# សៀវភៅ " ការជ្រើសរើសអនាគតរបស់អ្នក "

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្របក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- យោងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ២០០៥-២០០៩
- យោងសេចក្ដីណែនាំលេខ០៣ អយក. សណន.ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្ដីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងសំណើរបស់អង្គការអប់រំពិភពលោក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣
- យោងកំណត់ហេតុប្រជុំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេសនាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

ប្រការ១- អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ " ការជ្រើសរើសអនាគតរបស់អ្នក " ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់អង្គការអប់រំពិភពលោកសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀន និងរៀនកម្មវិធីបំណិនជីវិតនៅតាមអនុវិទ្យាល័យ ។

ប្រការ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងអង្គការអប់រំពិភពលោក មានភារកិច្ចអនុវត្តប្រកាសនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១៤

**បណ្ឌិត ហង់ ជួន ណារ៉ុន**

<u>កន្លែងទទួល</u> :
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- កាលប្បវត្តិ- ឯកសារនា.អគស.

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ /២១៧ ២៥៣ /៨២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

# គណៈកម្មការអភិវឌ្ឍសៀវភៅ
# " ការជ្រើសរើសអនាគតរបស់អ្នក "

**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. អ្នកស្រី អាលី លេន
២. លោក អេង សុខ
៣. លោក វីលៀម ‍‍វ៉ាន់ឌីវ៉ាល់

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណធន
២. លោក ប៊ុត សុភាន់
៣. លោក អែ សុងហៀង

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ ( USAID )

សហការរៀបចំដោយ
អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា.................................................................................................. ក

វត្ថុបំណងរួម.................................................................................................. ខ

ការត្រៀមលក្ខណៈមុនពេលបង្រៀន........................................................................ ខ

ខ្លឹមសារសង្ខេប.................................................................................................. គ

មេរៀនទី ១: ការណែនាំអំពីការងារដែលមាននៅប្រទេសកម្ពុជា.................................... ១

មេរៀនទី ២: ការងារក្នុងមូលដ្ឋាន.......................................................................... ៥

មេរៀនទី ៣: ការណែនាំអំពីកិច្ចសម្ភាសករណីសិក្សា.................................................. ៨

មេរៀនទី ៤: ការអភិវឌ្ឍជំនាញសម្ភាស.................................................................. ១១

មេរៀនទី ៥: ផ្លូវនៃការសិក្សាសម្រាប់អនាគត.......................................................... ១៤

មេរៀនទី ៦: ការភ្ជាប់ការងារទៅនឹងជម្រើសសិក្សា.................................................... ១៩

មេរៀនទី ៧: ការរៀបចំផែនការទស្សនកិច្ចសិក្សា...................................................... ២១

មេរៀនទី ៨: ទស្សនកិច្ចសិក្សា.............................................................................. ២៣

មេរៀនទី ៩: ការរាយការណ៍អំពីព័ត៌មានដែលទទួលបាន............................................ ២៤

មេរៀនទី ១០: កម្រងសំណួរការងារ និងកំណត់ត្រានៃផែនការអនាគត.......................... ២៥

សកម្មភាពបន្ថែម

វគ្គបណ្ដុះបណ្ដាលលើកទីមួយជាមួយក្រុមប្រឹក្សាកុមារ................................................ ៣១

វគ្គបណ្ដុះបណ្ដាលលើកទីពីរជាមួយក្រុមប្រឹក្សាកុមារ.................................................. ៣៩

# អារម្ភកថា

សៀវភៅ **ការជ្រើសរើសអនាគតរបស់អ្នក** មានបំណងឱ្យអ្នកប្រឹក្សាអាជីពក្នុងសាលាមធ្យមសិក្សា បណ្ដុះបណ្ដាលសិស្សនូវជំនាញចាំបាច់ដើម្បីស្រាវជ្រាវពីប្រភេទខុសៗគ្នានៃការសិក្សា ការបណ្ដុះបណ្ដាល និងការងារដែលមាន សម្រាប់ពួកគេក្នុងមូលដ្ឋានក្នុងខេត្ត និងក្នុងប្រទេសរបស់ពួកគេ ព្រមទាំងវិធីក្នុងការស្វែងយល់ពីរបៀបនៃការងារទាក់ទងជាមួយនឹងជំនាញ ការចាប់អារម្មណ៍និងការសិក្សារបស់ពួកគេ។ ទន្ទឹមនឹងនេះសៀវភៅនេះក៏នឹងណែនាំអំពីកិច្ចការប្រចាំថ្ងៃដែលអ្នកធ្វើការក្នុងផ្នែកនានាអនុវត្ត។

ការគិតអំពីអាជីពនៅបឋមវ័យនឹងជួយសិស្សឱ្យទទួលបានជំនាញ និងបទពិសោធន៍ចាំបាច់ដែលពួកគេត្រូវការ ដើម្បីទទួលបានមុខរបរដែលពួកគេពេញចិត្ត ព្រមទាំងបំពេញសក្ដានុពលរបស់ពួកគេ ជាជាងការធ្វើការងារដែលពួកគេមិនមានការលើកទឹកចិត្ត និងឱកាសតំឡើងដំណែងតិចតួច។

ជាការណែនាំ សៀវភៅនេះផ្ដោតលើសិស្សកម្រិតថ្នាក់ទី៨ ព្រោះថាសិស្សថ្នាក់ទី៧មានលក្ខណៈថ្មីថ្មោងសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា ហើយម្យ៉ាងទៀតពួកគេកំពុងតែស្វែងរកមុខវិជ្ជាដែលពួកគេចូលចិត្ត និងមានទេពកោសល្យ។ សម្រាប់សិស្សថ្នាក់ទី៩ គឺយឺតពេកដោយសារសិស្សមិនមានឱកាសច្រើនដើម្បីគិត អំពីជំនាញបន្ថែមដែលពួកគេត្រូវការ ឬចង់អភិវឌ្ឍ ហើយពួកគេត្រូវការពេលច្រើនដើម្បីត្រៀមប្រឡង។ ទោះបីជាយ៉ាងណាក៏ដោយ ធនធានដែលសិស្សបង្កើតឡើងអាចមានប្រយោជន៍ និងគួរជាទីចាប់អារម្មណ៍សម្រាប់សិស្សទាំងអស់ក្នុងសាលារបស់អ្នក។ យើងសង្ឃឹមថាមនុស្សវ័យក្មេងអាចមានការគិតឈានទៅមុខនៅក្នុងសេចក្ដីប៉ងប្រាថ្នារបស់ពួកគេសម្រាប់អនាគតមុខរបររបស់ពួកគេ ព្រមទាំងមានការយល់ដឹងពីប្រភេទការងារដែលស័ក្តិសមនឹងពួកគេ។

ជាការបន្ថែមទៅលើមេរៀនបំណិនជីវិត សៀវភៅនេះមានសកម្មភាពបន្ថែមខ្លះៗដែលអាចត្រូវបានអនុវត្តដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាកុមារ។ ដូច្នេះ គ្រូបង្រៀនបំណិនជីវិតសម្រាប់សៀវភៅនេះ ត្រូវបានហៅជាបុគ្គលធនធានមុខរបរ។ សកម្មភាពបន្ថែមដែលត្រូវអនុវត្តជាមួយក្រុមប្រឹក្សាកុមារ នឹងធ្វើឱ្យសេវាណែនាំពីមុខរបរក្នុងសាលារៀនកាន់តែមានភាពល្អប្រសើរ។

សៀវភៅនេះគឺជាការបន្ថែមលើសៀវភៅបំណិតជីវិតកុមារស្ដីពីពិភពការងារ ដែលនឹងកាន់តែជួយសិស្សឱ្យយល់ដឹង និងទទួលបានបំណិនអាជីពងាយសម្រាប់កន្លែងការងារ និងរបៀបក្នុងការដាក់ពាក្យស្នើសុំការងារ។

## ១. វត្ថុបំណងរួម

*បំណិនជីវិតគឺជាបំណិនបញ្ញាបុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈដែលអាចជួយដល់ការងារ សម្រេចចិត្តហើយធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពនិងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន។ វាក៏ជាបំណិនមួយដែលរួមចំណែកក្នុងការលើកស្ទួយ សុខុមាលភាព និងជីវិតប្រកបដោយផលិត ភាពខ្ពស់។ (គោលនយោបាយបំណិនជីវិតឆ្នាំ ២០០៦)។*

ការបង្រៀនបំណិនជីវិតនេះគឺចង់ឱ្យសិស្សប្រុសស្រីមើលឃើញនូវសារប្រយោជន៍ដែលផ្តល់ចំណេះដឹង និងសមត្ថភាពដល់ពួកគេ។

សៀវភៅនេះនឹងត្រូវបានប្រើប្រាស់ដោយបុគ្គលធនធានមុខរបរដើម្បីជួយសិស្សថ្នាក់ទី៨ឱ្យគិតអំពីអនាគតរបស់ពួកគេ។ វានឹងធ្វើឱ្យអ្នកប្រឹក្សាអាជីពអាចបណ្តុះបណ្តាលសិស្សអំពីរបៀបស្វែងរកព័ត៌មានអំពីឱកាសការងារក្នុងតំបន់ ព្រមទាំងគិតអំពីឱកាសសិក្សា និងបណ្តុះបណ្តាលសម្រាប់អនាគតរបស់ពួកគេ។ មេរៀននីមួយៗ ផ្តោតលើការផ្តល់ឱ្យសិស្សនូវជំនាញចាំបាច់ដើម្បីធ្វើផែនការយ៉ាងមានប្រសិទ្ធភាពនិងអនុវត្តការស្រាវជ្រាវអំពីឱកាសសិក្សានិងការងារដែលមានសម្រាប់ពួកគេ ព្រមទាំងប្រើប្រាស់បណ្តាញសាលារៀនដើម្បីចែករំលែកព័ត៌មានអំពីការងារក្នុងសហគមន៍របស់ពួកគេ និងក្នុងប្រទេសកម្ពុជាទាំងមូល។ យើងសង្ឃឹមថា ការផ្តល់ឱកាសឱ្យសិស្សគិត និងរៀបចំផែនការអនាគតរបស់ពួកគេនឹងជំរុញពួកគឱ្យកំណត់គោលដៅអនាគតរបស់ពួកគេ និងបន្តស្ថិតនៅក្នុងការអប់រំ និងការបណ្តុះបណ្តាលដែលធ្វើឱ្យពួកគេអាចបំពេញសក្តានុពល។

សកម្មភាពបន្ថែមដែលអនុវត្តមុនពេល ក្នុងកំឡុងពេល និងបន្ទាប់ពីវគ្គបំណិនជីវិត នឹងជួយឱ្យបុគ្គលធនធានចាត់អាទិភាពសិស្សទាំងនោះឱ្យពួកគេមានគំនិតតិចតួចអំពីអ្វីចង់ធ្វើបន្ទាប់ពីថ្នាក់ទី៩ ឬប្រឈមនឹងការបោះបង់ការសិក្សា ឬការបណ្តុះបណ្តាល និងផ្តល់ឱ្យពួកគេនូវឱកាសពិភាក្សាអំពីវាបន្ថែមទៀតជាមួយសមាជិកក្រុមប្រឹក្សាកុមារ អ្នកប្រឹក្សានៅសាលារៀន និង/ឬអ្នកប្រឹក្សាអាជីព ដើម្បីជួយពួកគេឱ្យគិតបន្ថែមទៀតអំពីអនាគតរបស់ពួកគេ និងជម្រើសដែលមានសម្រាប់ពួកគេ។

ការសម្ភាសជាមួយសិស្ស បានជ្រើសរើស និងទាមទារនូវពេលវេលា។ ដូច្នេះ បុគ្គលធនធាន និង/ឬអ្នកប្រឹក្សាសាលារៀនគួរបែងចែងពេលវេលាពីការបង្រៀនក្នុងសាលារៀនមកធ្វើកិច្ចការនេះ។ ពេលវេលាដែលត្រូវចំណាយចំពោះការងារនេះគួរតែជាពេលវេលាដែលផ្តល់ចំពោះការបង្រៀនសិស្សក្នុងកំឡុងពេលមេរៀនបំណិនជីវិត។

## ២. ការត្រៀមលក្ខណៈមុនពេលបង្រៀន

ម៉ូឌុលនេះចែកចេញជាច្រើនផ្នែកផ្សេងៗគ្នា ហើយមានវត្ថុបំណងខុសៗគ្នា។ ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស ជាដំណាក់កាលត្រៀមរបស់គ្រូ។ ព័ត៌មានទាក់ទងនឹងការបង្រៀន និងរៀន ពិសេសមេរៀន ត្រូវបានគ្រូត្រៀមទុកជាមុន។

### ● សម្ភារឧបទេស

ផ្នែកនេះផ្តល់នូវសេចក្តីសង្ខេបពីសម្ភារឧបទេស។ ភាគច្រើនជាសម្ភារមូលដ្ឋាន ដូចជា ប៊ិច ឬក្រដាស។ សម្ភារៈផ្សេងទៀតនៅក្នុងមេរៀននេះនឹងត្រូវផ្តល់ឱ្យ សិស្សប្រុស/ស្រីសម្រាប់អនុវត្ត តាមរយៈឯកសារសម្រាប់សិស្សប្រុស/ស្រីដែលបានភ្ជាប់នៅក្នុងម៉ូឌុលនេះ។ ពេលខ្លះវាមានការជាន់គ្នាផងដែរ។

### ● វត្ថុបំណង

ផ្តល់ឃ្លាបញ្ជាក់នូវអ្វីនឹងត្រូវសម្រេចបាន និងវាយតម្លៃនៅខាងចុងមេរៀន។ ឃ្លាទាំងនេះទាក់ទងនឹង គោលដៅរួមរបស់បំណិនជីវិត ដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំបំណិតជីវិតនៅមធ្យមសិក្សាបឋមភូមិ ព្រមទាំងកំណត់នៅក្នុង *បំណិនមូលដ្ឋាន ការសិក្សាជំនួញ បំណិនសេដ្ឋកិច្ច និងបំណិនអាជីពងាយៗ។*

● **សញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយៗ**

ខាងក្រោមនេះ ជាសញ្ញាសម្គាល់សកម្មភាពងាយៗដើម្បីឱ្យគ្រូអនុវត្តបានជោគជ័យក្នុងការបង្រៀន និងរៀន។

ធ្វើសកម្មភាពៈ លោកអ្នកគ្រូចាំបាច់ត្រូវធ្វើសកម្មភាពផ្ទាល់ខ្លួន

សរសេរ : ពេលខ្លះត្រូវការឱ្យលោកអ្នកគ្រូសរសេរនៅលើក្ដារខៀន

សួរ : មានសំណួរ ដែលត្រូវសួរទៅកាន់សិស្សប្រុស/ស្រី

ពន្យល់ : ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សប្រុស/ស្រីនៅក្នុងថ្នាក់

● **លំនាំបង្រៀន**

មេរៀននីមួយៗចែកជា ៣ផ្នែក។ ផ្នែកទី១ គឺជាសេចក្ដីផ្ដើមដែលយើងព្យាយាមផ្សារភ្ជាប់ទៅនឹងចំណេះដឹង ដែលសិស្សមានស្រាប់ ឬរំឭកមេរៀនចាស់។ ផ្នែកទី២ យើងនឹងបង្រៀនសកម្មភាពសំខាន់ៗដោយផ្អែកលើវិធីបង្រៀនរៀនបែបការងារគម្រោង(ចុះស្រាវជ្រាវ ប្រមូលព័ត៌មានសម្ភាស ចងក្រងឯកសារ និងបទបង្ហាញ...)។និងយុទ្ធវិធីបង្រៀនផ្សេងៗទៀត។ នៅផ្នែកទី៣ ដែលជាផ្នែកបញ្ចប់ យើងអាចធានាបានថា រាល់លទ្ធផលនៃការសិក្សារបស់យើង គឺបានឆ្លងកាត់នូវយុទ្ធវិធីខុសៗគ្នាជាច្រើន។

## ៣. ខ្លឹមសារសង្ខេប

មេរៀនសង្ខេបត្រូវបានផ្ដល់ជូនឱ្យគ្រូក្នុងផ្នែកនេះ ដើម្បីជាទុនខ្លះក្នុងការបង្រៀន ហើយក៏ជាសញ្ញាណមួយជាក់លាក់បញ្ជាក់ពីទំនាក់ទំនង និងសារៈសំខាន់រវាងមេរៀននីមួយៗ ។

ខាងក្រោមនេះ គឺជាសេចក្ដីសង្ខេបរួមទាំង ១០ មេរៀនដែលនៅក្នុងម៉ូឌុលបំណិនជីវិតនេះ ៖

| ចំណងជើងមេរៀន | រយៈពេល | វត្ថុបំណង | ទំព័រ |
|---|---|---|---|
| ១. ការណែនាំអំពីការងារដែលមាននៅប្រទេសកម្ពុជា | ១ ម៉ោង ៣០ នាទី | សិស្សរៀនស្វែងយល់ពីតួនាទីនៃអ្នកប្រឹក្សាអាជីពនិងចាប់ ផ្ដើមគិតអំពីមុខរបរដែលមានក្នុងមូលដ្ឋាន និងក្នុង ប្រទេសកម្ពុជាទាំងមូល | ១ |
| ២. ការងារក្នុងមូលដ្ឋាន | ១ ម៉ោង ៣០ នាទី | សិស្សសិក្សាអំពីរបៀបក្នុងការសម្គាល់ និងធ្វើផែនការការងារដែលមានក្នុងមូលដ្ឋាន | ៥ |
| ៣. ការណែនាំអំពីកិច្ចសម្ភាស ករណីសិក្សា | ១ ម៉ោង ៣០ នាទី | រៀនអំពីរបៀបក្នុងការសម្ភាសមនុស្សដែលពួកគេស្គាល់អំពីការងាររបស់ពួកគេនិងធ្វើ ករណីសិក្សា | ៨ |
| ៤. ការអភិវឌ្ឍជំនាញសម្ភាស | ១ ម៉ោង ៣០ នាទី | ឆ្លុះបញ្ចាំងអំពីបញ្ហា និងដំណោះស្រាយដើម្បីកែលម្អជំនាញកិច្ចសម្ភាសករណីសិក្សា | ១១ |
| ៥.ផ្លូវនៃការសិក្សាសម្រាប់អនាគត | ១ ម៉ោង ៣០ នាទី | រៀនអំពីជម្រើសសិក្សា និងបណ្ដុះបណ្ដាលដែលមានសម្រាប់ពួកគេបន្ទាប់ពីថ្នាក់ទី៩ | ១៤ |
| ៦. ការភ្ជាប់ការងារទៅនឹងជម្រើសសិក្សា | ១ ម៉ោង ៣០ នាទី | យល់ពីទំនាក់ទំនងមុខវិជ្ជាក្នុងសាលារៀន បំណិនជីវិត និងការកំសាន្ត និងបទពិសោធន៍ផ្សេងៗដែលទាក់ទងនឹងផ្លូវអនាគត | ១៩ |
| ៧. ការរៀបចំផែនការទស្សនកិច្ចសិក្សា | ១ ម៉ោង ៣០ នាទី | សិក្សាអំពីរបៀបរៀបចំនិងធ្វើផែនការសម្រាប់ទស្សនកិច្ចសិក្សាដើម្បីរៀនពីឱកាសសិក្សា ការបណ្ដុះបណ្ដាល និងការងារក្នុងមូលដ្ឋាន | ២១ |

| | | | |
|---|---|---|---|
| ៨. ទស្សនកិច្ចសិក្សា | ១ ម៉ោង ៣០ នាទី | សិស្សទៅធ្វើទស្សនកិច្ចសិក្សា ឬអញ្ជើញអ្នកធ្វើទស្សនកិច្ចទៅសាលារៀនរបស់ពួកគេដើម្បី រៀនបន្ថែមទៀតអំពីឱកាសក្នុងមូលដ្ឋាន។ ពួកគេអាចនឹងរៀនអំពីវិទ្យាល័យ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមណ្ឌលបណ្តុះបណ្តាលដទៃទៀត ឬនយោជិកក្នុងមូលដ្ឋាន។ | ២៣ |
| ៩. ការរាយការណ៍អំពីព័ត៌មានដែលទទួលបាន | ១ ម៉ោង ៣០ នាទី | សិស្សរៀបចំផ្សព្វផ្សាយនិងចែករំលែកព័ត៌មានដែលពួកគេទទួលបានក្នុងកំឡុងពេលទស្សនកិច្ចសិក្សា។ | ២៤ |
| ១០. កម្រងសំណួរការងារ និង កំណត់ត្រានៃផែនការអនាគត | ១ ម៉ោង ៣០ នាទី | កំណត់ត្រានៃគំនិតរបស់សិស្សអំពីគោលដៅការងារអនាគត និងចាត់អាទិភាពចំពោះអ្នកដែលត្រូវការជំនួយបន្ថែមដើម្បីជ្រើសរើសការងារ ការសិក្សា និងផែនការបណ្តុះបណ្តាលអនាគតរបស់ពួកគេ | ២៥ |
| សកម្មភាពបន្ថែម | មុនពេល ក្នុងពេល និងក្រោយពេលសិក្សា | សកម្មភាពណ្តុះបណ្តាលបន្ថែមដែលត្រូវធ្វើឡើងក្នុងសាលារៀន ដោយមានជំនួយពីក្រុមប្រឹក្សាសិស្ស និងអ្នកប្រឹក្សាសាលា ប្រសិនបើមាន។ ការប្រជុំសកម្មភាពបន្ថែមទី១គួរធ្វើឡើងជាមួយក្រុមប្រឹក្សាសិស្ស ២សប្តាហ៍មុនពេលចាប់ផ្តើមបង្រៀនវគ្គនេះ។ | ៣១ |

## ៤. ការវាយតម្លៃ

ការវាយតម្លៃមាន២ផ្នែកសំខាន់ៗ។ មួយផ្នែកជាការវាយតម្លៃនៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ និងជាវិញ្ញាសាសរសេរដែលយើងត្រូវបញ្ចូលនៅផ្នែកខាងចុងម៉ូឌុល ។ ផ្នែកមួយទៀត ជាការវាយតម្លៃទៅលើឥរិយាបថសិស្សដោយគ្រូជាអ្នកសង្កេតផ្ទាល់រៀងរាល់ថ្ងៃ ហើយដាក់ពិន្ទុ។ វិធីវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថរបស់សិស្សម្នាក់ៗ ។ ចំពោះការវាយតម្លៃសិស្សនេះ យើងគិតពិន្ទុ ៥០ ស្មើទៅនឹងមុខវិជ្ជាមួយចំនួន ផងដែរ គឺយើងឱ្យពិន្ទុ ៣៥ ទៅលើឥរិយាបថ និងពិន្ទុ ១៥ ទៅលើវិញ្ញាសាសរសេរ។

នៅតាមមេរៀននីមួយៗ គ្រូទុកពេលឱ្យសិស្សពិភាក្សាក្រុមតូចឱ្យបានច្រើន នៃចំណុចសំខាន់ៗនៅពាក់កណ្តាលមេរៀននីមួយៗ។ កំឡុងពេលសិស្សពិភាក្សាក្រុមតូច ជាពេលវេលាដែលគ្រូអាចសង្កេតឥរិយាបថសិស្សក្នុងការដាក់ពិន្ទុ។ ជាការល្អគ្រូគួរដាក់ពិន្ទុឥរិយាបថសិស្សចាប់ពីមេរៀនទី ៦ តទៅ។

## ៥. ឯកសារបន្ថែម

ផ្នែកនេះមានឯកសារសម្រាប់សិស្ស ដែលនឹងត្រូវប្រើប្រាស់ដោយបុគ្គលធនធាន។ ឯកសារទាំងនោះនឹងត្រូវបានផ្តល់ឱ្យជាលក្ខណៈអ៊ុតប្លាស្ទិច ដើម្បីឱ្យសិស្សប្រើប្រាស់ក្នុងកិច្ចការរបស់ពួកគេ។ រូបថតនៅលើទំព័រមុខនៃសៀវភៅនេះត្រូវបានដកស្រង់ពីវចនានុក្រមការងារ ដែលជាឯកសារដ៏ល្អពីអង្គការស៊ីប៉ា។ ជាការណែនាំសាលា គួរមានសៀវភៅនេះ ឬសៀវភៅធនធានការងារ ដែលស្រដៀងគ្នាក្នុងបណ្ណាល័យរបស់ពួកគេ។ ជាមួយនឹងករណីសិក្សា (ដែលសិស្សនឹងធ្វើក្នុងវគ្គបណ្តុះបណ្តាលបំណិនជីវិតនេះ) សៀវភៅនេះ នឹងផ្តល់ជាការចាប់ផ្តើមយ៉ាងល្អសម្រាប់សិស្សដើម្បីណែនាំខ្លួនរបស់ពួកគេ អំពីទីផ្សារការងារ និងផ្លូវសិក្សាសម្រាប់អនាគត។

ប្រសិនបើមានសៀវភៅបញ្ជីនៃការអប់រំជាន់ខ្ពស់ និងការបណ្តុះបណ្តាល គឺជាការណែនាំយ៉ាងល្អដើម្បីប្រមូលព័ត៌មានពីសាកលវិទ្យាល័យ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។

វេបសាយដ៏មានសារប្រយោជន៍ សម្រាប់ព័ត៌មានទំនាក់ទំនងលម្អិត អំពីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងឱកាសការងារគឺ www.nea.gov.kh

# មេរៀនទី ១: ការណែនាំអំពីការងារដែលមាននៅប្រទេសកម្ពុជា

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារចំនួន ៦ច្បាប់ - មួយច្បាប់សម្រាប់មួយក្រុម
- ក្រដាសរ៉ាម ហ្វឺត និងស្កុត
- ច្បាប់ចតចម្លងនៃវចនានុក្រមអាជីពដើម្បីប្រើប្រាស់ក្នុងការសម្គាល់ការងារ (ប្រសិនបើមាន)
- ផ្ទាំងរូបភាពនៃការងារក្នុងប្រទេសកម្ពុជា (ពីក្នុងសៀវភៅពិភពការងារ)

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

១. ប្រាប់ពីតួនាទីរបស់អ្នកប្រឹក្សាអាជីព
២. រៀបរាប់ឈ្មោះការងារខ្លះៗដែលមានក្នុងតំបន់ និងក្នុងប្រទេសកម្ពុជាទាំងមូល

**សេចក្តីផ្តើមៈ** 🕑 **៣០ នាទី**

អ្នកប្រឹក្សាអាជីពស្វាគមន៍សិស្ស (និងណែនាំខ្លួនពួកគេ ប្រសិនបើពួកគេមិនស្គាល់គ្នា)

អ្នកប្រឹក្សាអាជីពពន្យល់ពីវត្ថុបំណងរបស់មេរៀន

អ្នកប្រឹក្សាអាជីពប្រាប់សិស្សថា ពួកគេនឹងលេងល្បែងកំសាន្តមួយ ដើម្បីណែនាំពីប្រធានបទ។ អ្នកប្រឹក្សាអាជីពឱ្យសិស្សសរសេរដោយសម្ងាត់ ពីការងាររបស់នរណាម្នាក់ ដែលពួកគេស្គាល់ក្នុងជីវិតពិត ឬតាមទូរទស្សន៍ហើយពួកគេគិតថាមិនធម្មតា ហើយប្រហែលសិស្សដទៃទៀតនឹងមិនសរសេរ។ បន្ទាប់មក ឱ្យសិស្សទាំងអស់ឈរជារង្វង់និងសួរគ្នាទៅវិញទៅមក "តើការងាររបស់អ្នកជាអ្វី?" ហើយសរសេរការងារដែលពួកគេបានឮ។ ៥ ឬ៦នាទីក្រោយមក ឱ្យសិស្ស អង្គុយចុះ និងរាប់ចំនួនការងារដែលខុសគ្នាក្នុងបញ្ជីរបស់ពួកគេ។ សិស្សដែលសរសេរបានចំនួនការងារច្រើនជាងគេជាអ្នកឈ្នះ ហើយគ្រូវអានការងារក្នុងបញ្ជីរបស់គឱ្យសិស្សដទៃទៀតស្តាប់។

❓ តើរវាងការងារ និងអាជីពមានអ្វីខុសពីគ្នា?

ចម្លើយដែលអាចមាន៖ ជារឿយៗ ការងារគឺមិនមានការគ្រោងទុក និងធ្វើដើម្បីរកប្រាក់ជាគោល។ អាជីពគឺ ជាអ្វីដែលអ្នកកសាង និងអភិវឌ្ឍជាច្រើនឆ្នាំ និងអាចច្រើនជាងការងារមួយ។

តើហេតុអ្វីបានជាសិស្សគប្បីគិតពីអាជីពរបស់ពួកគេក្នុងថ្នាក់ទី៧ ឬទី៨ - វានឹងមានរយៈពេលវែងមុនពេលពួកគេត្រូវទៅធ្វើការ?

ចម្លើយដែលអាចមាន៖ វាមានសារៈសំខាន់ក្នុងការធ្វើផែនការ ដូច្នេះពួកគេនឹងបន្តការសិក្សា ខំប្រឹងរៀនសូត្រ និងធ្វើការជ្រើសរើសត្រឹមត្រូវអំពីមុខវិជ្ជាដែលត្រូវសិក្សា តើមេរៀនអ្វីខ្លះដែលអ្នកបានរៀនក្នុងមុខវិជ្ជាសិក្សាសង្គម (សីលធម៌ ពលរដ្ឋវិជ្ជា) ថ្នាក់ទី៧ ដែលទាក់ទងនឹងជម្រើសអាជីព?

ចម្លើយដែលអាចមាន៖ ជំពូកទី៥ ការកំណត់គោលដៅ ក្នុងមេរៀនទី១៖ ការជ្រើសរើសអាជីព, មេរៀនទី២៖ សារៈសំខាន់នៃការជ្រើសរើសអាជីព, មេរៀនទី៣៖ ព័ត៌មានពីអាជីព ។

ឱ្យអ្នកចូលរួមពិភាក្សាជាដៃគូរយៈពេល ១ទៅ ២នាទី៖ "តើអ្នកប្រឹក្សាអាជីពជាអ្នកណា?"

អ្នកប្រឹក្សាអាជីពឱ្យសិស្សម្នាក់ ឬពីរនាក់ចែករំលែកគំនិតរបស់ពួកគេ បន្ទាប់មកសរសេរនិយមន័យនៅលើក្ដារខៀនដើម្បីឱ្យសិស្សកត់ទុកក្នុងសៀវភៅរបស់ពួកគេ។

អ្នកប្រឹក្សាអាជីពគឺជាអ្នកដែលជួយធ្វើឱ្យប្រាកដថាមានព័ត៌មានបច្ចុប្បន្នភាពក្នុងសាលារៀនអំពីការងារ និងអាជីពក្នុងមូលដ្ឋាន និងក្នុងប្រទេសកម្ពុជា។ ពួកគេជួយសិស្សឱ្យគិតអំពីអ្វីដែលពួកគេនឹងធ្វើនៅពេលពួកគេបញ្ចប់ថ្នាក់ទី៩?

ពន្យល់ថា មានអ្នកប្រឹក្សាអាជីពក្នុងសាលារៀនរបស់ពួកគេ ដូចជារូបអ្នក។ ពន្យល់ថា ប្រសិនបើយើងចង់មានឱកាសការងារដែលទទួលបានប្រាក់កម្រៃខ្ពស់ យើងត្រូវព្យាយាមទទួលការអប់រំល្អ និងត្រូវបញ្ចប់ការអប់រំ ផ្នែកវិជ្ជាជីវៈជំនាញ និង/ឬសាកលវិទ្យាល័យ។ សិស្សខ្លះបោះបង់ការសិក្សាឆាប់ពេក ព្រោះពួកគេចង់រកប្រាក់ដើម្បីជួយគ្រួសារ ឬក៏គ្រួសារមិនអាចឧបត្ថម្ភសម្រាប់សម្ភារៈសិក្សាចាំបាច់។ វាមានសារៈសំខាន់ណាស់ដែលត្រូវគិតអំពីការពិភាក្សា នេះយ៉ាងយកចិត្តទុកដាក់ ព្រោះវានឹងកាត់បន្ថយជម្រើសអាជីពរបស់អ្នក និងស្វែងរកសក្ដានុពលក្នុងពេលអនាគត។ ប្រសិនបើអ្នកកំពុងគិតពីបញ្ហាឈប់រៀន អ្នកគួរពិភាក្សាជាមួយអ្នកប្រឹក្សាអាជីពក្រុមប្រឹក្សាកុមារ ឬនាយកសាលាដូច្នេះ ពួកគេអាចពិភាក្សាពីជំនួយដែលមានសម្រាប់អ្នក និងធ្វើឱ្យប្រាកដថា អ្នកច្បាស់អំពីជម្រើសរបស់អ្នកដើម្បីបន្តការសិក្សា និងការបណ្ដុះបណ្ដាល។

ចូរចងចាំ អ្នកនឹងធ្វើការស្ទើរតែពេញមួយជីវិតនៃយុវវ័យរបស់អ្នក ដូច្នេះវាមានសារៈសំខាន់ដែលអ្នកទទួលបានព័ត៌មានគ្រប់គ្រាន់អំពីជម្រើសអ្វីខ្លះដែលអ្នកមាន និងទុកពេលឱ្យខ្លួនរបស់អ្នកបំពេញសក្ដានុពលរបស់អ្នក។

## ការណែនាំពីជម្រើសអាជីពដែលមានក្នុងសាលារៀន

១០ នាទី

អ្នកប្រឹក្សាអាជីពពន្យល់ថា មានធាតុ៣យ៉ាងក្នុងការណែនាំអាជីពក្នុងសាលារៀន៖

១. សិក្សាជំនាញបំណិនអាជីពដែលទាក់ទងនឹងការជ្រើសរើសអាជីព និងការស្វែងរកការងារ រួមបញ្ចូលទាំងប្រធានបទនេះ និងពិភពការងារ

២. ប្រឹក្សាម្នាក់ទល់ម្នាក់ ឬជំនួយដទៃទៀតដែលផ្ដល់ទៅឱ្យសិស្សដើម្បីកំណត់អាទិភាពឱ្យអ្នកប្រឹក្សាអាជីព អ្នកប្រឹក្សា ឬក្រុមប្រឹក្សាសិស្សក្នុងសាលារៀនសម្រាប់សិស្សដែលជួបការលំបាក ឬគិតអំពីការឈប់រៀន

៣. ធនធានអាជីពផ្សេងៗដែលមានក្នុងសាលារៀន ជាពិសេសក្នុងបណ្ណាល័យរបស់អ្នក។មានការងារផ្សេងៗមួយចំនួនទាក់ទងនឹងប្រធានបទដែលមានក្នុងសាលារៀន ដូច្នេះត្រូវពិចារណាដោយយកចិត្តទុកដាក់ចំពោះបំណិនជីវិតដែលបានជ្រើសរើសក្នុងសាលានីមួយៗទាក់ទងនឹងសហគមន៍ក្នុងមូលដ្ឋាន និងការងារដែលមាន។




* បំណិនជីវិត ពិភពការងារ មានក្នុងសាលារៀន៖ វាជួយធ្វើឱ្យសិស្សទទួលបានបំណិនមូលដ្ឋាន (ដូចជា ការទំនាក់ទំនង ការធ្វើការងារជាក្រុមជំនាញ ដោះស្រាយបញ្ហា...) ពួកគេនឹងត្រូវការវាក្នុងជីវិតការងារនាពេលអនាគតរបស់ពួកគេ។

## អាជីពដែលមានក្នុងប្រទេសកម្ពុជា

🕑 ៦០ នាទី

✎ សរសេរតារាងខាងក្រោមនៅលើក្តារខៀន៖

| 1. ការងារដែលមានក្នុងសហគមន៍របស់យើង (ក្រុមទី១ និងទី២ត្រូវធ្វើ) | 2. ការងារដែលមិនមានក្នុងសហគមន៍យើងប៉ុន្តែមានក្នុងស្រុក ឬខេត្តរបស់យើង (ក្រុមទី៣ និងទី៤ត្រូវធ្វើ) | 3. ការងារដែលមិនមានក្នុងស្រុក ឬខេត្តរបស់យើង ប៉ុន្តែមានក្នុងប្រទេសកម្ពុជា (ក្រុមទី៥ និងទី៦ត្រូវធ្វើ) |
|---|---|---|
| | | |

☝ អ្នកប្រឹក្សាអាជីពបែងចែកសិស្សជា ៦ក្រុម។ ក្រុមនីមួយគួរមានប្រុស ៥០% និងស្រី៥០% ដូច្នេះនឹងមានសមភាពយេនឌ័រ។ ប្រសិនបើចាំបាច់ ផ្លាស់ប្តូរសិស្សទៅក្រុមផ្សេងដើម្បីឱ្យមានសមភាពយេនឌ័រក្នុងក្រុម។ ប្រាប់សិស្សថាពួកគេនឹងធ្វើការក្នុងក្រុមនេះពេញមួយវគ្គបំណិនជីវិតនេះ ហើយក្រុមរបស់ពួកគេនឹងរក្សានូវសំណុំឯកសារនៃការងាររបស់ពួកគេ។

អ្នកប្រឹក្សាអាជីពឱ្យសិស្ស២ក្រុមសរសេរការងារក្នុងតារាងទី១ ក្នុងក្រដាស់រាម ២ក្រុមសរសេរការងារក្នុងតារាងទី២ និង២ក្រុមសរសេរការងារក្នុងតារាងទី៣។ ពួកគេមានរយៈពេល១០នាទីដើម្បីសរសេរពីការងារឱ្យបានច្រើនបំផុតតាមដែលពួកគេអាចរកបានក្នុងតារាងដែលពួកគេត្រូវបំពេញ។



☞ រយៈពេល១០នាទីក្រោយ អ្នកប្រឹក្សាអាជីពឱ្យក្រុមទាំងអស់ឈប់ និងរាប់ចំនួនឈ្មោះការងារសរុបដែលពួកគេមានក្នុងតារាងរបស់ពួកគេ។ ក្រុមដែលមានចំនួនការងារច្រើនជាងគេគឺជាក្រុមដែលឈ្នះសម្រាប់តារាងនោះ (អ្នកទាំងអស់គ្នាគួរទះដៃអបអរសាទរក្រុមដែលឈ្នះសម្រាប់តារាងនីមួយៗ)

ហៅអ្នកតំណាងក្រុមមានចំនួនឈ្មោះការងារច្រើនជាងគេមកបិទបញ្ជីរបស់ពួកគេក្នុងតារាង និងពន្យល់ពីការងាររបស់ពួកគេ។ ក្រុមដទៃទៀតដែលបំពេញក្នុងតារាងដូចគ្នា អាចលើកឡើងពីការងារផ្សេងទៀតមានក្នុងតារាងរបស់ពួកគេ ហើយអាចដាក់បញ្ចូលក្នុងបញ្ជីរបស់ក្រុមនៅលើក្ដារខៀន។ ធ្វើដូចគ្នាសម្រាប់តារាងទាំង៣។ ក្រុមទាំងអស់អាចជួយកែតម្រូវការងារដែលស្ថិតក្នុងតារាងមិនត្រឹមត្រូវ។

☞ បិទផ្ទាំងរូបភាពពីសៀវភៅពិភពការងារ និងសួរសិស្សពីរបៀបដែលពួកគេអាចស្វែងរកអាជីពមានក្នុងប្រទេសកម្ពុជាបន្ថែមទៀត។

ចម្លើយអាចមាន៖ សួរគ្រូ ស្រាវជ្រាវក្នុងបណ្ណាល័យ(ដូចជាវចនានុក្រមការងាររបស់អង្គការស៊ីប៉ា និងធនធានដទៃទៀតដែលអ្នកអាចមាន) ធនធានដែលសិស្សបានស្រាវជ្រាវពីឆ្នាំមុន (ប្រសិនបើមាន) អ៊ីនធឺណេត សួរគ្រួសារ មិត្តភ័ក្ដ ចាប់ផ្ដើមសង្កេតការងារផ្សេងៗក្នុងសហគមន៍របស់ពួកគេ។ល។

នាំសិស្សទៅបណ្ណាល័យ ឬកន្លែងដែលធនធានអាជីពបានរក្សាទុក និងឱ្យពួកគេស្វែងរកឯកសារទាក់ទង នឹង ការងារ និងអាជីព។ ចូរប្រាកដថាពួកគេអាចស្វែងរកធនធានទាំងនោះបាន។

ប្រសិនបើនៅសល់ពេល ឱ្យសិស្សចាប់ផ្ដើមស្រាវជ្រាវការងារបន្ថែមទៀតដើម្បីដាក់ចូលទៅក្នុងបញ្ជីដែលពួកគេបានធ្វើ។

☞ ផ្ដល់ឱ្យក្រុមនីមួយៗនូវស៊ីមីមួយ និងប្រាប់ពួកគេឱ្យសរសេរឈ្មោះក្រុម ឬលេខក្រុមរបស់ពួកគេឱ្យបានច្បាស់លាស់។ ពន្យល់ពួកគេថា ពួកគេនឹងត្រូវរក្សាកិច្ចការរបស់ពួកគេទាំងអស់ដែលបានបំពេញតាមលំដាប់ ហើយក្រុមប្រឹក្សាកុមារ ទទួលបានច្បាប់ចតចម្លងរបស់ពួកគេ។ ឱ្យក្រុមនីមួយៗទុកបញ្ជីឈ្មោះការងារដែលពួកគេបានធ្វើក្នុងស៊ីមីនោះ។

**កិច្ចការផ្ទះ:**

ប្រាប់សិស្សឱ្យចម្លងតារាងខាងក្រោមក្នុងសៀវភៅសរសេររបស់ពួកគេ។

| 1. ការងារដែលមានក្នុងសហគមន៍របស់យើង | 2. ការងារដែលមិនមានក្នុងសហគមន៍យើងប៉ុន្តែមានក្នុងស្រុក ឬខេត្តរបស់យើង | 3. ការងារដែលមិនមានក្នុងស្រុក ឬខេត្តរបស់យើង ប៉ុន្តែមានក្នុងប្រទេសកម្ពុជា |
|---|---|---|
| | | |

ពួកគគេួរបំពញេក្នុងតារាងនូវឈ្មោះការងារយ៉ាងតិចណាស់៥ឬ៦ការងារក្នុងតារាងនីមួយៗដលែពួកគគេិតថាគួរឱ្យ ចាប់អារម្មណ៍។ ពួកគេគួរព្យាយាមបន្ថែមការងារយ៉ាងតិចណាស់ពីរទៀត ទៅក្នុងតារាងរបស់ពួកគេដែលពួកគេមិនបានរៀប រាប់ក្នុងថ្នាក់។ ពួកគេអាចប្រើប្រាស់វិធីស្រាវជ្រាវផ្សេងៗដែលបានពិភាក្សាក្នុងក្រុមដើម្បីធ្វើកិច្ចការនេះ។ ពន្យល់ថា អ្នកនឹងពិនិត្យមើលកិច្ចការផ្ទះនេះនៅពេលបន្ទាប់។

# មេរៀនទី ២: ការងារក្នុងមូលដ្ឋាន

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- បាល់ក្រដាសសម្រាប់ល្បែងបាល់ក្រដាស
- ក្រដាស់រ៉ាម ហ្វឺត និងស្កុត

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាចៈ

១. ធ្វើផែនទីឱកាសការងារក្នុងមូលដ្ឋាន
២. រៀបរាប់ពីការងារដែលមាននៅក្នុងកន្លែងធ្វើការនីមួយៗ

## សេចក្ដីផ្ដើមៈ ការរំឭកមេរៀនចាស់ 🕑 ២០ នាទី

ល្បែងបាល់ក្រដាសៈ

អ្នកចូលរួមរំឭកពីមេរៀនចាស់ ដោយការលេងល្បែងបាល់ក្រដាស។ សំណួរនីមួយៗ ត្រូវបានសរសេរនៅលើក្រដាសដាច់ដោយឡែកពីគ្នា។ ក្រដាសដែលមានសំណួរចុងក្រោយគេ (សំណួរទី៨) ត្រូវច្របាច់ធ្វើជាបាល់ទីមួយ។ សំណួរបន្ទាប់ពីសំណួរចុងក្រោយ (សំណួរទី៧) ត្រូវដាក់ពីលើ ហើយធ្វើរបៀបនេះរហូតដល់ សំណួរទី១ដែលស្ថិតនៅខាងក្រៅគេបំផុតនៃបាល់។

អ្នកប្រឹក្សាអាជីពគួរប្រើសំណួរខាងក្រោមដើម្បីធ្វើជាបាល់ក្រដាសទាក់ទងនឹងមេរៀនមុនៈ

៨. រៀបរាប់ការងារមួយដែលមិនមានក្នុងតំបន់របស់អ្នក ប៉ុន្តែមានក្នុងប្រទេសកម្ពុជា។
៧. រៀបរាប់ការងារចំនួនពីរដែលមិនមានក្នុងតំបន់របស់អ្នក ប៉ុន្តែមានក្នុងប្រទេសកម្ពុជា។
៦. រៀបរាប់ការងារមួយដែលមានក្នុងតំបន់របស់អ្នក។
៥. រៀបរាប់ការងារពីរដែលមានក្នុងតំបន់របស់អ្នក។
៤. រៀបរាប់ធាតុមួយក្នុងចំណោមធាតុទាំងបីនៃសេចក្ដីណែនាំពីអាជីពក្នុងសាលារៀន
៣. តើអ្វីជាភាពខុសប្លែកគ្នារវាងការងារ និងអាជីព?
២. តើធនធានអាជីពត្រូវបានរក្សាទុកនៅកន្លែងណានៃសាលារៀនរបស់អ្នក?
១. តើធនធានអាជីពអ្វីខ្លះដែលយើងមានរួចហើយក្នុងសាលារៀន?



អ្នកប្រឹក្សាអាជីពឱ្យសិស្សឈរជារង្វង់ធំមួយ និងឱ្យពួកគេហុចបាល់គ្នា ខណៈពេលអ្នកដទៃទះដៃរបស់ពួកគេ។

នៅពេលដែលគ្រូស្រែកថា "ឈប់" សិស្សឈប់ទះដៃ ហើយសិស្សដែលកំពុងកាន់បាល់នោះ ត្រូវបកយកស្រទាប់ខាងក្រៅនៃបាល់នោះមួយជាន់ ហើយអានសំណួរ និងព្យាយាមឆ្លើយវា។ ដំណើរការនេះត្រូវធ្វើឡើងរហូតដល់សំណួរទាំងអស់ត្រូវបានឆ្លើយ។

សិស្សអង្គុយតាមក្រុមរបស់ពួកគេ ហើយអ្នកប្រឹក្សាអាជីពឱ្យសិស្សចែករំលែកជាមួយមិត្តភក្តិអង្គុយជិតគ្នា អំពីតារាងការងារ ដែលពួកគេបានបំពេញជាកិច្ចការផ្ទះ ហើយពិភាក្សាគ្នា ប្រសិនបើពួកគេអាចរកការងារពីរ ដែលមិនត្រូវបានពិភាក្សាក្នុងមេរៀនមុន។ ៥នាទីបន្ទាប់មក អ្នកប្រឹក្សាអាជីពឱ្យសិស្សមួយចំនួនចែករំលែកការងារផ្សេងៗ ដែលពួកគេគិតថាមិនត្រូវបានលើកយកមកពិភាក្សាក្នុងមេរៀនមុន។

## សកម្មភាពសំខាន់: ការធ្វើផែនទីការងារនៅក្នុងមូលដ្ឋាន

៧០ នាទី

អ្នកប្រឹក្សាអាជីពពន្យល់ទៅកាន់អ្នកចូលរួមថាពួកគេ នឹងធ្វើផែនទីឱកាសការងារក្នុងមូលដ្ឋានមួយដែលមានក្នុងតំបន់របស់ពួកគេរួមបញ្ចូលទាំង ការងាររដ្ឋ និងសេវាកម្ម (ឃុំ ប៉ូលីស មណ្ឌលសុខភាព/មន្ទីរពេទ្យ កន្លែងពន្លត់អគ្គីភ័យ ទាហាន។ល។) ជំនួញ ក្រុមហ៊ុន ធនាគារ និងរោងចក្រ អង្គការ ផ្សារ និងតំបន់កសិកម្មសំខាន់ៗ...។ល។

តើតំបន់សំខាន់ណាខ្លះដែលនៅជិតសាលារៀន ហើយយើងអាចរកការងារបាន?

អ្នកប្រឹក្សាអាជីពណែនាំសិស្សឱ្យគិតអំពីប្រភេទខុសៗគ្នានៃការងារ និងទីកន្លែងពួកគេស្ថិតនៅ - គិតអំពីប្រភេទខុសៗគ្នានៃការងារ - ការងាររដ្ឋ ជំនួញ អង្គការ ផ្សារ កសិកម្ម ធនាគារ សេវាកម្ម...។ល។
ប្រសិនបើអាចធ្វើបាន ហើយមានពេលវេលា អ្នកប្រឹក្សាអាជីពអាចនាំសិស្សដើរ ១០ឬ១៥នាទី ជុំវិញតំបន់មូលដ្ឋានដើម្បីមើលកន្លែងធ្វើការផ្សេងៗក្នុងមូលដ្ឋាន។

ពិភាក្សាជាមួយក្រុមទាំង៦ ថាតើកន្លែងណាខ្លះដែលក្រុមនីមួយៗនឹងយកចិត្តទុកដាក់ ហើយឱ្យពួកគេចាប់ផ្តើមគូសផែនទីមួយអំពីកន្លែងការងារ ៤កន្លែងផ្សេងគ្នានៅលើក្រដាស A4 ពីរសន្លឹក។ រយៈពេល ១០ ឬ១៥នាទីក្រោយ បញ្ឈប់ការងារក្រុមទាំងអស់។ ពន្យល់ថា កន្លែងធ្វើការនីមួយៗអាចមានការងារច្រើនប្រភេទ។

តើការងារអ្វីខ្លះដែលអ្នកអាចរកបាននៅក្នុងផ្ទះសំណាក់?

ចម្លើយដែលអាចមាន៖ អ្នកទទួលភ្ញៀវ/អ្នកគិតលុយ អ្នកគ្រប់គ្រង អ្នកអនាម័យ (ប្រហែលមានទាំងបុគ្គលិកភោជនីយដ្ឋាន)។ល។

តើការងារអ្វីខ្លះដែលអ្នកអាចរកបាននៅក្នុងធនាគារ?

ចម្លើយដែលអាចមាន៖ អ្នកគិតលុយ អ្នកគ្រប់គ្រង អ្នកដឹកនាំ អ្នកទីផ្សារ អ្នកទំនាក់ទំនង អ្នកផ្តល់សេវាកម្មសន្តិសុខ។ល។

តើការងារអ្វីខ្លះដែលមានក្នុងផ្នែកកសិកម្ម?

កសិករដាំស្រូវ អ្នកដាំកៅស៊ូ អ្នកនេសាទ ពេទ្យសត្វ ប្រធានផ្នែកកសិកម្ម អ្នករដ្ឋបាល បុគ្គលិកបច្ចេកទេសហិរញ្ញវត្ថុ...
ប្រាប់ក្រុមទាំងអស់ឱ្យរៀបរាប់ការងារផ្សេងៗ ដែលពួកគេអាចនឹកឃើញសម្រាប់កន្លែងធ្វើការនីមួយៗដែលពួកគេបានគូសនៅលើក្រដាស A4។ ដើរពិនិត្យមើល និងសួរសំណួរដើម្បីឱ្យពួកគេអាចបន្ថែមការងារឱ្យបានច្រើនតាមដែលពួកគេអាចបន្ថែមបានសម្រាប់កន្លែងធ្វើការនីមួយៗដូចក្នុងឧទាហរណ៍ខាងលើ។



១៥នាទីបន្ទាប់ អ្នកប្រឹក្សាអាជីពគូររូបសាលារៀននៅលើក្ដារខៀន ហើយឱ្យសមាជិកម្នាក់ពីក្នុងក្រុមនីមួយៗឡើងមកបង្ហាញទីតាំងកន្លែងការងាររបស់ពួកគេដោយភ្ជាប់ជាមួយនឹងសាលារៀន។ ពួកគេត្រូវនិយាយពីកន្លែងធ្វើការដែលពួកគេមាន និងការងារណាខ្លះដែលប្រហែលជាអាចមានក្នុងកន្លែងធ្វើការនោះ។ ក្រុមដទៃទៀតអាចផ្ដល់មតិយោបល់ ឬបន្ថែមព័ត៌មានដទៃទៀត ប្រសិនបើពួកគេស្គាល់កន្លែងនោះ។

ក្រុមនីមួយៗគួរទុកកិច្ចការរបស់ពួកគេក្នុងស៊ីមីរបស់ក្រុម ឬពួកគេអាចដាក់តាំងការងាររបស់ពួកគេក្នុងបណ្ណាល័យ ឬតាមជញ្ជាំងនៃថ្នាក់រៀនដោយមានជំនួយពីក្រុមប្រឹក្សាកុមារ។

តើយើងអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពីកន្លែងធ្វើការនីមួយៗដោយរបៀបណា?
ចម្លើយដែលអាចមាន៖ សួរបងប្អូន ឬមិត្តភ័ក្ដ សួរមិត្តរួមថ្នាក់ដែលស្គាល់នរណាម្នាក់ធ្វើការនៅកន្លែងនោះ រកមើលក្នុងបណ្ណាល័យ ស្រាវជ្រាវតាមអ៊ីនធើណេត សួរគ្រូ ឬឪពុកម្ដាយ សួរនរណាម្នាក់ដែលធ្វើការនៅទីនោះ ប្រសិនបើពួកគេមិនប្រកាន់អ្នកដែលស្វែងរកព័ត៌មានពីការងារនៅកន្លែងនោះ។

## កិច្ចការផ្ទះ៖ ១០ នាទី

សិស្សម្នាក់ៗគួរជ្រើសរើសកន្លែងធ្វើការមួយ ឬពីរ ដែលពួកគេចាប់អារម្មណ៍ក្នុងការស្រាវជ្រាវ ហើយសរសេរការងារទាំងអស់ដែលមាននៅកន្លែងនោះ ព្រមទាំងគូសផែនទីពីទីតាំងកន្លែងធ្វើការនោះក្នុងសៀវភៅសរសេររបស់ពួកគេ។

អ្នកប្រឹក្សាអាជីពគួរពន្យល់ថា ពួកគេនឹងត្រូវពិភាក្សាពីកិច្ចការផ្ទះរបស់ពួកគេនៅពេលក្រោយ។

# មេរៀនទី ៣: ការណែនាំអំពីកិច្ចសម្ភាសករណីសិក្សា

រយៈពេលបង្រៀន: ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

សម្ភារឧបទេស ធនធានដែលត្រូវការ

ឯកសារ ១ ចែកសិស្ស ៖ ទម្រង់ករណីសិក្សា

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- រៀបចំសម្រាប់ការសម្ភាស និងសម្ភាសមនុស្សដែលពួកគេស្គាល់ពីការងាររបស់ពួកគេ
- សិក្សាស្រាវជ្រាវលើទម្រង់គំរូនៃសំណួរសម្ភាសន៍

## រំឭកមេរៀនចាស់ ១៥ នាទី

ហៅសិស្សម្នាក់មកខាងមុខ ប្រាប់ឱ្យគិតអំពីការងារមួយដែលសិស្សស្គាល់ ហើយធ្វើសកម្មភាពនៃការងារនោះ (ហាមនិយាយ) ដើម្បីឱ្យសិស្សដទៃទៀតទាយថាតើការងារអ្វីដែលគេកំពុងធ្វើ។ ធ្វើរបៀបនេះជាមួយសិស្សម្នាក់ ឬពីរនាក់ទៀត។

ឱ្យសិស្សយកកិច្ចការផ្ទះរបស់ពួកគេចេញមក ហើយពិភាក្សាវាជាមួយសិស្សដទៃទៀតក្នុងក្រុមរបស់ពួកគេ។ ឱ្យសិស្សម្នាក់ ឬពីរនាក់ចែករំលែកជាមួយសិស្សដទៃទៀតអំពីការងារដែលពួកគេបានរៀបរាប់សម្រាប់កន្លែងធ្វើការមួយ។

## សេចក្ដីផ្ដើម: ការធ្វើករណីសិក្សា ២០ នាទី

ពន្យល់ថា មេរៀនបន្ទាប់នឹងពិនិត្យមើលពីការបង្កើតករណីសិក្សាពីមនុស្សក្នុងមូលដ្ឋាន និងការងាររបស់ពួកគេ។ នេះមានន័យថា សិស្សនឹងប្រមូលព័ត៌មានអំពីការងារដែលប្រជាជនកំពុងធ្វើក្នុងសហគមន៍ និងស្វែងយល់ពីរបៀបដែលពួកគេទទួលបានការងារនេះ ព្រមទាំងអ្វីដែលគាត់/នាងត្រូវធ្វើជាប្រចាំថ្ងៃក្នុងការងាររបស់ពួកគេ។

តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីបង្កើតករណីសិក្សាអំពីមនុស្សដែលធ្វើការក្នុងមូលដ្ឋាន? បង្ហាញខាងក្រោម




## សកម្មភាពសំខាន់: ការធ្វើផែនការសម្ភាសន៍ករណីសិក្សា ៦០ នាទី

ពន្យល់ទៅកាន់សិស្សថា នៅពេលដែលយើងសម្ភាសនរណាម្នាក់ យើងត្រូវគិតឱ្យច្បាស់ពីអ្វីដែលយើងចង់ដឹង និងព្យាយាមរៀបចំសំណួររបស់យើង ដូច្នេះសំណួរទាំងនេះជួយយើងឱ្យស្វែងរកព័ត៌មានដែលយើងត្រូវការ។

សួរពួកគេថាតើចំណុចអ្វីខ្លះដែលពួក គេចង់ដឹងអំពីការងារមួយដើម្បីឱ្យដឹងថា តើវាសក្តិសមជាមួយពួកគេដែរឬទេ។
ចម្លើយប្រហែលជារួមបញ្ចូលទាំង៖ ជំនាញ តួនាទី និងទំនួលខុសត្រូវ តើការអប់រំ និងការបណ្តុះបណ្តាលអ្វីខ្លះដែលត្រូវការ។ល។

ចែកឯកសារទី១ សម្រាប់សិស្ស៖ ណែនាំទម្រង់ករណីសិក្សា។ធ្វើឱ្យច្បាស់ថាវាគឺគ្រាន់តែទម្រង់ណែនាំមួយប៉ុណ្ណោះ។ ប្រាប់សិស្សថា ពួកគេនឹងសម្ភាសអ្នកដើម្បីស្វែងរកព័ត៌មានពីការងាររបស់អ្នក។ ប្រាប់ពួកគេឱ្យមើលសំណួរ និងសម្រេចជាមួយក្រុមរបស់ពួកគេថាតើទម្រង់បែបបនឹងអាចឆ្លើយប្រាប់ព័ត៌មានទាំងអស់ដែលពួកគេត្រូវការដឹងបានដែរឬទេ។ ពួកគេគួរសរសេរសំណួរបន្ថែមដែលពួកគេចង់ស្វែងរកព័ត៌មានឱ្យកាន់តែច្បាស់ទៀតអំពីការងាររបស់អ្នក។
១០នាទីក្រោយ សួរសិស្សថាតើពួកគេមានសំណួរបន្ថែមដើម្បីបន្ថែមទៅក្នុងទម្រង់ និងចែករំលែកជាមួយសិស្សក្នុងថ្នាក់ដែរឬទេ។ សរសើរសិស្សសម្រាប់សំណួរដែលពួកគេបានបន្ថែម ព្រោះនេះបញ្ជាក់ថាពួកគេកំពុងគិតដោយខ្លួនរបស់ពួកគេ ហើយនេះមានសារៈសំខាន់សម្រាប់លទ្ធភាពនាពេលអនាគតរបស់ពួកគេក្នុងការស្រាវជ្រាវព័ត៌មាន។
ឱ្យសិស្សគិតអំពីពេលដែលពួកគេទៅសម្ភាសប្រជាជន អ្វីដែលពួកគេគួរធ្វើ មុនពេលពួកគេចាប់ផ្តើមសួរសំណួរសម្ភាសន៍ដែលពួកគេបានរៀបចំ។
ចម្លើយដែលអាចមាន៖ ចូរប្រាកដថា វាជាពេលវេលាសមរម្យដើម្បីសួរសំណួរ។ ពន្យល់ពីអ្វីដែលអ្នកចង់សម្ភាសពួកគេ និងរយៈពេលដែលនឹងត្រូវចំណាយ ណែនាំខ្លួនរបស់អ្នក អរគុណពួកគេដែលបានអនុញ្ញាតឱ្យអ្នកសម្ភាស។

ឱ្យសិស្សធ្វើការនៅក្នុងក្រុមរបស់ពួកគេ និងឱ្យមនុស្សម្នាក់សម្តែងជាអ្នក (គ្រូ/នាយកសាលា) ដែលត្រូវបានគេសម្ភាសហើយអ្នកដទៃជាអ្នកសម្ភាស។ ពួកគេគួរចងចាំក្នុងទំនាក់ទំនងជាមួយសិស្ស ដែលដើរតួនោះដោយសមរម្យ ហើយមិនចាប់ផ្តើមសួរសំណួរភ្លាមៗទេ។ ពួកគេគួរសួរសំណួរក្នុងទម្រង់សម្ភាសរបស់ពួកគេ ហើយសិស្សអាចព្យាយាមឆ្លើយសំណួរ បើទោះបីជាពួកគេប្រហែលជាមិនដឹងចម្លើយសម្រាប់សំណួរទាំងនោះក៏ដោយ។
នៅពេលក្រុមបានបញ្ចប់ ប្រាប់សិស្សថា ឥឡូវពួកគេមានឱកាសសម្ភាសអ្នក និងស្វែងយល់ពីបទពិសោធន៍នៃ អាជីពបង្រៀនរបស់អ្នក។ ឱ្យក្រុមមួយស្ម័គ្រចិត្តមកធ្វើជាអ្នកសម្ភាស។ រំឭកពួកគេថាពួកគេមិនគួរត្រឹមតែសួរសំណួរ ប៉ុណ្ណោះទេ ពួកគេគួរទំនាក់ទំនងជាមួយអ្នក ដូចអ្វីដែលពួកគេធ្វើជាមួយនរណាម្នាក់ កំពុងធ្វើការក្នុងសហគមន៍ ដែលពួកគេមិនស្គាល់ច្បាស់ ដូច្នេះពួកគេអាចអនុវត្តជំនាញសម្ភាសពិតប្រាកដ។ សិស្សដទៃទៀតក្នុងថ្នាក់ គួរស្តាប់ចម្លើយរបស់អ្នក ហើយព្យាយាមកត់ត្រាចម្លើយរបស់អ្នក។

នៅពេលសិស្សបានបញ្ចប់ការសម្ភាសអ្នក ឱ្យសិស្សដទៃទៀតផ្តល់មតិយោបល់ស្ថាបនាអំពីអ្វីដែលពួកគេបានធ្វើល្អ និងអ្វីដែលគួរកែលម្អក្នុងរបៀបទំនាក់ទំនងក្នុងការសម្ភាស។ ទន្ទឹមនឹងនេះ សួរសិស្សថាតើអ្វីខ្លះជាភាពលំបាកក្នុងការកត់ត្រា ក្នុងកំឡុងពេលសម្ភាស និងរបៀបដែលពួកគេនឹងព្យាយាមដោះស្រាយបញ្ហានេះ។

**កិច្ចការផ្ទះ** **៥ នាទី**

ឱ្យសិស្សសម្ភាសសមាជិកគ្រួសារ ឬអ្នកជិតខាងអំពីការងាររបស់ពួកគេ។ រំឭកពួកគេឱ្យមើលសំណួរគំរូ និងពិនិត្យមើលថាតើវាសក្តិសម ឬត្រូវកែសម្រួលសម្រាប់ការងាររបស់បុគ្គលនោះ ឬក៏ត្រូវធ្វើវាឱ្យងាយស្រួលយល់។ ប្រសិនបើអាច ក្មេងស្រីគួរព្យាយាមសួរស្ត្រី និងក្មេងប្រុសគួរព្យាយាមសួរបុរស ដូច្នេះវានឹងមានការលាយបញ្ចូលគ្នានៃប្រជាជនបុរស និងស្ត្រីដែលត្រូវបានសម្ភាស។ កិច្ចការផ្ទះនេះអាចធ្វើជាបុគ្គលរៀងៗខ្លួន ឬធ្វើជាដៃគូ។ រំឭកសិស្សថាកិច្ចការផ្ទះនេះសំខាន់ណាស់ ត្រូវបំពេញវា ដោយសារតែវានឹងត្រូវបានយកមកប្រើនៅមេរៀនក្រោយ។
សិស្សគួរបំពេញកិច្ចការផ្ទះរបស់ពួកគេដោយការសរសេរឱ្យបានស្អាតបាត ឬប្រសិនបើមានកុំព្យូទ័រក្នុងសាលា ចូរវាយវាដោយប្រើក្រដាសរ៉ាម ព្រោះវានឹងត្រូវរក្សាទុកក្នុងសាលារៀន ហើយនឹងត្រូវបានប្រើប្រាស់សម្រាប់សិស្សដទៃទៀតរៀន។ ពួកគេអាចប្រើសំណួរដែលពួកគេបានរៀបចំធ្វើជាចំណងជើង និងសរសេរចម្លើយនៅខាងក្រោម។ ពួកគេគួរសរសេរឈ្មោះរបស់ពួកគេ និងបន្ទប់រៀននៅលើក្រដាស A4 ដូច្នេះសិស្សដទៃនឹងស្គាល់។

ឈ្មោះអ្នកសម្ភាស: ____________________ ភេទ ___ ថ្នាក់ _____ ឈ្មោះសាលា ____________________

ឈ្មោះអ្នកត្រូវសម្ភាស: ________________ ភេទ ___ កន្លែងធ្វើការ ______________ មុខដំណែង ____________

ស្រុក ________________ ខេត្ត ____________________ លេខទូរស័ព្ទ ________________________

អ្នកចូលរួម 1. ________________________ កាលបរិច្ឆេទ ________________________

2. ________________________

3. ________________________

4. ________________________

5 ________________________

6 ________________________

| សំណួរ | កត់ត្រាចម្លើយ |
| --- | --- |
| តើអ្នកធ្វើការអ្វី ? | |
| តើអ្នកធ្វើការនេះរយៈពេលយូរប៉ុណ្ណា ? | |
| តើក្នុងមួយថ្ងៃជាធម្មតាអ្នកធ្វើការប៉ុន្មានម៉ោង ? ពីម៉ោងណាដល់ម៉ោងណា ? | |
| តើអ្នកធ្វើការប៉ុន្មានថ្ងៃក្នុងមួយសប្តាហ៍ ? តើអ្នកឈប់ថ្ងៃបុណ្យជាតិដែរឬទេ ? | |
| តើហេតុអ្វីបានជាអ្នកជ្រើសរើសយកការងារនេះ ? | |
| តើអ្នកត្រូវបានបណ្តុះបណ្តាលសម្រាប់ជំនាញនេះដោយរបៀបណា ? ( ក្នុងពេលបំពេញការងារ មិត្តរួមការងារ មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការ ពីគ្រួសារ... ) | |
| តើជំនាញ និងការអប់រំអ្វីខ្លះដែលគួរតែត្រូវការ សម្រាប់ការងារនេះ ? | |
| តើអ្នកទទួលបានការងារនេះដោយរបៀបណា ? ដាក់ពាក្យតាមការផ្សព្វផ្សាយ មិត្តភ័ក្ត្រ ជំនួញផ្ទាល់ខ្លួន។ | |
| តើជាធម្មតាអ្នកត្រូវធ្វើអ្វីខ្លះនៅកន្លែងការងាររបស់អ្នក ? | |
| តើអ្នកចូលចិត្តអ្វីជាងគេអំពីការងារនេះ ? | |
| តើអ្វីដែលអ្នកចូលចិត្តតិចជាងគេអំពីការងាររបស់អ្នក ? | |
| តើអ្នកធ្វើការនៅមួយកន្លែង ឬតើអ្នកត្រូវធ្វើដំណើរទៅកាន់កន្លែងផ្សេងៗ ? | |
| តើអនុសាសន៍អ្វីខ្លះដែលអ្នកអាចផ្តល់ឱ្យយើងដើម្បីស្វែងរកការងារដែលស្របជាមួយអ្នក ? | |
| តើមានមនុស្សប៉ុន្មាននាក់ធ្វើការនៅទីនោះ ? តើការងារខុសគ្នាអ្វីខ្លះដែលអ្នកបានធ្វើ ? | |
| សំណួរបន្ថែម ( សូមបញ្ជាក់ ) | |
| | |

# មេរៀនទី ៤: ការអភិវឌ្ឍជំនាញសម្ភាស

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារ១ ចែកសិស្ស ៖ ទម្រង់ករណីសិក្សា
- ក្រដាសតូចៗសម្រាប់បោះឆ្នោត

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- ធ្វើផែនការ និងរៀបចំករណីសិក្សាជាមួយអ្នកដែលនៅក្រៅពីគ្រួសារ ឬមិត្តភ័ក្ដរបស់ពួកគេ។

## សេចក្ដីផ្ដើម : រំឭកមេរៀន 🕑 ១៥ នាទី

✋ ប្រាប់សិស្សឱ្យយកកិច្ចការផ្ទះពួកគេចេញមក ហើយឱ្យពួកគេពិនិត្យមើល តើមានដាក់ឈ្មោះ និងថ្នាក់នៅលើក្រដាស់រាមហើយឬនៅ? ដូច្នេះសិស្សដទៃទៀតស្គាល់ថានរណាដែលពួកគេអាចទាក់ទងដើម្បីសម្ភាសនាពេលអនាគត។ បន្ទាប់មក ពួកគេគួរពិភាក្សាពីការសម្ភាសដែលពួកគេបានធ្វើជាមួយឪពុកម្ដាយ ឬអ្នកជិតខាងរបស់ពួកគេព្រមទាំងសរសេរការងារទាំងអស់ដែលសមាជិកក្នុងក្រុមរបស់ពួកគេបានរកឃើញ។

✎ ឱ្យក្រុមនីមួយៗអានបញ្ជីការងារដែលក្រុមរបស់ពួកគេបានរកឃើញ និងកត់ត្រានៅលើក្ដារខៀនតាមលេខរៀង (មើលឧទាហរណ៍ខាងក្រោម)។ កុំសរសេរការងារជាន់គ្នា ប្រសិនបើសិស្សបានរកឃើញការងារដូចគ្នា។ ប្រាប់សិស្សឱ្យកត់បញ្ជីការងារទុកក្នុងសៀវភៅរបស់ពួកគេ ដូច្នេះពួកគេអាចដឹងពីព័ត៌មានដែលមានសម្រាប់ពួកគេក្នុងការស្រាវជ្រាវជាមួយមិត្តរួមថ្នាក់របស់ពួកគេ។

1. ជាងកាត់ដេរ
2. អ្នកលក់នៅផ្សារ
3. ......

## សកម្មភាពសំខាន់: ការអភិវឌ្ឍជំនាញសម្ភាសស្រាវជ្រាវ 🕑 ៧០ នាទី

👄 ឱ្យសិស្សមើលការងារទាំងអស់ដែលមាននៅលើក្ដារខៀន និងគិតរៀងៗខ្លួនថាតើការងារមួយណាដែលពួកគេចង់ស្រាវជ្រាវខ្លាំងបំផុត។ប្រាប់ពួកគេថាពួកគេមានឆ្នោតមួយសន្លឹកតែប៉ុណ្ណោះហើយអាចសរសេរលេខនៃការងារមួយដែលពួកគេស្រាវជ្រាវ នៅលើក្រដាសនេះ។

ឱ្យតំណាងក្រុមនីមួយៗប្រមូលសន្លឹកឆ្នោតរបស់ក្រុមខ្លួនហើយយកវាមកខាងមុខ។បន្ទាប់មកស្នើសុំអ្នកស្ម័គ្រចិត្តពីរនាក់ដើម្បីជួយរាប់សន្លឹកឆ្នោត។ សិស្សម្នាក់បើកសន្លឹកឆ្នោតមួយម្ដងៗ ហើយសិស្សម្នាក់ទៀតកត់ត្រាឆ្នោតម្ដងមួយៗនៅជិត

ការងារដែលទាក់ទង នៅពេលគេហៅ។ ចុងក្រោយ ពួកគេរកមើលថាតើការងារមួយណាដែលទទួលបានសម្លេងច្រើនជាងគេបំផុត។

ឱ្យសិស្សម្នាក់សម្ភាសអ្នកដែលការងាររបស់គាត់/នាងទទួលបានសម្លេងច្រើនជាងគេ មកខាងមុខ ហើយសម្តែងជាបុគ្គលម្នាក់នោះ។ ឱ្យសិស្ស ២ ឬ៣នាក់ផ្សេងទៀតធ្វើជាអ្នកសម្ភាស - ពួកគេអាចប្រើឯកសារទី១ សម្រាប់សិស្ស៖ ទម្រង់ករណីសិក្សា។ រំឭកពួកគេថា ពួកគេគួរទំនាក់ទំនង និងគោរពអ្នកដែលពួកគេនឹងត្រូវសម្ភាសឱ្យបានសមរម្យមុនពេលចាប់ផ្តើមសួរសំណួរ។ ឱ្យសិស្សដទៃទៀតសង្កេតមើល និងត្រៀមខ្លួនផ្តល់មតិយោបល់ស្ថាបនា។

នៅបញ្ចប់ការសម្ភាស ទុកឱកាសឱ្យសិស្សដទៃផ្តល់មតិយោបល់ អំពីដំណើរការនៃការសម្ភាស។ បន្ទាប់មកប្រសិនបើនៅសល់ពេល ឱ្យសិស្សសម្ភាសការងារទីពីរដែលទទួលបានសម្លេងច្រើន មកខាងមុខ និងធ្វើការសម្តែងដូចដំណើរការខាងលើ។

ប្រាប់សិស្សឱ្យធ្វើការក្នុងក្រុមរបស់ពួកគេ និងពិភាក្សាពីភាពលំបាកនានាដែលពួកគេបានជួបប្រទះ ឬអាចនឹងជួបប្រទះ នៅពេលសម្ភាសនរណាម្នាក់អំពីការងាររបស់ពួកគេ ព្រមទាំងដំណោះស្រាយចំពោះភាពលំបាកទាំងនោះ។ ១០នាទីក្រោយមក ឱ្យក្រុមផ្តល់មតិយោបល់អំពីភាពលំបាកទាំងនោះដែលពួកគេបានជួប និងដំណោះស្រាយដែលអាចមាន - ព្យាយាមធ្វើឱ្យប្រាកដថា យ៉ាងហោចណាស់បញ្ហាខាងក្រោមត្រូវបានគ្របដណ្តប់...

**ចម្លើយដែលអាចមាន៖**

| បញ្ហា | ដំណោះស្រាយ |
|---|---|
| សំណួរទាំងនោះមានលក្ខណៈផ្លូវការពេក/មិនផ្លូវការគ្រប់គ្រាន់ | គិតអំពីមនុស្សដែលអ្នកនឹងត្រូវសម្ភាស និងសម្រួលសំណួរទៅតាមការអប់រំ/សមត្ថភាពរបស់មនុស្សដែលអ្នកនឹងនិយាយជាមួយ |
| ចម្លើយមិនច្បាស់/មិនគ្រប់ជ្រុងជ្រោយ | សួរសំណួរខ្លីច្បាស់លាស់បន្តបន្ទាប់ដើម្បីទទួលបានចម្លើយដែលអ្នកត្រូវការ |
| មានការលំបាកក្នុងការកត់ត្រា នៅពេលគេកំពុងនិយាយ | សរសេរចំណុចសង្ខេបខ្លីៗ ឬពាក្យគន្លឹះ នៅពេលដំបូង បន្ទាប់មកសរសេរការសម្ភាសឱ្យបានត្រឹមត្រូវ ខណៈពេលដែលព័ត៌មាននៅតែស្ថិតក្នុងចិត្តរបស់អ្នកថ្មីៗ |
| បុគ្គលនោះមានភាពមមាញឹកពេក/ពិបាកជួប | ទំនាក់ទំនងជាមុន ថាតើពួកគេមានពេលដែរឬទេ ប្រសិនបើចាំបាច់ជួបពួកគេនៅពេលផ្សេង |

នៅពេលអ្នកបញ្ចប់ ប្រាប់សិស្សថា អ្នកនឹងរៀបចំទស្សនកិច្ចសិក្សាមួយ ឬក៏អញ្ជើញអ្នកទស្សនាមកកាន់សាលារៀនក្នុងពេលខាងមុខ ដើម្បីធ្វើការសម្ភាសបន្ថែមទៀតជាមួយនយោជក និង/ឬអ្នកផ្តល់ការអប់រំ ឬការបណ្តុះបណ្តាល ដើម្បីចាប់ផ្តើមគិតអំពីកន្លែងការងារដែលពួកគេចង់ដឹងបន្ថែមទៀត។

ឱ្យសិស្សគិតអំពីរបៀបថែរក្សាទុកព័ត៌មានដែលពួកគេស្រាវជ្រាវបានអំពីការងាររបស់ឪពុកម្តាយនិងគ្រួសារ ឬមិត្តភ័ក្តដែលពួកគេបានស្រាវជ្រាវរហូតមកដល់ពេលនេះ ដូចនេះសិស្សទាំងអស់ងាយនឹងរកព័ត៌មានទាំងនោះបាននៅពេលដែលពួកគេត្រូវការចង់មើលវា។

ចម្លើយដែលអាចមាន៖ រក្សាវាទុកក្នុងស៊ីមីក្នុងបណ្ណាល័យ ដូច្នេះសិស្សដទៃទៀតទទួលបានផលប្រយោជន៍ពីវាផងដែរ (ពួកគេអាចធ្វើការជាមួយក្រុមប្រឹក្សាកុមារដើម្បីធ្វើកិច្ចការនេះ) រក្សាវាទុកក្នុងស៊ីមីក្រុមរបស់ពួកគេ ហើយសិស្សដទៃទៀតអាចមើលវាបាននៅពេលចេញលេង។ រៀបចំឱ្យសិស្សធ្វើរបាយការណ៍អំពីប្រធានបទដែលចាប់អារម្មណ៍ក្នុងកំឡុងពេលចេញលេង។ល។

ចូរប្រាកដថា សិស្សមានភាពច្បាស់លាស់អំពីអ្វីដែលជាផែនការរបស់ពួកគេក្នុងការផ្សព្វផ្សាយ និងអ្វីខ្លះជាទំនួលខុសត្រូវរបស់សមាជិកក្នុងក្រុមម្នាក់ៗ និងត្រូវធ្វើការតាមដាននាពេលបន្ទាប់។

**កិច្ចការផ្ទះ** **១៥ នាទី**

សួរសិស្ស "តើវិធីអ្វីខ្លះដែលអ្នកអាចនឹកឃើញ និងអាចប្រើក្នុងការស្រាវជ្រាវរកព័ត៌មាន?"
ចម្លើយដែលអាចមាន៖ ការសម្ភាស ការសួរសំណួរទៅកាន់គ្រូ ឪពុកម្តាយ ឬមិត្តភ័ក្ត្រ រកមើលក្នុងសៀវភៅនិងធនធានដទៃទៀតក្នុងបណ្ណាល័យ ប្រើអ៊ីនធើណេត សង្កេត ធ្វើទស្សនកិច្ចសិក្សា។ល។

ពន្យល់ទៅកាន់សិស្សថា អ្នកចង់ឱ្យពួកគេគិតអំពីឱកាសអ្វីខ្លះដែលពួកគេអាចនឹងមានបន្ទាប់ពីថ្នាក់ទី៩ និងថ្នាក់ទី១២ សម្រាប់ការសិក្សា និងការបណ្តុះបណ្តាលនាពេលអនាគត។ សម្រាប់កិច្ចការផ្ទះ ពួកគេគួរសរសេរនៅក្នុងសៀវភៅរបស់ពួកគេពីជម្រើសអ្វីដែលមាន និងវិធីល្អបំផុតក្នុងការស្រាវជ្រាវអំពីរបៀបក្នុងការដាក់ពាក្យ និងទទួលបានព័ត៌មានបន្ថែមអំពីជម្រើសទាំងនោះ។

# មេរៀនទី ៥: ផ្លូវនៃការសិក្សាសម្រាប់អនាគត

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ មុនពេលបង្រៀន លោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារចែកសិស្សៈ វិធីសិក្សានាពេលអនាគត និងតារាងមុខវិជ្ជាដែលរៀនពូកែ

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- ស្វែងយល់ពីផ្លូវសិក្សាសម្រាប់អនាគតអ្វីខ្លះដែលមានបន្ទាប់ពីថ្នាក់ពី៩ និងទី១២
- បញ្ជាក់ដោយស្មោះត្រង់នូវភាពខ្លាំងនិងខ្សោយសម្រាប់មុខវិជ្ជានីមួយៗ

## សេចក្ដីផ្ដើម 🕑 ២០ នាទី

☝ ករណីសិក្សាដែលបានសម្ភាសកន្លងមក រៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ។ ករណីសិក្សារបស់សិស្សដទៃទៀត ពួកគេបានរៀនពីរបៀបដែលពួកគេបានអនុវត្ត ជួយដោះស្រាយបញ្ហាផ្សេងៗ ដែលមានក្នុងកំឡុងពេល ធ្វើកិច្ចការនេះ។ បន្ទាប់មកពន្យល់ថា ឥឡូវអ្នកនឹងនិយាយពីវិធីសិក្សាសម្រាប់ពេលអនាគត។

⍰ សួរ "តើជម្រើសអ្វីខ្លះ ដើម្បីបន្តការសិក្សារបស់អ្នក បន្ទាប់ពីបញ្ចប់ថ្នាក់ទី ៩ និងទី១២?"

ចម្លើយដែលអាចមានៈ បន្តទៅថ្នាក់វិទ្យាល័យ (ទី១០-១២) ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ សាកលវិទ្យាល័យរដ្ឋ និងឯកជន ការបណ្ដុះបណ្ដាលផ្សេងៗទៀត ឧទាហរណ៍តាមរយៈអង្គការ ក្រុមហ៊ុន... មណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដូចជា វិក្រឹតការខេត្ត/តំបន់ មហាវិទ្យាល័យកសិកម្ម មហាវិទ្យាល័យពេទ្យ។ល។

សរសេរចម្លើយ ដែលសិស្សបានរៀបរាប់តាមលំដាប់លំដោយ។ នៅពេលពួកគេបានបញ្ចប់ ឱ្យពួកគេសម្រេចចិត្តនៅក្នុងក្រុមរបស់ពួកគេ តើជម្រើសមួយណាដែលពួកគេអាចចូលរៀនបាន បន្ទាប់ពីថ្នាក់ទី៩ និងជម្រើសណាខ្លះបន្ទាប់ពីថ្នាក់ទី១២...

៥នាទីបន្ទាប់សួរសិស្សថា ជម្រើសទាំងនេះមាននៅពេលណា និងសរសេរថ្នាក់ទី៩ ឬទី១២ នៅជិតជម្រើសនីមួយៗដែលអ្នកបានសរសេរនៅលើក្ដារខៀន។ (ប្រសិនបើពួកគេធ្វើឱ្យមានកំហុស កុំព្យាយាមកែតម្រូវពួកគេក្នុងពេលនេះ។)

## ស្វែងយល់ការសិក្សាសម្រាប់ពេលអនាគត 🕑 ៤០ នាទី

☝ ចែកឯកសារទី២ ចែកសិស្ស ៖ ផ្លូវសិក្សាសម្រាប់ពេលអនាគត។ ទុកពេលពីរឬបីនាទី ឱ្យសិស្សមើលឯកសារនេះ និងពិនិត្យមើលថាតើមានវិធីសិក្សាផ្សេងទៀត ដែលពួកគេមិនទាន់បាននឹកឃើញដែរឬទេ? និងដើម្បីពិនិត្យមើលថា តើពួកគេបានធ្វើត្រឹមត្រូវ នូវជម្រើសទាំងនោះបាននៅពេលណា?

ឱ្យសិស្សស្ម័គ្រចិត្តម្នាក់ ឬពីរនាក់មកពន្យល់ពីជម្រើសសិក្សាដែលមានក្នុងឯកសារចែកសិស្ស។ ពិនិត្យមើលថា តើសិស្សដឹងថា ជម្រើសមួយណាដែលមានក្នុងខេត្តរបស់អ្នក។

សួរសិស្សថា តើពួកគេមានការយល់ឃើញខុសគ្នាចំពោះគំនិតដែលពួកគេមានពីមុនមកដែរឬទេ និងឱ្យពួកគេមកក្ដារខៀនដើម្បីកែតម្រូវ ឬបន្ថែមព័ត៌មានដែលបានកត់ត្រានៅទីនោះ ដោយរួមបញ្ចូលទាំងថ្នាក់ដែលជម្រើសអាចមាន។




| ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបច្ចេកទេស*<br>(វិទ្យាស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈសាធារណៈចំនួន ៣៨ទូទាំងខេត្ត២៤នៃប្រទេសកម្ពុជា) | | |
|---|---|---|
| កម្រិត | សញ្ញាបត្រ – ប្រព័ន្ធបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបច្ចេកទេស | លក្ខខណ្ឌចូលរៀន |
| 8 | ថ្នាក់បណ្ឌិតនៃបច្ចេកទេស/ពាណិជ្ជសាស្ត្រ | ថ្នាក់អនុបណ្ឌិតវិទ្យាសាស្ត្រ/សិល្បៈ |
| 7 | ថ្នាក់អនុបណ្ឌិត បច្ចេកទេស/ពាណិជ្ជសាស្ត្រ | ថ្នាក់បរិញ្ញាបត្រ |
| 6 | ថ្នាក់បរិញ្ញាបត្របច្ចេកទេស/ពាណិជ្ជសាស្ត្រ | បរិញ្ញាបត្ររង (រៀនក្នុងថ្នាក់ BA BAT ២ឆ្នាំរួចហើយក្នុងជំនាញដូចគ្នា) |
| 5 | ថ្នាក់បរិញ្ញាបត្ររង | សញ្ញាបត្រវិជ្ជាជីវៈកម្រិត ៣/ថ្នាក់ទី១២ /សញ្ញាបត្រវិជ្ជាជីវៈដែលមានកម្រិតស្មើ (សញ្ញាបត្របច្ចេកទេសវិជ្ជាជីវៈកម្រិត៣) |
| 4 | សញ្ញាបត្រវិជ្ជាជីវៈកម្រិត ៣ | សញ្ញាបត្រវិជ្ជាជីវៈកម្រិត ២ ឬសញ្ញាបត្រវិជ្ជាជីវៈដែលមានកម្រិតស្មើ (សញ្ញាបត្របច្ចេកទេសវិជ្ជាជីវៈកម្រិត២) |
| 3 | សញ្ញាបត្រវិជ្ជាជីវៈកម្រិត ២ | សញ្ញាបត្រវិជ្ជាជីវៈកម្រិត ១ ឬសញ្ញាបត្រវិជ្ជាជីវៈដែលមានកម្រិតស្មើ (សញ្ញាបត្របច្ចេកទេសវិជ្ជាជីវៈកម្រិត១) |
| 2 | សញ្ញាបត្រវិជ្ជាជីវៈកម្រិត ១ | ថ្នាក់ទី៩ ឬសញ្ញាបត្រវិជ្ជាជីវៈដែលមានកម្រិតស្មើ (បំណិនមូលដ្ឋាន និងការចេះអានចេះសរសេរ) |
| 1 | សញ្ញាបត្របណ្ដុះបណ្ដាលវិជ្ជាជីវៈ | / |

ក្នុងខេត្តខ្លះ មានតែសញ្ញាបត្រវិជ្ជាជីវៈ។ លេខទាក់ទង មណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈអាចរកបាននៅលើវេបសាយ៖ www.nea.gov.kh

✧ សួរសំណួរខាងក្រោមទៅកាន់ថ្នាក់ទាំងមូល និងអនុញ្ញាតឱ្យសិស្ស២ ឬ៣នាក់ឆ្លើយសំណួរនីមួយៗ៖

១. តើអ្វីខ្លះជាជម្រើសសិក្សាសំខាន់ៗបន្ទាប់ពីថ្នាក់ទី៩?
២. តើអ្វីខ្លះជាជម្រើសសិក្សាសំខាន់ៗបន្ទាប់ពីថ្នាក់ទី១២?
៣. តើមុខវិជ្ជាអ្វីខ្លះដែលអ្នកអាចសិក្សានៅវិទ្យាល័យ?
ចម្លើយដែលអាចមាន៖ ស្រដៀងគ្នានឹងមុខវិជ្ជាថ្នាក់ទី៧-៩ ប៉ុន្តែស៊ីជម្រៅជាង
៤. តើមុខវិជ្ជាអ្វីខ្លះដែលអ្នកអាចសិក្សានៅថ្នាក់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស?
ចម្លើយដែលអាចមាន៖ មុខវិជ្ជាបច្ចេកទេស និងវិជ្ជាជីវៈបន្ថែមទៀត
៥. តើអ្នកអាចគិតអំពីគុណសម្បត្តិនៃការសិក្សារហូតដល់ថ្នាក់ទី១២ដែរឬទេ?
ចម្លើយដែលអាចមាន៖ វានឹងមានជម្រើសសិក្សាច្រើនទៀតវានឹងអាចដាក់ពាក្យសម្រាប់ការបណ្តុះបណ្តាល ការងាររដ្ឋវានឹងអាចទទួលបានការសិក្សាជាន់ខ្ពស់ និងសិក្សានៅសាកលវិទ្យាល័យ អាចនឹងទទួលបានប្រាក់ខែខ្ពស់ និងមុខដំណែងល្អនាពេលអនាគត មានទំនោរទៅរកការសិក្សា និងវិជ្ជាជីវៈជាជាងបច្ចេកទេស។
៦. តើអ្នកអាចនឹកគិតអំពីគុណប្រយោជន៍នៃការសិក្សានៅវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសបានដែរឬទេ?
ចម្លើយដែលអាចមាន៖ ជំនាញបច្ចេកទេសនៅក្នុងប្រទេសកម្ពុជាយើងគឺមានតម្រូវការខ្ពស់ ប៉ុន្តែមិនមានមនុស្សច្រើនប៉ុន្មានទេដែលមានជំនាញទាំងនេះ ដូចនេះ វាអាចមានភាពងាយស្រួលក្នុងការទទួលបានការងារ ចូលចិត្តការងារអនុវត្ត វាអាចបន្តការសិក្សាទៅកាន់ការងារថ្នាក់បច្ចេកទេសជាន់ខ្ពស់ និងទទួលបានសញ្ញាបត្រស្មើនឹងកម្រិតសាកលវិទ្យាល័យ។
៧. តើជម្រើសសិក្សាបន្ទាប់ពីថ្នាក់ទី៩ និងទី១២ទាំងអស់គឺមាននៅក្នុងខេត្តរបស់អ្នកដែរឬទេ? ប្រសិនបើមិនមានតើជម្រើសមួយណាដែលមិនមាននៅទីនេះ?

## ស្វែងយល់ពីភាពខ្លាំងរបស់អ្នកនៅក្នុងសាលារៀន

🕑 ៣៥ នាទី

✋ ឱ្យសិស្សទាំងអស់ចម្លងតារាងពីក្នុងឯកសារទី៣ សម្រាប់សិស្ស៖ តារាងភាពខ្លាំងនៃមុខវិជ្ជា ទៅក្នុងសៀវភៅសរសេររបស់ពួកគេ។

សិស្សគួរធ្វើការរៀងៗខ្លួនដើម្បីបំពេញតារាង និងព្យាយាមចម្លងដោយភាពស្មោះត្រង់តាមតែអាចធ្វើបាន និងមិនចម្លងពីមិត្តភ័ក្តរបស់ពួកគេ។

វាមានសារសំខាន់ណាស់ដែលសិស្សត្រូវដឹងពីមូលហេតុដែលពួកគេត្រូវធ្វើកិច្ចការនេះ ដូច្នេះពួកគេអាចឆ្លុះបញ្ចាំងបានយ៉ាងច្បាស់ពីភាពខ្លាំងនិងភាពខ្សោយរបស់ពួកគេ ដើម្បីជួយពួកគេក្នុងការសម្រេចចិត្តជ្រើសរើសយក អាជីពក្នុងពេលអនាគតរបស់ពួកគេ និងមិនប្រៀបធៀបថាតើពួកគេល្អជាង ឬអាក្រក់ជាងមិត្តភ័ក្តរបស់ពួកគេទេ។ អ្នកគួរធ្វើឱ្យប្រាកដថាពួកគេទាំងអស់គ្នាមានមុខវិជ្ជាខ្លះពួកគេពូកែ និងមុខវិជ្ជាខ្លះពួកគេខ្សោយ - នេះមិនមែនមានន័យថា ពិន្ទុរបស់ពួកគេខ្ពស់ជាង ឬទាបជាងសិស្សដទៃទៀតក្នុងថ្នាក់ឡើយ ប៉ុន្តែវាគឺជា សមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេចំពោះមុខវិជ្ជាណាមួយដោយប្រៀបធៀបជាមួយសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេចំពោះមុខវិជ្ជាណាមួយទៀត។ កាលណាពួកគេកាន់តែមានភាពស្មោះត្រង់ វានឹងកាន់តែជួយពួកគេ។

សម្រាប់មុខវិជ្ជាគោលដៅនីមួយៗ ពួកគេគួរដាក់សញ្ញា “ - “ ប្រសិនបើវាជាមុខវិជ្ជាមួយដែលពួកគេមិនសូវពូកែ “ √ “ ប្រសិនបើពួកគេពូកែចំពោះមុខវិជ្ជានេះ ហើយដាក់សញ្ញា“ + “ ប្រសិនបើពួកគេពូកែខ្លាំងចំពោះមុខវិជ្ជានេះ។

បន្ទាប់មក ពួកគេគួរព្យាយាមបន្ថែមមតិយោបល់អំពីអ្វី ដែលពួកគេធ្វើបានជោគជ័យ ចំពោះមុខវិជ្ជាពាក់ព័ន្ធនីមួយៗ ហើយនិងអ្វីដែលពួកគេគិតថាមានការលំបាក។

នៅពេលសិស្សបានបញ្ចប់ការបំពេញតារាងភាពខ្លាំងនិងភាពខ្សោយនៃមុខវិជ្ជារៀងៗខ្លួន ពួកគេអាចចាប់ផ្តើមពិភាក្សាវាជាមួយអ្នកដែលអង្គុយជិតពួកគេ។ ពួកគេគួរពិភាក្សាពីអ្វីពួកគេគិតថាជាមុខវិជ្ជាដែលពួកគេពូកែ និងអ្វីដែលពួកគេអាចធ្វើដើម្បីដោះស្រាយភាពលំបាកទាំងនោះ នៅពេលពួកគេបានជួបប្រទះក្នុងមុខវិជ្ជាដទៃទៀតដែលពួកគេសិក្សា។

ប្រាប់សិស្សថា ពួកគេនឹងត្រូវការព័ត៌មានដែលបំពេញក្នុងតារាងរបស់ពួកគេសម្រាប់ជាកិច្ចការផ្ទះ ពួកគេនឹងបំពេញ **ក្នុងមេរៀនបន្ទាប់ពីមេរៀននេះ** (សម្រាប់កិច្ចការផ្ទះបន្ទាប់ពីមេរៀនទី៦)។







ចម្លងតារាងខាងក្រោមដាក់ក្នុងសៀវភៅរបស់អ្នក និងបំពេញចម្លើយរបស់អ្នកដោយស្មោះត្រង់។ ចំណុចសំខាន់ៗនេះ នឹងជួយអ្នកក្នុងការកំណត់អ្វីខ្លះជាភាពខ្លាំងរបស់អ្នក ដើម្បីគិតអំពីអាជីពនាពេលអនាគត។

| មុខវិជ្ជា ពាក់ព័ន្ធ | មុខវិជ្ជា គោលដៅ | លទ្ធភាព - = ខ្សោយ, √ = ល្មម, + = ខ្លាំង | ជោគជ័យ | ភាពខ្សោយ |
|---|---|---|---|---|
| ខ្មែរ | 1. ការនិយាយ<br>2. ការស្តាប់<br>3. ការអាន<br>4. ការសរសេរ | | | |
| ភាសាបរទេស | 1. ការនិយាយ<br>2. ការស្តាប់<br>3. ការអាន<br>4. ការសរសេរ | | | |
| គណិតវិទ្យា | 1. លេខ<br>2. រង្វាស់<br>3. ធរណីមាត្រ<br>4. ស្ថិតិ<br>5. ពិជគណិត | | | |
| សិក្សាសង្គម | 1. សីលធម៌ ពលរដ្ឋ<br>2. ភូមិវិទ្យា<br>3. ប្រវត្តិ<br>4. គេហវិជ្ជា | | | |
| វិទ្យាសាស្ត្រ | 1. រូបវិទ្យា<br>2. គីមី<br>3. ជីវវិទ្យា<br>4. ផែនដី និងបរិស្ថាន | | | |
| អប់រំកាយ, សុខភាព និងកីឡា | 1. អប់រំកាយ<br>2. ការថែរក្សាសុខភាព<br>3. កីឡា | | | |
| បំណិនជីវិត | 1.<br>2.<br>3. | | | |

នៅពេលអ្នកបំពេញរួច ពិភាក្សាជាមួយសិស្សដែលអង្គុយជិតអ្នកអំពីភាពខ្លាំង និងអ្វីដែលអ្នកអាចធ្វើដើម្បីជម្នះលើភាពលំបាកដែលអ្នកបានជួបប្រទះក្នុងការសិក្សារបស់អ្នក។

# មេរៀនទី ៦: ការភ្ជាប់ការងារទៅនឹងជម្រើសសិក្សា

រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ មុនពេលបង្រៀន លោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

សម្ភារឧបទេស ធនធានដែលត្រូវការ

- ផ្ទាំងក្រដាសធំ ហ្វឺត និងស្កុត
- សម្ភារៈដែលសិស្សបានធ្វើអំពីតារាងការងារក្នុងប្រទេសកម្ពុជា តារាងការងារក្នុងមូលដ្ឋាន
- ករណីសិក្សាដែលបានធ្វើ

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- ភ្ជាប់កម្មវិធីសិក្សារបស់សាលារៀន និងមុខវិជ្ជាបំណិនជីវិត និងចំណូលចិត្ត ទៅនឹងការងារដែលអាចមាន

## សេចក្ដីផ្ដើមៈ សកម្មភាពសម្ដែងតួ ១៥ នាទី

ឱ្យនរណាម្នាក់ធ្វើសកម្មភាពតំណាងជាអាជីពមួយ។ នៅពេលអ្នកណាដឹងពីប្រភេទអាជីពនោះ ពួកគេមិនត្រូវនិយាយទេប៉ុន្តែត្រូវចូលរួមជាមួយអ្នកនោះ ធ្វើសកម្មភាពមួយទៀតដែលទាក់ទងនឹងអាជីពនោះ។ (ឧ.ជាងឈើទទួលជំនួយពីនរណាម្នាក់ដែលយកឈើឱ្យគាត់កាន់ញញួរ ឬអ្វីក៏ដោយដែលពួកគេអាចនឹងឃើញ)។ បន្តធ្វើរហូតដល់អ្នកទាំងអស់គ្នា ឬក៏សិស្សភាគច្រើនបានចូលរួម។

## សកម្មភាពសំខាន់ៈ ការភ្ជាប់ការងារទៅនឹងមុខវិជ្ជាដែលសិក្សា ៧០ នាទី

វាមានភាពសំខាន់ណាស់ដែលសិស្សទាំងអស់មានឱកាសគិតអំពីអាជីពនាពេលអនាគតរបស់ពួកគេ។ ពួកគេគួរគិតអំពីកម្រិតថ្នាក់ដែលពួកគេចង់រៀន និងការងារប្រភេទណាដែលត្រូវនឹងមុខវិជ្ជាដែលពួកគេចូលចិត្ត ឬពូកែ និងជំនាញដែលពួកគេមានមកពីខាងក្រៅសាលា។

តើសកម្មភាពអ្វីខ្លះដែលយើងបានបញ្ចប់ហើយអាចជួយអ្នកឱ្យគិតអំពីការងារអ្វីដែលអ្នកមានបំណងចង់ធ្វើ?

ចម្លើយដែលអាចមានៈ តារាងការងារមានក្នុងមូលដ្ឋាន ក្នុងខេត្ត និងក្នុងប្រទេសកម្ពុជា ផែនទីការងារមានក្នុងតំបន់ករណីសិក្សា។

ចូរធ្វើឱ្យប្រាកដថា សិស្សទាំងអស់ដឹងច្បាស់ថាធនធានទាំងនោះនៅទីណា និងដឹងពីអាជីពផ្សេងៗដែលទាក់ទងនឹងធនធានក្នុងបណ្ណាល័យ។ ពិនិត្យមើលករណីសិក្សាទាំងអស់ដែលបានធ្វើ ហើយទុកដាក់ឯកសារនេះនៅកន្លែងណាមួយដែលសិស្សទាំងឡាយអាចរកបាន។

ទុកពេល ២ ឬ៣នាទីដើម្បីសម្រេចថាតើនរណានឹងធ្វើបទបង្ហាញខ្លីៗពីលទ្ធផលនៃកិច្ចការផ្ទះរបស់ពួកគេទាក់ទងនឹងការងារដែលពួកគេត្រូវបានស្នើឱ្យធ្វើការស្រាវជ្រាវ។ ពួកគេគួរនិយាយថាតើការងារមួយណាដែលពួកគេទទួល

បាន តើការសិក្សាអ្វីដែលពួកគេនឹងត្រូវធ្វើដើម្បីឱ្យមានសមត្ថភាពគ្រប់គ្រាន់ និងរបៀបដែលពួកគេស្រាវជ្រាវរកព័ត៌មាននេះ។ ប្រសិនបើពួកគេមិនអាចស្វែងរកចម្លើយបានទេ ពួកគេគួររៀបរាប់ពីអ្វីដែលពួកគេបានព្យាយាម ហើយសិស្សដទៃអាចជួយផ្តល់មធ្យោបាយផ្សេងៗដែលពួកគេអាចស្រាវជ្រាវរកព័ត៌មាន។
ក្រុមនីមួយៗគួរចំណាយពេល ៣ ឬ៤នាទីដើម្បីបង្ហាញលទ្ធផលរបស់ពួកគេ។

ឱ្យសិស្សធ្វើការក្នុងក្រុមរបស់ពួកគេ។ ប្រាប់ក្រុមនីមួយៗឱ្យជ្រើសរើសការងារ៤ប្រភេទខុសៗគ្នា ដោយប្រើប្រាស់ការងារដែលពួកគេបានសរសេរអំពីអាជីពក្នុងសហគមន៍មូលដ្ឋាន អាជីពក្នុងខេត្ត និងអាជីពក្នុងប្រទេសកម្ពុជា។ ចូរប្រាកដថាក្រុមជ្រើសរើសយកយ៉ាងតិចណាស់ការងារមួយពីក្នុងតារាងមួយ ដូចនេះនឹងមានការងារខុសៗគ្នាក្នុងក្រុមនីមួយៗ។

ឱ្យពួកគេបំពេញព័ត៌មានក្នុងតារាងលើផ្ទាំងក្រដាសធំដូចខាងក្រោម - ប្រាប់ពួកគេថា ពួកគេមានពេលត្រឹមតែ ១៥ នាទី ដូច្នេះពួកគេត្រូវធ្វើការឱ្យបានរហ័ស តាមតែអាចធ្វើបាន។

សរសេរទម្រង់តារាងនៅលើក្តារខៀនៈ

| ការងារ | ទាក់ទងនឹង មុខវិជ្ជាក្នុងសាលា | ទាក់ទងជំនាញនិងទេពកោសល្យ(ឧ.ពីក្លឹប បំណិនជីវិត, ការជួយ គ្រួសារ...) | កម្រិតសិក្សាដែលត្រូវការ (ថ្នាក់ទី៦, ៩, ១២ ឬជំនាញវិជ្ជាជីវៈ និងសាកលវិទ្យាល័យ) |
|---|---|---|---|
| * | *<br>* | *<br>* | *<br>* |
| * | *<br>* | *<br>* | *<br>* |
| * | *<br>* | *<br>* | *<br>* |
| * | *<br>* | *<br>* | *<br>* |

១៥នាទីក្រោយមក ឱ្យតំណាងក្រុមនីមួយៗយកផ្ទាំងក្រដាសធំរបស់ពួកគេ ប្រគល់ឱ្យទៅក្រុមដែលនៅខាងឆ្វេងដៃ។ បន្ទាប់មកទុកពេលឱ្យក្រុម ១០នាទីទៀតដើម្បីបន្ថែម ឬស្នើធ្វើការផ្លាស់ប្តូរនៅលើផ្ទាំងក្រដាសធំ។

១០នាទីបន្ទាប់មក ឱ្យតំណាងក្រុមនីមួយៗយកផ្ទាំងក្រដាសធំរបស់ពួកគេ ប្រគល់ឱ្យទៅក្រុមដែលនៅខាងឆ្វេងដៃម្តងទៀត។ បន្ទាប់មក ទុកពេលឱ្យក្រុម ១០នាទីទៀតដើម្បីបន្ថែម ឬស្នើធ្វើការផ្លាស់ប្តូរនៅលើផ្ទាំងក្រដាសធំ។

បន្ទាប់ពីនេះ ប្រាប់ក្រុមទាំងអស់ឱ្យបិទផ្ទាំងក្រដាសធំរបស់ពួកគេនៅលើជញ្ជាំង ហើយទុកពេលឱ្យពួកគេដើរមើលតារាងទាំងនោះនៅក្នុងថ្នាក់រៀន។

នៅពេលអ្នកទាំងអស់គ្នាអង្គុយចុះ ទុកពេល២ ឬ៣នាទីសម្រាប់ការសួរសំណួរដែលពួកគេចង់សួរចំពោះផ្ទាំងក្រដាសធំរបស់ក្រុមដទៃ។ ប្រសិនបើមានចន្លោះនៅលើតារាងដែលមិនមាននរណាម្នាក់អាចឆ្លើយបាន ឬសិស្សមិនច្បាស់ - សួរពីរបៀបដែលពួកគេអាចនឹងស្វែងរកចម្លើយបាន (ឧ. ទៅសួរ សរសេរ ឬទូរស័ព្ទទៅនរណាម្នាក់ដែលធ្វើការងារនោះ សួរនៅមហាវិទ្យាល័យ មណ្ឌលវិជ្ជាជីវៈ ឬក្រសួងការងារ... ប្រព័ន្ធផ្សព្វផ្សាយ ...)។ ផ្ទាំងក្រដាសធំគប្បីត្រូវបានរក្សាទុកនៅក្នុងស៊ីមីររបស់ក្រុមនីមួយៗ។

## កិច្ចការផ្ទះៈ ការភ្ជាប់ការងារទៅនឹងមុខវិជ្ជាដែលសិក្សា ១៥ នាទី

សិស្សគួរមើលក្នុងតារាងដែលពួកគេបានបំពេញក្នុងមេរៀនទី៥អំពីភាពខ្លាំង និងភាពខ្សោយរបស់ពួកគេ។ ពួកគេគួរសរសេរក្នុងសៀវភៅរបស់ពួកគេអំពីមុខវិជ្ជាដែលពួកគេរៀនពូកែ និងមុខវិជ្ជាដែលពួកគេចូលចិត្ត ហើយនឹកគិតរកការងារ ៣ ឬ ៤ដែលទាក់ទងនឹងមុខវិជ្ជាទាំងនោះ ព្រមទាំងសរសេរវាទុក។ ប្រាប់ពួកគេថា ពួកគេនឹងត្រូវ ការព័ត៌មាននេះនៅមេរៀនបន្ទាប់។

# មេរៀនទី ៧: ការរៀបចំផែនការទស្សនកិច្ចសិក្សា

រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ មុនពេលបង្រៀន លោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

សម្ភារឧបទេស ធនធានដែលត្រូវការ

- ទម្រង់ករណីសិក្សា
- ក្រដាសរ៉ាម, ហ្វឺត និងស្កុត

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- ធ្វើផែនការទស្សនានៅក្នុងតំបន់មូលដ្ឋានរបស់ពួកគេ

## សេចក្ដីផ្ដើមៈ រំឭកកិច្ចការផ្ទះ — ១៥ នាទី

សិស្សគួរមើលកិច្ចការផ្ទះរបស់ពួកគេ និងពិភាក្សាវាក្នុងក្រុមរដោយពួកគេម្នាក់ៗគិតថា ជាមុខវិជ្ជាដែលពួកគេរៀនពូកែ និងជាមុខវិជ្ជាដែលចូលចិត្ត។ ពិភាក្សាជាមួយមិត្តភ័ក្ដថា តើការងារដែលពួកគេបានសរសេរ ទាក់ទងនឹងមុខវិជ្ជាទាំងនោះ ត្រូវគ្នាដែរឬទេ។

១០ នាទីក្រោយមក ឱ្យសិស្ស ២ ឬ ៣នាក់ចែករំលែកគំនិតរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ទាំងមូល។

## សកម្មភាពសំខាន់ — ៧៥ នាទី

ពន្យល់ទៅកាន់សិស្សថា នៅមេរៀនក្រោយ ពួកគេនឹងមានឱកាសទៅទស្សនាកន្លែងធ្វើការមួយ ឬមណ្ឌលសិក្សាវិជ្ជាជីវៈមួយ ឬមណ្ឌលសិក្សាដទៃទៀត ឬនឹងអញ្ជើញនរណាម្នាក់មកកាន់ថ្នាក់រៀនរបស់ពួកគេដើម្បីសម្ភាស ឬស្ដាប់ពីកន្លែងការងារទាំងនេះ។

ឱ្យសិស្សពិភាក្សាក្រុមរបស់ពួកគេដើម្បីរកនឹកកន្លែងការងារមួយ និង(ប្រសិនបើវាមិនឆ្ងាយពេក) កន្លែងសិក្សាមួយដែលពួកគេគិតថាវានឹងល្អ ក្នុងការទស្សនា/អញ្ជើញពួកគេឱ្យមកនិយាយក្នុងសាលារៀនជាមួយពួកគេក្នុងថ្នាក់។ លើកទឹកចិត្តពួកគេឱ្យគិតពីកន្លែងការងារធំៗដែលនៅមិនឆ្ងាយពេក ដូចជាធនាគារ មន្ត្រីរដ្ឋាភិបាល ឬសេវាកម្ម (ឧ. មន្ទីរពេទ្យ/មណ្ឌលសុខភាព) រោងចក្រ ក្រុមហ៊ុន...ដែលមានមនុស្សធ្វើការច្រើននៅទីនោះ ជាងកន្លែងធ្វើការតូចដែលមាននយោជិកតែមួយ ឬពីរនាក់ ដូច្នេះពួកគេអាចស្វែងរកពីភាពខុសគ្នានៃការងារដែលមាន។ ទុកពេលប្រហែល ១០ ឬ ១៥នាទីដើម្បីសម្រេច។

សួរក្រុមនីមួយៗថាតើកន្លែងសិក្សាណាមួយដែលពួកគេបានជ្រើសរើស និងកន្លែងការងារណាមួយដែលពួកគេបានជ្រើស រើស ហើយសរសេរវានៅលើក្ដារខៀន។ សម្រេចចិត្តនៅក្នុងថ្នាក់ថា តើកន្លែងណាដែលគួរទៅទស្សនា - ព្យាយាមបញ្ចូលគ្នាឱ្យបានល្អនៃការងារការិយាល័យ និងការងារអនុវត្ត ហើយនិងមណ្ឌលសិក្សាមួយយ៉ាងតិច ឬវិទ្យាល័យ (ប្រសិនបើវាមិនស្ថិតនៅឆ្ងាយពេក)។

ចូរកត់សម្គាល់ថា ប្រសិនបើអ្នកនឹងទៅធ្វើទស្សនកិច្ចខាងក្រៅ គួរមានសមាជិកក្រុមមិនឱ្យលើសពី៦-៨ នាក់ក្នុងមួយក្រុម ប្រសិនបើអ្នកមិនទៅទស្សនាមណ្ឌលវិជ្ជាជីវៈ ឬកន្លែងសិក្សា ឬក្រុមហ៊ុនធំ និងមណ្ឌល/ក្រុមហ៊ុនដែលអាចទទួលបានក្រុមធំ។ ប្រសិនបើអ្នកអញ្ជើញវាគ្មិនមកកាន់សាលារៀន វាគ្មិន២ ឬ៣នាក់ប្រហែលជាគ្រប់គ្រាន់។ ព្យាយាមលើកទឹកចិត្តឱ្យមានទាំងវាគ្មិនប្រុស និងស្ត្រី ដូច្នេះនឹងមានគំរូវិជ្ជមានសម្រាប់សិស្សទាំងអស់។

✋ បែងចែកសិស្សយោងទៅតាមកន្លែងដែលនឹងទៅទស្សនា/ចំនួនវាគ្មិនដែលអ្នកនឹងអញ្ជើញមកកាន់សាលារៀន។ ក្រុមនីមួយគួរធ្វើផែនការឱ្យបានច្បាស់លាស់ពីអ្វីដែលពួកគេចង់ស្វែងរក និងធ្វើឱ្យប្រាកដថា ពួកគេមានសំណួរគ្រប់គ្រាន់សម្រាប់ជួយពួកគេឱ្យស្វែងរកចំណុចសំខាន់ៗដែលពួកគេចង់ដឹង។ ពួកគេអាចពិគ្រោះជាមួយឯកសារទី១ សម្រាប់សិស្ស ៖ ទម្រង់ករណីសិក្សា ប៉ុន្តែគួរប្រាកដថាពួកគេបានសម្រួលសំណួរស្វែងរកតួនាទីខុសៗគ្នានៅក្នុងកន្លែងធ្វើការ និងសមត្ថភាពផ្សេងៗដែលចាំបាច់សម្រាប់ប្រភេទការងារនីមួយៗ។

សម្រាប់មណ្ឌលសិក្សា ពួកគេគួរស្វែងរកចំណុចសំខាន់ៗដែលពួកគេត្រូវសិក្សា និងលក្ខខណ្ឌផ្សេងៗនៃការប្រឡងចូល...។

២៥នាទីក្រោយមក ពួកគេគួរប្រៀបធៀបចម្លើយរបស់ពួកគេជាមួយក្រុមដទៃ ហើយបន្ថែមអ្វីដែលខ្វះខាត។

✋ ជាចុងក្រោយ ផែនការមួយត្រូវបានធ្វើ សម្រាប់ត្រៀមរៀបចំទៅទស្សនា ឬការរៀបចំសម្រាប់វាគ្មិនមកកាន់សាលារៀន។ ស្វែងរកនរណាម្នាក់ ដែលមានលេខទំនាក់ទំនងជាមួយកន្លែងគោលដៅ ហើយប្រសិនបើមានយើងងាយស្រួលក្នុងការចាត់ចែង។ វាជាកាសក្តិសមបំផុតគឺគ្រូ ក្នុងការណាត់ជួបសម្រាប់ទស្សនកិច្ច(ប្រហែលជាត្រូវមានជំនួយពីនាយកសាលា) ដើម្បីធ្វើឱ្យប្រាកដថា វាត្រូវបានរៀបចំសមរម្យ ដូច្នេះហើយសាលារៀនគឺច្បាស់លាស់ថាសិស្ស នឹងត្រូវទៅជួបអ្នកណា ហើយនរណាដែលត្រូវទាក់ទង នៅពេលជួបបញ្ហាលំបាក។

ចូរឱ្យប្រាកដថា សិស្សទាំងអស់មានលេខទូរស័ព្ទរបស់គ្រូ ដើម្បីធ្វើការទំនាក់ទំនង ក្នុងករណីមានបញ្ហាពិបាក និងដើម្បីសុវត្ថិភាព។ ប្រសើរបំផុត ប្រសិនបើគ្រូ នាយកសាលា ឬមនុស្សពេញវ័យ ដែលទទួលខុសត្រូវផ្សេងទៀត ដូចជាឪពុក ម្តាយទៅជាមួយសិស្សក្នុងការទស្សនា ដូច្នេះចូរប្រាកដថា តើនរណាអាចទៅចូលរួមជាមួយពួកគេបាន។ ប្រសិនបើចាំបាច់ អ្នកអាចធ្វើការតាមដានព័ត៌មាននេះជាមួយអ្នកដឹកនាំក្រុមនីមួយៗ។

**កិច្ចការផ្ទះ** ⏲ **១០ នាទី**

សិស្សគួរបញ្ចប់សំណួរដែលពួកគេនឹងត្រូវប្រើសម្រាប់ទស្សនកិច្ចសិក្សា។ពួកគេនឹងត្រូវការធ្វើកំណត់ត្រា/ចំណុចសម្គាល់ ខណៈពេលដែលគេកំពុងនិយាយ ហើយបន្ទាប់មក ពួកគេគួរសរសេរវាឱ្យបានពេញលេញសម្រាប់មេរៀនបន្ទាប់ពីបានទស្សនកិច្ច។



# មេរៀនទី ៨: ទស្សនកិច្ចសិក្សា

🕒 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ មុនពេលបង្រៀន លោកគ្រូ អ្នកគ្រូត្រូវ
- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ
- ទម្រង់សំណួរ
- ក្រដាសរ៉ាម សៀវភៅ ប៊ិច

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- សម្ភាសនយោជក និង/ឬមណ្ឌលសិក្សាអំពីឱកាសដែលមាន

**ទស្សនកិច្ចសិក្សា** 🕒 **១០០ នាទី**

នេះនឹងធ្វើឡើងនៅខាងក្រៅសាលារៀន (ឬប្រសិនបើចាំបាច់ដោយយោងតាមការលំបាកក្នុងការធ្វើដំណើរ) វាគ្មិននឹងមកសាលារៀន)។ សកម្មភាពនឹងកើតឡើងតាមអ្វីដែលយល់ព្រមពីមេរៀនមុន និងបញ្ជាក់ដោយគ្រូ។

# មេរៀនទី ៩: ការរាយការណ៍អំពីព័ត៌មានដែលទទួលបាន

រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ មុនពេលបង្រៀន លោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

សម្ភារឧបទេស ធនធានដែលត្រូវការ

- ទម្រង់របាយការណ៍
- ក្រដាសវ៉ាម, ហ្វឺត និងស្កុត

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- ធ្វើបទបង្ហាញព័ត៌មានដែលស្រាវជ្រាវរកបានទៅកាន់ដៃគូរបស់ពួកគេ

## សកម្មភាពសំខាន់ៈ ការធ្វើរបាយការណ៍ទៅកាន់មិត្តរួមថ្នាក់ ១០០ នាទី

សិស្សគួរធ្វើការក្នុងក្រុមរបស់ពួកគេប្រមាណជា ១៥ឬ២០នាទី ដើម្បីធ្វើឱ្យប្រាកដថា ពួកគេមានព័ត៌មានលម្អិតត្រឹមត្រូវអំពីទស្សនកិច្ចសិក្សារបស់ពួកគេ បន្ទាប់មក ជ្រើសរើសសិស្សពីរនាក់ដើម្បីថតចម្លងកិច្ចការរបស់ពួកគេចំនួនពីរច្បាប់ មួយច្បាប់ទុកក្នុងបណ្ណាល័យ និងមួយច្បាប់ទៀតទុកក្នុងស៊ីមីរបស់ពួកគេ។

បន្ទាប់មកពួកគេគួរធ្វើផែនការ ពីរបៀបធ្វើបទបង្ហាញព័ត៌មានទៅកាន់សិស្សដទៃទៀតក្នុងថ្នាក់ ដោយការសម្ដែងការសម្ភាស/ទស្សនកិច្ចសិក្សា ឬរកវិធីគួរឱ្យចាប់អារម្មណ៍ផ្សេងទៀតដើម្បីផ្សព្វផ្សាយព័ត៌មានដែល ពួកគេទទួលបានពីទស្សនកិច្ចសិក្សា ដូចនេះសិស្សដទៃទៀតអាចរៀនសូត្រពីអ្វីដែលពួកគេរកបាន។ បន្ទាប់មក ក្រុមនីមួយៗគួរធ្វើបទបង្ហាញពីលទ្ធផលនៃទស្សនកិច្ចសិក្សារបស់ពួកគេទៅកាន់សិស្សដទៃទៀត។ សិស្សដទៃអាចកត់ត្រានូវអ្វីដែលពួកគេបានឮ។

# មេរៀនទី ១០: កម្រងសំណួរការងារ និងកំណត់ត្រានៃផែនការអនាគត

🕑 រយៈពេលបង្រៀន: ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ មុនពេលបង្រៀន លោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- កម្រងសំណួរអាជីពអនាគត
- តារាងកំណត់ត្រាការងារគោលដៅ

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- វាយតម្លៃថាតើពួកគេយល់ច្បាស់ពីជម្រើសរបស់ពួកគេបន្ទាប់ពីបញ្ចប់ថ្នាក់ទី៩
- កត់ត្រាអាជីពគោលដៅរបស់ពួកគេសម្រាប់អនាគត

## សេចក្តីផ្តើម: រំឭកមេរៀនមុន 🕑 ១០ នាទី

✋ ពិនិត្យខ្លឹមសារសម្ភាស ដែលពួកគេបានធ្វើនាពេលកន្លងមក។ ពិនិត្យមើលថា តើពួកគេបានរៀនពីករណីសិក្សាដែលសិស្សដទៃទៀតបានស្រាវជ្រាវ និងរបៀបដែលពួកគេបានធ្វើ។ ជួយដោះស្រាយបញ្ហាផ្សេងៗដែលអាចមានក្នុងកំឡុងពេលធ្វើកិច្ចការនេះ។

## សកម្មភាពសំខាន់: កម្រងសំណួរ 🕑 ៩០ នាទី

✋ ពន្យល់ថា អ្នកចង់ឱ្យពួកគេបំពេញកម្រងសំណួរខ្លីមួយដើម្បីស្វែងរកការងារ តើត្រូវការជំនួយបន្ថែមទៀតដែរឬទេ? ក្នុងការស្រាវជ្រាវដែលពួកគេនឹងធ្វើបន្ទាប់ពីបញ្ចប់ថ្នាក់ពី៩។ ចែកឯកសារសិស្ស៖ កម្រងសំណួរអាជីពអនាគត។ ប្រាប់សិស្សថានេះមិនមែនជាតេស្តទេដូច្នេះពួកគេគួរឆ្លើយសំណួរដោយភាពស្មោះត្រង់ព្រោះចម្លើយទៅនឹងសំណួរនេះបង្ហាញឱ្យឃើញថា តើនរណាដែលត្រូវការជំនួយបន្ថែមទៀតក្នុងការសម្រេចចិត្តពីអ្វីដែលនឹងត្រូវធ្វើបន្ទាប់ពីថ្នាក់ពី៩។ ឱ្យសិស្សកត់ត្រាតារាងពីក្នុងឯកសារចែកសិស្ស ទៅក្នុងក្រដាសមួយសន្លឹក ហើយឆ្លើយសំណួរទាំងនោះ។ ប្រាប់ពួកគេកុំគិតអំពីពិន្ទុក្នុងពេលនេះ អ្នកនឹងពន្យល់នៅពេលក្រោយ។

✋ នៅពេលសិស្សបានបញ្ចប់ បិទផ្ទាំងរូបភាពដែលបានបំពេញក្នុងកម្រងសំណួរអាជីព និងពន្យល់ពីរបៀបក្នុងការដាក់ពិន្ទុចំពោះចម្លើយទាំងនោះ (មើលឧទាហរណ៍នៃការដាក់ពិន្ទុក្នុងទំព័រទី៣១)។

ប្រាប់សិស្សឱ្យធ្វើការរៀងៗខ្លួនដើម្បីសរុបពិន្ទុនៃចម្លើយទាំងនោះនៅលើផ្ទាំងរូបភាព។ ពិនិត្យមើលចម្លើយដែលពួកគេបានបំពេញ។ ប្រសិនបើសិស្សភាគច្រើនសរុបពិន្ទុខុស ឱ្យសិស្សម្នាក់ឡើងពន្យល់ពីរបៀបក្នុងការបូកសរុបពិន្ទុឱ្យបានត្រឹមត្រូវ។ បន្ទាប់មក នៅពេលពួកគេយល់ ឱ្យពួកគេដាក់ពិន្ទុក្នុងទម្រង់របស់ពួកគេផ្ទាល់។

នៅពេលពួកគេបានបញ្ចប់ការដាក់ពិន្ទុក្នុងទម្រង់របស់ពួកគេ ពួកគេគួរពិនិត្យមើលពិន្ទុរបស់អ្នកដែលអង្គុយនៅជិតខាងពួកគេ និងធ្វើឱ្យប្រាកដថា ពួកគេបានសរសេរឈ្មោះរបស់ពួកគេច្បាស់លាស់ក្នុងក្រដាសចម្លើយនោះ។

ឱ្យប្រធានថ្នាក់ប្រមូលកម្រងសំណួរទាំងអស់នោះមកវិញ ហើយរៀបពីអ្នកដែលបានពិន្ទុទាប ទៅពិន្ទុខ្ពស់បន្ទាប់មកធ្វើជាបញ្ជីប្រចាំថ្នាក់មួយ ដោយមានដាក់ឈ្មោះសិស្ស និងពិន្ទុរបស់ពួកគេ(ពិន្ទុទាបជាងគេមុខ ហើយពិន្ទុខ្ពស់ជាងគេនៅចុងក្រោយគេ)។

អ្នកដែលបានពិន្ទុ ១៣ ឬច្រើនជាងនេះមិនត្រូវការមានការសម្ភាសម្នាក់ទល់ម្នាក់ទេ - ពួកគេអាចបំពេញក្នុងបញ្ជីអត្តសញ្ញាណអាជីពរបស់សិស្ស ដែលអ្នកនឹងណែនាំក្នុងពេល ពីរ ឬបីនាទីទៀត។

អ្នកដែលទទួលបានពិន្ទុ៨ ឬតិចជាងនេះគួរចូលរួមក្នុងសកម្មភាពបន្ថែមជាមួយក្រុមប្រឹក្សាកុមារ ហើយប្រសិនបើចាំបាច់ ត្រូវធ្វើការសម្ភាសម្នាក់ទល់ម្នាក់ជាមួយអ្នកប្រឹក្សាអាជីព/អ្នកប្រឹក្សាសាលា ឬអ្នកផ្តល់ការគាំទ្រផ្សេងទៀតដែលមានក្នុងសាលារៀន។ បន្ទាប់ពីពួកគេបានទទួលជំនួយបន្ថែម ពួកគេអាចបំពេញតារាងដែលពួកគេមិនទាន់អាចបំពេញបានក្នុងបញ្ជីអត្តសញ្ញាណអាជីព។

សិស្សដទៃទៀត (អ្នកដែលបានពិន្ទុ ៩-១២) នឹងត្រូវបានផ្តល់អាទិភាពទៅតាមតម្រូវការ។ ពួកគេអាចចាប់ផ្តើមបំពេញក្នុងបញ្ជីអត្តសញ្ញាណអាជីព ប៉ុន្តែប្រហែលជាត្រូវការធ្វើការស្រាវជ្រាវបន្ថែមទៀតដោយមានជំនួយពីក្រុមប្រឹក្សាដើម្បីបំពេញវា។

សរសេរតារាងខាងក្រោមនៅលើក្តារខៀន និងឱ្យសិស្សសរសេរវាក្នុងសៀវភៅសរសេររបស់ពួកគេ។ បន្ទាប់មកសិស្សគួរចាប់ផ្តើមបំពេញព័ត៌មានឱ្យបានច្រើនតាមតែពួកគេអាចធ្វើបាន នៅខាងក្រោមចំណងជើងអំពីខ្លួនរបស់ពួកគេ។ អ្នកដែលទទួលបានពិន្ទុក្រោម ១៣ នៅលើកម្រងសំណួរ អាចចាប់ផ្តើមបំពេញតារាង ប៉ុន្តែប្រហែលជាមិនអាចបំពេញគ្រប់ផ្នែកទាំងអស់នៃតារាងបាននៅឡើយទេ។

| មុខវិជ្ជាដែលចូលចិត្ត (រៀបរាប់ឱ្យបាន៤) | មុខវិជ្ជាដែលរៀនពូកែ (រៀបរាប់ឱ្យបាន ១ ឬ ២) | ជំនាញដទៃទៀត (ឧ.មកពីក្លឹប ការជួយគ្រួសារ) | ការងារដែលអាចទាក់ទង | រៀបរាប់ការងារគោលដៅ ១ ឬ២ | កម្រិតសិក្សាដែលរំពឹងទុក? (ទី៩ ទី១២ ជំនាញ វិជ្ជាជីវៈ សាកលវិទ្យាល័យ) |
|---|---|---|---|---|---|
| *<br>*<br>*<br>* | *<br>* | *<br>*<br>*<br>* | *<br>*<br>*<br>* | | |

ឱ្យប្រធានថ្នាក់ចាប់ផ្តើម ឱ្យសិស្សទាំងអស់បំពេញក្នុងតារាងកំណត់ត្រាការងារគោលដៅ ដូចក្នុងឧទាហរណ៍ខាងក្រោម ដូច្នេះអ្នកនឹងអាចមាន កំណត់ត្រាការងារគោលដៅរបស់សិស្សទាំងអស់។ ប្រសិនបើមិនមានពេលគ្រប់គ្រាន់សម្រាប់ឱ្យសិស្សបំពេញតារាង ប្រធានថ្នាក់អាចធ្វើការតាមដាន និងធ្វើឱ្យប្រាកដថា កិច្ចការនេះត្រូវបានបញ្ចប់បន្ទាប់ពីម៉ោងរៀន ហើយនឹងប្រគល់ទៅឱ្យអ្នកនៅថ្ងៃបន្ទាប់។

ពន្យល់ថា នេះគឺជាមេរៀនចុងក្រោយ ប៉ុន្តែការគាំទ្របន្ថែមទៀតនឹងមានពីក្រុមប្រឹក្សាកុមារ និង/ឬ អ្នកប្រឹក្សាអាជីព ឬអ្នកគាំទ្រផ្សេងទៀតក្នុងសាលា (ឧ. អ្នកប្រឹក្សាសាលា ទីប្រឹក្សាកុមារី LSMC ឬក្រុមគាំទ្រដទៃទៀតដែលអ្នកមានក្នុងសាលារៀន)។ សិស្សដែលទទួលបានពិន្ទុតិចជាង ៧ ប្រាប់ពួកគេអំពីពេលវេលានៃការប្រជុំលើកទីមួយជាមួយក្រុមប្រឹក្សាកុមារ។

ក្នុងកំឡុងពេល ១៥នាទីចុងក្រោយនៃមេរៀន សិស្សគួរបំពេញវង្វាយតម្លៃនៃមេរៀនបំណិនជីវិត ការជ្រើសរើសអនាគតរបស់អ្នក នៅទំព័របន្ទាប់។ ចម្លើយនៃសំណួរគឺមានផ្តល់ជូនសម្រាប់គ្រូដើម្បីដាក់ពិន្ទុវង្វាយតម្លៃរបស់សិស្សម្នាក់ៗ។

សួរសិស្សថាតើពួកគេមានសំណួរអ្វីដែរឬទេ ហើយរំឭកពួកគេថា អ្នកដែលមិនទាន់អាចបំពេញតារាងកំណត់ត្រាការងារគោលដៅបានច្រើនដូចអ្វីដែលពួកគេអាច ពួកគេគួរជួបជាមួយប្រធានថ្នាក់ដើម្បីធ្វើឱ្យប្រាកដថា កិច្ចការនេះត្រូវបានបញ្ចប់ឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាននៅមុនថ្ងៃបន្ទាប់។

អរគុណសិស្សទាំងអស់សម្រាប់ការចូលរួមរបស់ពួកគេ។



## កម្រងសំណួរអាជីពអនាគត

| ឈ្មោះ | | ថ្នាក់ | |
|---|---|---|---|

| ល.រ. | សំណួរ | ចម្លើយ | ពិន្ទុ |
|---|---|---|---|
| 1. | តើអ្នកនឹងបន្តការសិក្សារហូតដល់បញ្ចប់ថ្នាក់ទី ១២ បន្ទាប់ពីអ្នកបញ្ចប់ថ្នាក់ទី៩ឬ? | បាទ/ចាស ទេ មិនដឹង | 5 0 0 |
| 2. | តើឪពុកម្តាយរបស់អ្នកនឹងអនុញ្ញាតឱ្យអ្នករៀន រហូតដល់ថ្នាក់ទី១២ | បាទ/ចាស ទេ មិនដឹង | 2 0 0 |
| 3. | ក. តើអ្នកដឹងថាការងារមួយណាដែលអ្នកចាប់អារម្មណ៍ នៅពេលអ្នកបញ្ចប់ការសិក្សា? | បាទ/ចាស ទេ | 1 0 |
| | ខ. ប្រសិនបើដឹង តើការងារអ្វីខ្លះដែលអ្នកចង់ធ្វើ? | ________<br>________<br>________ | 5 0 |
| | គ. ប្រសិនបើដឹង តើគ្រួសាររបស់អ្នកយល់ស្រប ជាមួយគំនិតរបស់អ្នកទេ? | បាទ/ចាស ទេ មិនដឹង | 2 0 0 |
| 4. | តើអ្នកធ្លាប់និយាយជាមួយនរណាម្នាក់អំពីការងារ អនាគតរបស់អ្នកដែរឬទេ?<br>(ជ្រើសរើសជម្រើសទាំងអស់ដែលត្រូវនឹងអ្នក) | ឪពុកម្តាយ<br>បងប្អូន<br>ក្រុមប្រឹក្សាសិស្ស<br>នាយកសាលា<br>គ្រូ<br>មិត្តភ័ក្ត | 1<br>1<br>1<br>1<br>1<br>1 |
| 5. | តើអ្នកណា ឬសម្ភារៈអ្វីខ្លះដែលអ្នកប្រើដើម្បីស្វែងរកការងារ ឬស្រាវជ្រាវពីអាជីពទាំងនេះ? | ________<br>________<br>________<br>________ | 2 0 |
| | | សរុប | |

## វង្វាយតម្លៃបំណិនជីវិតការជ្រើសរើសអនាគតរបស់អ្នក

សិស្សគួរចំណាយពេល ១០ ទៅ ១៥នាទីដើម្បីបំពេញ វង្វាយតម្លៃមេរៀនបំណិនជីវិតការជ្រើសរើសអនាគតរបស់អ្នកខាងក្រោម៖

| ឈ្មោះសិស្ស______ ថ្នាក់______<br>ឈ្មោះគ្រូ______ កាលបរិច្ឆេទ______ | | |
|---|---|---|
| សំណួរ | ចម្លើយជ្រើសរើស | ចម្លើយ |
| **1.** តើអ្វីជាភាពខុសប្លែកគ្នារវាងការងារ និង អាជីព? | ក. មិនមានភាពខុសគ្នា។<br>ខ. ការងារគឺការធ្វើការក្នុងហាង ហើយអាជីពគឺធ្វើការក្នុងការិយាល័យ<br>គ. ជារឿយៗ ការងារគឺមិនមានគម្រោង រីឯអាជីពគឺជាអ្វីដែលអ្នកកសាង និងអភិវឌ្ឍជាច្រើនឆ្នាំ។ | |
| **2.** រៀបរាប់ការងារពីរដែលមិនមានក្នុងតំបន់របស់អ្នក ប៉ុន្តែមានក្នុងប្រទេសកម្ពុជា។ | 1. ______<br>2. ______ | |
| **3.** តើអ្នកគួររៀបចំសំណួរសម្រាប់សម្ភាសករណីសិក្សាដោយរបៀបណា? | ក. ប្រើទម្រង់សម្ភាសករណីសិក្សា<br>ខ. ត្រូវច្បាស់ពីអ្វីដែលអ្នកចង់ដឹង<br>គ. ត្រូវច្បាស់ពីអ្វីដែលអ្នកចង់ដឹង រៀបចំសំណួរដោយប្រើប្រាស់កម្រិតភាសាសមរម្យដើម្បីឱ្យអ្នកដែលត្រូវសម្ភាសយល់ | |
| **4.** តើអ្នកត្រូវសិក្សានៅវិក្រឹតការខេត្តប៉ុន្មានឆ្នាំដើម្បីក្លាយជាគ្រូម្នាក់? | ក. ពីរឆ្នាំ<br>ខ. បីឆ្នាំ<br>គ. បួនឆ្នាំ | |
| **5.** តើអ្នកត្រូវបញ្ចប់ថ្នាក់ទីប៉ុន្មានដើម្បីចូលរៀនសាកលវិទ្យាល័យកម្រិតបរិញ្ញាបត្រ? | ក. ថ្នាក់ទី៩<br>ខ. ថ្នាក់ទី១១<br>គ. ថ្នាក់ទី១២ | |
| | ពិន្ទុវង្វាយតម្លៃ | /10 |

| ចម្លើយ | | |
|---|---|---|
| សំណួរ | ចម្លើយត្រឹមត្រូវ | ពិន្ទុ |
| **1.** តើអ្វីជាភាពខុសប្លែកគ្នារវាងការងារ និង អាជីព? | គ. ជារឿយៗ ការងារគឺមិនមានគម្រោង រីឯអាជីពគឺជាអ្វីដែលអ្នកកសាង និងអភិវឌ្ឍជាច្រើនឆ្នាំ។ | 2 ពិន្ទុ |
| **2.** រៀបរាប់ការងារពីរដែលមិនមានក្នុងតំបន់របស់អ្នក ប៉ុន្តែមានក្នុងប្រទេសកម្ពុជា។ | 1. ______<br>2. ______<br>(ចម្លើយត្រឹមត្រូវគឺអាស្រ័យតាមទីកន្លែងដែលអ្នករស់នៅ) | 2 ពិន្ទុ (១ សម្រាប់ចម្លើយត្រឹមត្រូវនីមួយៗ) |
| **3.** តើអ្នកគួររៀបចំសំណួរសម្រាប់សម្ភាសករណីសិក្សាដោយរបៀបណា? | គ. ត្រូវច្បាស់ពីអ្វីដែលអ្នកចង់ដឹង រៀបចំសំណួរដោយប្រើប្រាស់កម្រិតភាសាសមរម្យសម្រាប់ដើម្បីឱ្យអ្នកដែលត្រូវសម្ភាសយល់ | 2 ពិន្ទុ |
| **4.** តើអ្នកត្រូវសិក្សានៅវិក្រឹតការខេត្តប៉ុន្មានឆ្នាំដើម្បីក្លាយជាគ្រូម្នាក់? | ក. ពីរឆ្នាំ | 2 ពិន្ទុ |
| **5.** តើអ្នកត្រូវបញ្ចប់ថ្នាក់ទីប៉ុន្មានដើម្បីចូលរៀនសាកលវិទ្យាល័យកម្រិតបរិញ្ញាបត្រ? | គ. ថ្នាក់ទី១២ | 2 ពិន្ទុ |
| | ពិន្ទុវង្វាយតម្លៃ | /10 |

ឧទាហរណ៍នៃតារាងកំណត់ត្រាការងារគោលដៅ (ដើម្បីរក្សាទុកនូវកំណត់ត្រានៃការងារគោលដៅរបស់សិស្សថ្នាក់ទី៨ទាំងអស់)។

| ល.រ | ឈ្មោះសិស្ស | ភេទ | មុខវិជ្ជាដែលចូលចិត្ត (រៀបរាប់ឱ្យបាន៤) | មុខវិជ្ជាដែលពូកែ (រៀបរាប់ឱ្យបាន ១ ឬ ២) | ជំនាញដទៃទៀត (ឧ.មកពីក្លឹបបំណិនជីត ការជួយគ្រួសារ) | ការងារដែលអាចទាក់ទង | រៀបរាប់ការងារគោលដៅ ១ ឬ២ | កម្រិតសិក្សាដែលរំពឹងទុក? (ទី៩ ទី១២ ជំនាញ វិជ្ជាជីវៈ សាកលវិទ្យាល័យ) |
|---|---|---|---|---|---|---|---|---|
| 1. | | | * * * * | * * | | * * * * | * * | |
| 2. | | | * * * | * * | | * * * | * * | |
| 3. | | | * * * | * * | | * * * | * * | |
| 4. | | | * * * | * * | | * * * | * * | |
| 5. | | | * * * | * * | | * * * | * * | |
| 6. | | | * * * | * * | | * * * | * * | |
| 7. | | | * * * | * * | | * * * | * * | |
| 8. | | | * * * | * * | | * * * | * * | |

## ឧទាហរណ៍នៃការដាក់ពិន្ទុសម្រាប់កម្រងសំណួរអាជីពអនាគត

**កម្រងសំណួរអាជីពអនាគត**

| ឈ្មោះ: | | ថ្នាក់ | |
|---|---|---|---|
| ល.រ. | សំណួរ | ចម្លើយ | ពិន្ទុ |
| 1. | តើអ្នកនឹងបន្តការសិក្សារហូតដល់បញ្ចប់ថ្នាក់ទី១២ បន្ទាប់ពីអ្នកបញ្ចប់ថ្នាក់ទី៩? | បាទ/ចាស ទេ មិនដឹង | 5 0 0 |
| 2. | តើឪពុកម្ដាយរបស់អ្នកនឹងអនុញ្ញាតឱ្យអ្នករៀនរហូតដល់ថ្នាក់ទី១២ | បាទ/ចាស ទេ មិនដឹង | 2 0 0 |
| 3. | ក. តើអ្នកដឹងថាការងារមួយណាដែលអ្នកចាប់អារម្មណ៍ នៅពេលអ្នកបញ្ចប់ការសិក្សា? | បាទ/ចាស ទេ | 1 0 |
| | ខ. ប្រសិនបើដឹង តើការងារអ្វីខ្លះដែលអ្នកចង់ធ្វើ? | ______ ______ ______ | 5 0 |
| | គ. ប្រសិនបើដឹង តើគ្រួសាររបស់អ្នកយល់ស្របជាមួយគំនិតរបស់អ្នកទេ? | បាទ/ចាស ទេ មិនដឹង | 2 0 0 |
| 4. | តើអ្នកធ្លាប់និយាយជាមួយនរណាម្នាក់អំពីការងារអនាគតរបស់អ្នកដែរឬទេ? (ជ្រើសរើសជម្រើសទាំងអស់ដែលត្រូវនឹងអ្នក) | ឪពុកម្ដាយ ✓<br>បងប្អូន<br>ក្រុមប្រឹក្សាសិស្ស<br>នាយកសាលា<br>គ្រូ<br>មិត្តភ័ក្ត ✓ | 1<br>1<br>1<br>1<br>1<br>1 |
| 5. | តើអ្នកណា ឬសម្ភារៈអ្វីខ្លះដែលអ្នកប្រើដើម្បីស្វែងរកការងារ ឬស្រាវជ្រាវពីអាជីពទាំងនេះ? | ______ ______ ______ ______ | 2 0 |
| | | សរុប | 4 |

អ្នកដែលទទួលបានពិន្ទុលើសពី ១៣ ឬច្រើនជាងនេះ មិនចាំបាច់ត្រូវធ្វើការសម្ភាសម្នាក់ទល់ម្នាក់ទេ - ពួកគេគួរបំពេញក្នុងបញ្ជីអត្តសញ្ញាណអាជីពរបស់សិស្សភ្លាមៗ។

អ្នកដែលទទួលបាន៨ពិន្ទុ ឬតិចជាងនេះ គួរទទួលបានការសម្ភាសម្នាក់ទល់ម្នាក់ជាមួយអ្នកប្រឹក្សាអាជី និង/ឬ អ្នកប្រឹក្សាសាលារៀន និងចូលរួមក្នុងសកម្មភាពបន្ថែមជាមួយក្រុមប្រឹក្សាកុមារ។ ពួកគេបំពេញបញ្ជី អត្តសញ្ញាណអាជីពបន្ទាប់ពីការសម្ភាសម្នាក់ទល់ម្នាក់។

សម្រាប់សិស្សដទៃទៀត ពួកគេគួរត្រូវបានផ្ដល់អាទិភាពទៅតាមតម្រូវការ។ ពួកគេអាចបំពេញបញ្ជីអត្តសញ្ញាណអាជីព ប៉ុន្តែប្រហែលជាត្រូវការស្រាវជ្រាវបន្ថែមទៀតដោយមានជំនួយពីក្រុមប្រឹក្សាសិស្សដើម្បីបំពេញវា។

# សកម្មភាពបន្ថែម

**គោលបំណង៖**

គោលបំណងនៃសកម្មភាពបន្ថែមនេះ គឺដើម្បីធ្វើឱ្យប្រាកដថា សិស្សទាំងអស់បានទទួលការណែនាំពីអាជីព នៅខាងក្រៅនិងពីបំណិនជីវិតក្នុងថ្នាក់ទី៨របស់ពួកគេ។ ហេតុដូច្នេះហើយ ពួកគេត្រូវផ្តល់ការគាំទ្របន្ថែម ដែលពួកគេត្រូវគិតពីការសិក្សា និងឱកាសបណ្តុះបណ្តាលបន្ទាប់ពីថ្នាក់ទី៩ និងទី១២ ព្រមទាំងអាជីពក្នុងពេលអនាគតផងដែរ។ ជាពិសេសក្រុមប្រឹក្សាកុមារ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយរៀបចំសកម្មភាពពាក់ព័ន្ធ ក្នុងសាលានិងធ្វើឱ្យប្រាកដថា សិស្សដែលប្រឈមនឹងការបោះបង់ការសិក្សា ត្រូវបានគាំទ្រនិងជួយដោះស្រាយពីការប្រឹក្សា អាហារូបករណ៍ និងសេវាកម្មគាំទ្រអ្វីខ្លះដែលមានក្នុងសាលារៀនរបស់ពួកគេ។

តើគួររៀបចំសកម្មភាពបន្ថែមនៅពេលណា?

វាត្រូវបានណែនាំថា អ្នកប្រឹក្សាអាជីព ជួបប្រជុំជាមួយក្រុមប្រឹក្សាកុមារយ៉ាងតិចណាស់ ពីរសប្តាហ៍មុនពេលចាប់ផ្តើមបង្រៀនវគ្គបំណិនជីវិត។ នេះនឹងធ្វើឱ្យប្រាកដថា ពួកគេអាចជួយអ្នកប្រឹក្សាអាជីពរៀបចំធនធានអាជីពក្នុងបណ្ណាល័យ និងធ្វើផែនការក្នុងការជម្រាបឪពុកម្តាយសិស្សអំពីសកម្មភាពណែនាំពីអាជីពក្នុងសាលារៀន។ បន្ទាប់ពីនេះ អ្នក ប្រឹក្សាអាជីពគួរជួបជាមួយក្រុមប្រឹក្សាកុមារយ៉ាងតិចណាស់ម្តងក្នុងមួយខែដើម្បីពិភាក្សាពីសកម្មភាពអ្វីខ្លះដែលពួកគេនឹងធ្វើនៅក្នុងកំឡុងខែបន្ទាប់។

**កិច្ចប្រជុំពិសេសមួយគួរត្រូវបានរៀបចំយ៉ាងឆាប់បំផុតបន្ទាប់ពីបញ្ចប់មេរៀនវគ្គបំណិនជីវិតដើម្បីពន្យល់ពីរបៀបធ្វើការជាមួយសិស្សដែលទទួលបានពិន្ទុទាបនៅក្នុងកម្រងសំណួរអាជីពក្នុងពេលអនាគត។**

## វគ្គបណ្តុះបណ្តាលលើកទី១ ជាមួយក្រុមប្រឹក្សាកុមារ

🕑 រយៈពេលបង្រៀនៈ ១០០ នាទី

☑ ការត្រៀមលក្ខណៈ មុនពេលបង្រៀន លោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ខ្លឹមសារអំពីតួនាទី និងការទទួលខុសត្រូវ
- ក្រដាសរ៉ាម ហ្វឺត និងស្កុត

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- ស្វែងយល់ពីតួនាទីរបស់ពួកគេក្នុងការគាំទ្រសកម្មភាពណែនាំពីអាជីពក្នុងសាលារៀន

**សេចក្តីណែនាំពីតួនាទី និងការទទួលខុសត្រូវពីអាជីព** 🕑 **៣០ នាទី**

✋ ស្វាគមន៍សមាជិកក្រុមប្រឹក្សាកុមារ និងប្រាប់ពួកគេថាអ្នកនឹងពន្យល់ពីរបៀប ដែលពួកគេអាចគាំទ្រសកម្មភាពណែនាំពីអាជីពក្នុងសាលារៀន។ ប្រាប់ពួកគេថា អ្នកនឹងបង្រៀនសិស្សថ្នាក់ទី៨នូវវគ្គបំណិនជីវិតមួយ ហៅថាការជ្រើសរើសអនាគតរបស់អ្នក។ ក្រុមប្រឹក្សាសិស្ស នឹងជួយគាំទ្រសិស្សទាំងអស់ក្នុងសាលារៀន ក្នុងកំឡុងពេល១០សប្តាហ៍នេះ ដោយប្រាប់ពួកគេពីការគាំទ្រ និងព័ត៌មានផ្សេងៗដើម្បីជួយពួកគេ។ បន្ទាប់ពីវគ្គបំណិនជីវិត ១០សប្តាហ៍ត្រូវបានបញ្ចប់ ពួកគេនឹងផ្តល់ការគាំទ្របន្ថែមចំពោះសិស្សថ្នាក់ទី៨ដែលត្រូវការវា។

**ទំនួលខុសត្រូវអ្នកប្រឹក្សាអាជីព**

<u>១. សិស្សទាំងអស់មានឱកាសគិតអំពីជម្រើសអាជីពរបស់ពួកគេក្នុងសាលារៀន</u>



- បង្រៀនមេរៀនបំណិនជីវិតអំពីការជ្រើសរើសផ្លូវសិក្សា និងអាជីពឱ្យសិស្សថ្នាក់ទី៨
- បណ្តុះបណ្តាលសមាជិកក្រុមប្រឹកស្សាសិស្សអំពីតួនាទីគាំទ្រការណែនាំពីអាជីព និងត្រួតពិនិត្យផែនការអនុវត្តរបស់ពួកគេ
- តាមដានផែនការនិងដំណើរការរបស់ក្រុមប្រឹក្សាសិស្សយ៉ាងតិចណាស់ម្តងក្នុងមួយខែ១

<u>២. ការគាំទ្រការណែនាំពីអាជីពបន្ថែមដែលផ្តល់សម្រាប់សិស្សអាទិភាព</u>

- ផ្តល់ការសម្ភាសម្នាក់ទល់ម្នាក់ ឬរៀបចំជាមួយអ្នកប្រឹក្សាសាលារៀន អ្នកប្រឹក្សាស្ត្រី ឬ គណៈកម្មាធិការគ្រប់គ្រងអាហាររូបករណ៍ក្នុងមូលដ្ឋាន ដើម្បីជួបប្រជុំជាមួយសិស្ស តាមភាពសមរម្យដើម្បីគាំទ្រកុមារនីមួយៗដែលមានពិន្ទុទាប។

<u>៣. ភាពផ្សេងៗនៃធនធានអាជីពដែលមានក្នុងសាលារៀន</u>



- មើលខុសត្រូវការទុកដាក់សម្ភារៈដែលត្រូវបានបង្កើតឡើងក្នុងវគ្គបំណិនជីវិត និងផែនការរបស់ក្រុមប្រឹក្សាសិស្សដើម្បីរៀបចំ និងធ្វើការដាក់បង្ហាញសម្ភារៈណែនាំពីអាជីពក្នុងបណ្ណាល័យ។

**ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាសិស្ស**

<u>១. សិស្សទាំងអស់មានឱកាសគិតអំពីជម្រើសអាជីពរបស់ពួកគេក្នុងសាលារៀន</u>

- ធ្វើបច្ចុប្បន្នភាពតារាងកំណត់ត្រាការងារគោលដៅរបស់សិស្សថ្នាក់ទី៨ នៅពេលពួកគេត្រៀមរួចរាល់ក្នុងការធ្វើបែបនេះ
- ធ្វើផែនការសកម្មភាពដើម្បីធ្វើឱ្យប្រាកដថា សិស្ស ឪពុកម្តាយ និងសហគមន៍មានការពាក់ព័ន្ធជាមួយសកម្មភាពណែនាំពីអាជីព។

<u>២. ការគាំទ្រការណែនាំពីអាជីពបន្ថែមដែលផ្តល់សម្រាប់សិស្សអាទិភាព</u>

- ជួបជាមួយសិស្សថ្នាក់ទី៨ដែលមានពិន្ទុទាបក្នុងកម្រងសំណួរអាជីពដែលអ្នកប្រឹក្សាអាជីពបានផ្តល់មកឱ្យក្នុងបំណិនជីវិតដើម្បីបញ្ចូលពួកគេក្នុងសកម្មភាពអាជីពបន្ថែម
- សួរអ្នកប្រឹក្សាអាជីព ឬអ្នកប្រឹក្សាសាលារៀនអំពីដំបូលន្មានក្នុងការជួយសិស្ស និងប្រសិនបើចាំបាច់ បញ្ជូនពួកគេទៅកាន់អ្នកប្រឹក្សាអាជីពដោយបញ្ជាក់ពីភាពលំបាកអ្វីខ្លះដែលពួកគេជួបប្រទះ។



<u>៣. ភាពផ្សេងៗនៃធនធានអាជីពដែលមានក្នុងសាលារៀន</u>

- ប្រមូលករណីសិក្សា និងព័ត៌មានអំពីការសិក្សា និងឱកាសបណ្តុះបណ្តាលដែលពេញនិយមបំផុតដើម្បីទុកដាក់ពួកវាឱ្យបានត្រឹមត្រូវសម្រាប់សិស្សពេលបច្ចុប្បន្ន និងអនាគតអាចប្រើប្រាស់បានក្នុងបណ្ណាល័យ
- ផ្សព្វផ្សាយពីព័ត៌មានអ្វីដែលមានក្នុងសាលារៀន
- សរសេរអត្ថបទសម្រាប់ព្រឹត្តិបត្រ ប្រសិនបើមានអនុវត្តក្នុងសាលារបស់ពួកគេ។





សួរសមាជិកក្រុមប្រឹក្សាកុមារៈ តើអ្វីជាភាពខុសប្លែកគ្នារវាងការងារ និងអាជីព?

ចម្លើយដែលអាចមានៈ ជារឿយៗ ការងារគឺមិនមានការគ្រោងទុក និងធ្វើដើម្បីរកប្រាក់ជាគោល។ អាជីពគឺ ជាអ្វីដែលអ្នកកសាង និងអភិវឌ្ឍជាច្រើនឆ្នាំ និងអាចច្រើនជាងការងារមួយ។

តើហេតុអ្វីបានជាសិស្សគប្បីគិតពីអាជីពរបស់ពួកគេក្នុងថ្នាក់ទី៧ ឬទី៨?

ចម្លើយដែលអាចមានៈ វាមានសារៈសំខាន់ក្នុងការធ្វើផែនការ ដូច្នេះពួកគេនឹងបន្តការសិក្សា ខំប្រឹងរៀនសូត្រ និងធ្វើការជ្រើសរើសត្រឹមត្រូវអំពីមុខវិជ្ជាដែលត្រូវសិក្សា។

ឱ្យអ្នកចូលរួមពិភាក្សាជាដៃគូរយៈពេល១ទៅ២នាទីៈ "តើអ្វីជាអ្នកប្រឹក្សាអាជីព?"

អ្នកប្រឹក្សាអាជីពឱ្យសិស្សម្នាក់ ឬពីរនាក់ចែករំលែកគំនិតរបស់ពួកគេ បន្ទាប់មកសរសេរនិយមន័យនៅលើក្តារខៀន ដើម្បីឱ្យសិស្សកត់ទុកក្នុងសៀវភៅរបស់ពួកគេ។

អ្នកប្រឹក្សាអាជីពគឺជាអ្នកដែលបញ្ជាក់ឱ្យសិស្សដឹងពីព័ត៌មានដែលមាននៅក្នុងសាលារៀនអំពីការងារ និងអាជីពក្នុងមូលដ្ឋាន និងក្នុងប្រទេសកម្ពុជា។ ពួកគេផ្តល់គំនិតដល់សិស្សក្នុងការសម្រេចចិត្តធ្វើអ្វីនៅពេលពួកគេបញ្ចប់ថ្នាក់ទី៩។

ពន្យល់ថា មានអ្នកប្រឹក្សាអាជីពក្នុងសាលារៀនរបស់ពួកគេដូចជារូបអ្នក។ ពន្យល់ថា ប្រសិនបើយើងចង់មានឱកាសទទួលបានការងារមានប្រាក់កម្រៃខ្ពស់ យើងត្រូវព្យាយាមទទួលបានការអប់រំល្អ និងត្រូវបញ្ចប់ការអប់រំវិជ្ជាជីវៈ ជំនាញ និង/ឬសាកលវិទ្យាល័យ។

ក្រុមប្រឹក្សាកុមារអាចជួយសិស្សឱ្យគិតអំពីអនាគតរបស់ពួកគេ និងបញ្ជាក់ប្រាប់សិស្សទាំងឡាយដែលជួបការលំបាក ឬកំពុងគិតអំពីការបោះបង់ចោលការសិក្សា និងទទួលបានការគាំទ្រដើម្បីបន្តការរៀនសូត្រប្រសិនបើអាចមាន។ ពិភាក្សាពីបញ្ហានេះមានសារៈសំខាន់ណាស់ ព្រោះវាអាចកាត់បន្ថយជម្រើសអាជីពរបស់អ្នក និងស្វែងរកសក្តានុពលក្នុងពេលអនាគត ដូច្នេះ ប្រសិនបើអ្នកកំពុងគិតអំពីការឈប់រៀន អ្នកគួរពិភាក្សាជាមួយអ្នកប្រឹក្សាអាជីព អ្នកប្រឹក្សាសិស្ស និង/ឬនាយកសាលា គណៈកម្មការគ្រប់គ្រងអាហាររូបករណ៍ក្នុងតំបន់ ឬអ្នកផ្តល់ការគាំទ្រផ្សេងទៀត ដូច្នេះពួកគេអាចពិភាក្សាពីជំនួយបែបណាមានសម្រាប់អ្នក និងធ្វើឱ្យអ្នកប្រាកដក្នុងចិត្តជម្រើសដើម្បីបន្តការសិក្សា និងការបណ្តុះបណ្តាល។

ចូរចងចាំ អ្នកនឹងធ្វើការស្ទើរតែពេញមួយជីវិតនៃយុវវ័យរបស់អ្នក ដូច្នេះវាមានសារៈសំខាន់ដែលអ្នកទទួលបានព័ត៌មានគ្រប់គ្រាន់អំពីជម្រើសអ្វីខ្លះដែលអ្នកមាន និងទុកពេលឱ្យខ្លួនរបស់អ្នកបំពេញសក្តានុពលរបស់អ្នក។

ចែកឯកសារឱ្យសិស្សសម្រាប់សកម្មភាពបន្ថែមៈ តួនាទី និងទំនួលខុសត្រូវ។ ឱ្យសមាជិកក្រុមប្រឹក្សាកុមារអានពីតួនាទី និងទំនួលខុសត្រូវ បន្ទាប់មកសួរថាតើពួកគេមានសំណួរដែរឬទេ។ ប្រាប់ពួកគេថា អ្នកនឹងផ្តល់ឱ្យពួកគេនូវគំនិតបន្ថែមទៀតអំពីវិធីដែលពួកគេអាចជួយសិស្សទាំងនោះបាន។

## ការធ្វើផែនការគាំទ្រសម្រាប់សកម្មភាពណែនាំពីអាជីពក្នុងសាលារៀន

៧០ នាទី

សួរក្រុមប្រឹក្សាកុមារថាតើសម្ភារៈណែនាំពីអាជីពអ្វីខ្លះដែលមានក្នុងសាលារៀនរួចហើយ។ កត់ត្រាអ្វីទាំងអស់នោះនៅលើក្តារខៀន និងទុកពេលឱ្យពួកគេកត់ត្រាធនធានសំខាន់ៗដែលមាន។

ពន្យល់ទៅកាន់ក្រុមប្រឹក្សាកុមារថា ពួកគេគួររៀបចំកន្លែងទំនេរមួយនៅក្នុងបណ្ណាល័យដើម្បីទុក និងតាំងបង្ហាញធនធានអាជីព ប្រសិនបើពួកវាមិនមានទេ។ ប្រាប់ពួកគេថាអ្នកបាននិយាយជាមួយបណ្ណារក្សអំពីបញ្ហានេះហើយ។ (សូមកត់សម្គាល់ថា នៅឆ្នាំដំបូងនៃការអនុវត្ត ប្រសិនបើអ្នកមិនទាន់មានធនធានដែលទាក់ទងនឹងអាជីពទេ សកម្មភាពនេះអាចត្រូវបានពន្យារដល់សប្តាហ៍ទី ៤ ឬទី ៥។

ប្រាប់ក្រុមប្រឹក្សាកុមារថា សិស្សថ្នាក់ទី៨ នឹងធ្វើធនធានបន្ថែមពីសប្តាហ៍ទី៤ ដែលជាផ្នែកមួយនៃវគ្គបំណិនជីវិត ដូចជាករណីសិក្សា ពីអ្នកដែលកំពុងធ្វើការក្នុងសហគមន៍។ ដូច្នេះក្រុមប្រឹក្សាកុមារ អាចរៀបចំដើម្បីថតចម្លងករណីសិក្សាដែលសំខាន់បំផុត និងធនធានដទៃទៀត ដើម្បីទុកក្នុងបណ្ណាល័យបន្ទាប់ពីសប្តាហ៍ទី៤។ ពួកគេអាចសម្របសម្រួល ជាមួយប្រធានថ្នាក់ក្នុងការធ្វើកិច្ចការនេះ។ មន្ត្រីអប់រំខេត្ត និងស្រុកក៏នឹងប្រមូលយកករណីសិក្សាដែលល្អបំផុត ដើម្បីចែករំលែកនៅថ្នាក់ខេត្ត ឬថ្នាក់ជាតិ។

ក្រុមប្រឹក្សាកុមារចាប់ផ្តើមរៀបចំសម្ភារៈដែលមានក្នុងបណ្ណាល័យ មុនពេលចាប់ផ្តើមវគ្គបំណិនជីវិតអំពីការជ្រើសរើសផ្លូវសិក្សា និងអាជីពរបស់អ្នក។

ក្រុមប្រឹក្សាកុមារគួរមានភាពស៊ាំជាមួយនឹងធនធានអាជីពដែលមានក្នុងបណ្ណាល័យ និងបន្តធ្វើបច្ចុប្បន្នភាពចំណេះដឹងរបស់ពួកគេដោយបន្ថែមច្បាប់ថតចម្លងធនធានអាជីពល្អបំផុត ដែលត្រូវបានបង្កើតឡើងដោយសិស្សថ្នាក់ទី៨ ក្នុងវគ្គបំណិនជីវិត ទៅក្នុងបណ្ណាល័យ និងការអានធនធានទាំងនេះ។ បន្ទាប់មកពួកគេនឹងអាចផ្សព្វផ្សាយទៅកាន់សិស្សទាំងអស់ក្នុងសាលារៀន និងប្រាប់សហគមន៍ពីអ្វីដែលមានក្នុងសាលា បន្ទាប់ពីការបញ្ចប់វគ្គបំណិនជីវិត ជួយផ្តល់ដំបូន្មានដល់សិស្ស ដែលត្រូវការការគាំទ្របន្ថែមពីពួកគេអាចធ្វើបន្ទាប់ពីថ្នាក់ទី៩ និងទី១២ ហើយរៀបចំសកម្មភាពបន្ថែមក្នុងការណែនាំពីអាជីព។

បញ្ជីត្រូវបានស្នើអំពីធនធានបណ្ណាល័យដែលអ្នកចង់បាន គឺអាចរកបាននៅផ្នែកខាងក្រោយនៃសៀវភៅនេះ។

? តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីបញ្ជាក់ថា អ្នកធ្វើបច្ចុប្បន្នភាពក្នុងបណ្ណាល័យជាទៀងទាត់ ហើយនឹងធ្វើឱ្យសិស្សទាំងអស់ទទួលបានព័ត៌មានអំពីសកម្មភាពណែនាំពីអាជីពក្នុងសាលារៀន?

ចម្លើយដែលអាចមាន៖ ជួបប្រជុំយ៉ាងតិចណាស់មួយខែម្តងដើម្បីធ្វើផែនការពីសម្ភារៈបន្ថែមដែលពួកគេចង់រក្សាទុកក្នុងបណ្ណាល័យ និងត្រួតពិនិត្យដំណើរការរបស់ពួកគេ។ កំណត់ពេលវេលាណាមួយជារៀងរាល់ខែដើម្បីផ្សព្វផ្សាយទៅកាន់សិស្សទាំងអស់អំពីសម្ភារៈអ្វីខ្លះដែលមានក្នុងបណ្ណាល័យ ហើយធ្វើផែនការឱ្យបានច្បាស់លាស់អំពីសកម្មភាពដែលពួកគេនឹងអនុវត្ត ផ្តល់ត្រឡប់មកឱ្យអ្នកវិញដើម្បីត្រួតពិនិត្យ និងបន្ថែមមតិយោបល់ និងធ្វើឱ្យប្រាកដថាសិស្សមានការយល់ដឹងពីមនុស្ស និងការគាំទ្រទាំងអស់ដែលមានសម្រាប់ពួកគេក្នុងសាលារៀនរបស់អ្នក។

? តើនរណាខ្លះនៅក្នុងសាលារបស់យើងអាចជួយកុមារជួបប្រទះទុក្ខលំបាក ហើយប្រហែលជាចង់បោះបង់ចោលការសិក្សា?

ចម្លើយដែលអាចមាន៖ ក្រុមប្រឹក្សាកុមារ អ្នកប្រឹក្សាអាជីព នាយកសាលា ទីប្រឹក្សាកុមារី LSMC គ្រូដទៃទៀត គណៈកម្មការទ្រទ្រង់សាលារៀន ។ល។

? តើសេវាកម្មគាំទ្រអ្វីខ្លះដែលអ្នកទាំងនេះអាចផ្តល់ឱ្យសិស្សទាក់ទងនឹងអាជីពក្នុងពេលអនាគតរបស់ពួកគេ និងភាពលំបាកដែលពួកគេជួបប្រទះ ហើយអាចបណ្តាលឱ្យពួកគេបោះបង់ចោលការសិក្សា?

ត្រូវពិនិត្យមើលថា សិស្សសរសេរបញ្ជីអ្នកពាក់ព័ន្ធដែលមានក្នុងសាលារៀនរបស់អ្នក (ក្រុមប្រឹក្សាកុមារ អ្នកប្រឹក្សាអាជីព នាយកសាលា ទីប្រឹក្សាកុមារី LSMC គ្រូដទៃទៀតគណៈកម្មការទ្រទ្រង់សាលារៀន) វិធីដែលពួកគេអាចទាក់ទងអ្នកទាំងនោះ និងការគាំទ្រអ្វីខ្លះដែលពួកគេអាចផ្តល់។ ប្រសិនបើពួកគេមិនច្បាស់អំពីការគាំទ្រដែលអ្នកទាំងនោះអាចផ្តល់ ពួកគេអាចសួរអ្នក និងនាយកសាលា ប្រសិនបើអាច ជួយជាមួយអ្នកពាក់ព័ន្ធដើម្បីស្វែងយល់ឱ្យបានច្បាស់ពីតួនាទីគាំទ្ររបស់ពួកគេ ដូចនេះពួកគេនឹងអាចប្រាប់អ្នកដទៃ។

? តើយើងអាចប្រាកដថាសិស្ស និងឪពុកម្តាយសិស្សទាំងអស់ដឹងថាសេវាកម្មគាំទ្រអ្វីខ្លះដែលមានចំពោះពួកគេក្នុងសាលារៀន?

ចម្លើយដែលអាចមាន៖ ធ្វើការប្រកាសជាទៀងទាត់នៅដងទង់ជាតិ ឬក្នុងថ្នាក់នីមួយៗ ធ្វើជាខិតបណ្ណផ្សព្វផ្សាយ (មើលឧទាហរណ៍ខិតបណ្ណខាងក្រោម ដែលអាចផ្តល់ទៅឱ្យសិស្សថ្នាក់ទី៨ យកទៅផ្ទះ និងពិភាក្សាជាមួយឪពុកម្តាយរបស់ពួកគេ) បិទព័ត៌មានក្នុងការិយាល័យឃុំ និងឱ្យមេឃុំ និងមេភូមិធ្វើសេចក្តីប្រកាសក្នុងសហគមន៍ អញ្ជើញឪពុកម្តាយមកកាន់សាលារៀន និងពន្យល់ពីការគាំទ្រដែលមាន សរសេរអត្ថបទសម្រាប់ព្រឹត្តិបត្រសាលា ប្រសិនបើមាន។

ឱ្យអ្នកចូលរួមពិភាក្សាដៃគូនូវសំណួរខាងក្រោមក្នុងរយៈពេល ៣ ឬ៤នាទី៖

“តើអ្នកគួរធ្វើអ្វី ប្រសិនបើសិស្សម្នាក់មកពិភាក្សាពីបញ្ហាអាជីពជាមួយអ្នក ឬក៏ប្រាប់អ្នកថា ពួកគេ ឬមិត្តរបស់គេជួបការលំបាក ឬចង់ឈប់រៀន?”

សរសេរគំនិតរបស់ពួកគេនៅលើក្តារខៀន និងប្រាប់ពួកគេឱ្យកត់ត្រាវាទុក។ ត្រូវបញ្ជាក់ឱ្យពួកគេកត់ត្រាទុកនូវគំនិតរៀងៗខ្លួន៖ ពិភាក្សា និងកំណត់ឱ្យបានច្បាស់លាស់ពីជំនួយបែបណាដែលពួកគេ ដើម្បីស្វែងរកព័ត៌មានពាក់ព័ន្ធនៅក្នុងសាលារៀន ប្រាប់ពួកគេអំពីការគាំទ្រដែលពួកគេអាចទទួលបាន (ឧ.ការចូលរួមក្នុងក្លឹបសិក្សា អាហា រូបករណ៍ ការប្រឹក្សា។ល។) ជួយពួកគេឱ្យទាក់ទងអ្នកគាំទ្រត្រឹមត្រូវក្នុងសាលារៀន តាមដានជាមួយ សិស្សនៅពេល ក្រោយ ដើម្បីពិនិត្យថាតើពួកគេទទួលបានជំនួយដែលពួកគេត្រូវការដែរឬទេ ប្រសិនបើកុមារប្រឈមនឹងគ្រោះថ្នាក់ ពួកគេអាចពិគ្រោះជាមួយអ្នកប្រឹក្សាអាជីព ឬអ្នកប្រឹក្សាក្នុងសាលារៀន។

វានឹងមានប្រយោជន៍សម្រាប់សមាជិក ៥ ឬ៦នាក់នៃក្រុមប្រឹក្សាដើម្បីក្លាយជា “អ្នកដឹកនាំ” ក្នុងព័ត៌មានអាជីព។ ជាពិសេស យ៉ាងហោចណាស់ ពាក់កណ្តាលនៃ“អ្នកដឹកនាំ” ទាំងនោះគួរសិក្សានៅថ្នាក់ទី៨ និងសិស្សម្នាក់ ឬពីរនាក់មកពីថ្នាក់ទី៩និងថ្នាក់ទី៧ ក៏ស្ថិតក្នុងក្រុមនេះដែរ ដូច្នេះពួកគេអាចផ្សព្វផ្សាយព័ត៌មានក្នុងសាលារៀនដោយភាពងាយស្រួល។ សរសេរឈ្មោះសមាជិកក្រុមប្រឹក្សាកុមារ ដែលយល់ព្រមធ្វើជា “អ្នកជំនាញ” អាជីព។ សមាជិក ក្រុម ប្រឹក្សា ដទៃទៀតអាចនៅតែជាប់ទាក់ទងក្នុងការជួយក្នុងសកម្មភាពណែនាំពីអាជីព ប៉ុន្តែក្រុមដែលមាន សមាជិក ៥ ឬ ៦នាក់ នេះ នឹងទទួលខុសត្រូវពីការទទួលបានព័ត៌មាននិងសកម្មភាពណែនាំពីអាជីព ព្រមទាំងបញ្ជាក់ថា សកម្មភាពណែនាំពីអាជីពកើតមានឡើងក្នុងសាលារៀនមែន។

ប្រាប់សមាជិកក្រុមប្រឹក្សាសិស្សឱ្យធ្វើការជាក្រុមដែលមានសមាជិក៦នាក់ ដើម្បីពិភាក្សាពីសកម្មភាពបន្តទៀតដែលពួកគេនឹងធ្វើក្នុងខែបន្ទាប់ និងសរសេរវាទុកក្នុងក្រដាសរ៉ាម(ឬ ផ្ទាំងក្រដាសធំ) ដោយប្រើហ្វឺត។ ទុកពេល ១៥នាទីឱ្យពួកគេពិភាក្សាពីគំនិតរបស់ពួកគេ។

១៥នាទីក្រោយមក ឱ្យក្រុមមួយមកធ្វើបទបង្ហាញពីគំនិតរបស់ពួកគេ ហើយឱ្យក្រុមដទៃទៀតផ្តល់គំនិតដែលពួកគេមាន។ ប្រសិនបើចាំបាច់ ស្នើឱ្យពួកគេបន្ថែមគំនិតដែលពួកគេគិតថានឹងមានប្រយោជន៍ និងមាន សារៈសំខាន់ (ឧទាហរណ៍ផែនការដែលបានបំពេញរួចមាននៅខាងក្រោម)។

កត់ត្រាតារាងខាងក្រោមនៅលើក្តារខៀន ពន្យល់ពីរបៀបក្នុងការបំពេញវា និងឱ្យសមាជិកម្នាក់នៃក្រុមប្រឹក្សាកុមារដើម្បីជួយសម្របសម្រួលក្នុងការបំពេញតារាង។

| **ផែនការសកម្មភាពណែនាំពីអាជីពសម្រាប់ខែ _______** *[បញ្ចូលខែ]* | | | | |
|---|---|---|---|---|
| លរ | សកម្មភាព | អ្នកទទួលខុសត្រូវ | នៅពេលណា? | រួច? √ ឬ X |
| | | | | |

នៅពេលពួកគេបញ្ចប់ ឱ្យសមាជិកក្រុមប្រឹក្សាកុមារម្នាក់ពិនិត្យមើលពីការវិវឌ្ឍទៅមុខនៃផែនការ និងដាក់ឈ្មោះរបស់ពួកគេនៅផ្នែកខាងក្រោមនៃតារាងជាមួយនឹងកន្លែងចុះហត្ថលេខារបស់ពួកគេ និងរបស់អ្នក។ ពួកគេគួរយល់ព្រមសរសេរផែនការពីរច្បាប់ ហើយអ្នកគ្រូគពិនិត្យផែនការគួររក្សាទុកមួយច្បាប់ និងមួយច្បាប់ទៀតគប្បីផ្តល់ឱ្យអ្នកជាអ្នកថែរក្សា។

ប្រាប់ពួកគេថា អ្នកគ្រូគពិនិត្យផែនការគួរធ្វើរបាយការណ៍ទៅកាន់អ្នកជាទៀងទាត់អំពីការវិវឌ្ឍ និងការពិភាក្សាភាពលំបាកផ្សេងៗដែលពួកគេជួប។ រៀងរាល់ខែចាប់ពីពេលឥឡូវនេះ ក្រុមប្រឹក្សាសិស្សគួរជួបប្រជុំជាមួយគ្នាតាមផ្លូវការដើម្បីពិភាក្សា ពីការវិវឌ្ឍផែនការសកម្មភាពណែនាំពីអាជីពក្នុងខែកន្លងមក ហើយអ្នកគ្រូគពិនិត្យគួរបំពេញតារាង“ធ្វើរួច” ចុះហត្ថលេខាក្នុងផែនការចាស់។ ពួកគេគួរពិភាក្សាផែនការសម្រាប់ខែបន្ទាប់របស់ពួកគេ ឬជួបប្រជុំដាច់ដោយឡែក និងបញ្ជូនវាទៅអ្នក និងរក្សាច្បាប់ចតចម្លងដោយខ្លួនរបស់ពួកគេក្នុងខែនីមួយ។

អ្នកគ្រូគពិនិត្យគួររក្សាទុកស៊ីមីមួយនៃផែនការទាំងអស់ ហើយបញ្ជីនៃព័ត៌មានដែលទាក់ទងនឹងអាជីព និងការស្រាវជ្រាវ ដូច្នេះព័ត៌មាននឹងមាននៅកន្លែងមួយ និងអាចជួយក្មេងជំនាន់ក្រោយ។

ឧទាហរណ៍នៃផែនការសកម្មភាពណែនាំពីការណែនាំអាជីពរបស់ក្រុមប្រឹក្សាកុមារ

| ផែនការសកម្មភាពណែនាំពីអាជីពសម្រាប់ខែធ្នូ | | | | |
|---|---|---|---|---|
| លរ | សកម្មភាព | អ្នកទទួលខុសត្រូវ | នៅពេលណា? | រួច? √ ឬ X |
| 1. | ទៅបណ្ណាល័យ និងធ្វើការជាមួយបណ្ណារក្សដើម្បីបញ្ជាក់ថា សម្ភារៈណែនាំពីអាជីពទាំងអស់ (ប្រសិនបើមាន) ស្ថិតនៅកន្លែងមួយ និងងាយស្រួលរក។ | ដារ៉ា, លីន, រំដួល | 5 ធ្នូ | |
| 2. | វាយអត្ថបទ ឬសរសេរដៃនូវបញ្ជីច្បាប់ចម្លងមួយនៃធនធានណែនាំពីអាជីពដែលមានក្នុងបណ្ណាល័យ។ | រំដួល | 8 ធ្នូ | |
| 3. | ជួបជាមួយអ្នកផ្តល់ការគាំទ្រទាំងអស់ដែលមានក្នុងសាលារៀន (អ្នកប្រឹក្សាអាជីព ទីប្រឹក្សាកុមារី LSMC SSC CEFAC ឬសមាជិកក្រុមប្រឹក្សាឃុំ...) និងស្វែងរកមើលថាតើការគាំទ្រអ្វីខ្លះដែលពួកគេអាចផ្តល់ទៅឱ្យសិស្សដែលជួបការលំបាក ឬអំពីការណែនាំអាជីព។ | សុខា, សារ៉ាន, សំអាត | 9 ធ្នូ | |
| 4 | វាយអត្ថបទ ឬសរសេរដៃនូវលេខទំនាក់ទំនងមួយនៃអ្នកផ្តល់ការគាំទ្រ និងការគាំទ្រសំខាន់ៗដែលពួកគេផ្តល់។ | សុខា, សារ៉ាន | 11 ធ្នូ | |
| 5 | ប្រកាសនៅដងទង់ជាតិ៖<br>• សារៈសំខាន់នៃការអប់រំដើម្បីទទួលបានការងារល្អមួយ<br>• សម្ភារៈណែនាំពីអាជីពដែលមានក្នុងសាលារៀន<br>• អ្នកដែលអាចផ្តល់ការគាំទ្រដល់ពួកគេក្នុងសាលារៀន និងសេវាកម្មសំខាន់ៗដែលពួកគេផ្តល់<br>• សិស្សអាចទំនាក់ទំនងសមាជិកក្រុមប្រឹក្សាកុមារ ថាតើពួកគេចង់ដឹងថានរណាដែលអាចជួយពួកគេ ឬពួកគេដឹងថានរណាដែលចង់បោះបង់ចោលការសិក្សា។<br>• សមាជិកក្រុមប្រឹក្សាទាំងអស់រៀបរាប់ពីឈ្មោះ និងថ្នាក់របស់ពួកគេដើម្បីរំឭកសិស្សថាពួកគេជានរណា។ | រំដួល, សុខា<br><br>(សមាជិកក្រុមប្រឹក្សាសិស្សទាំងអស់ដើម្បីរៀបរាប់ពីឈ្មោះ និងថ្នាក់របស់ពួកគេ) | 14 ធ្នូ | |
| 6. | ថតចម្លង/ធ្វើ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយទៅកាន់សិស្សថ្នាក់ទី៨ ទាំងអស់ដើម្បីឱ្យពួកគេពិភាក្សាជាមួយឪពុកម្តាយរបស់ពួកគេ។ ទៅថ្នាក់ទី៨ ដើម្បីចែកខិត្តប័ណ្ណ។ | លក្ខណា, សុខ | 18 ធ្នូ | |
| 7. | រៀបចំជាមួយអ្នកប្រឹក្សាអាជីពដើម្បីជួបជាមួយមេឃុំ និងស្នើឱ្យពួកគេផ្សព្វផ្សាយទៅកាន់ឪពុកម្តាយអំពីសារៈសំខាន់នៃការពិភាក្សាពីអាជីពរបស់កូនៗពួកគេក្នុងពេលអនាគតជាមួយពួកគេ។ ឱ្យពួកគេបិទខិត្តប័ណ្ណសម្រាប់សិស្សថ្នាក់ទី៨ និងឪពុកម្តាយសិស្សក្នុងការិយាល័យឃុំ។ | សុខា, សារ៉ាន់ | 22 ធ្នូ | |
| 8. | ពិនិត្យផែនការដើម្បីបញ្ជាក់ថាវាត្រូវបានបញ្ចប់តាមពេលកំណត់ ហើយពិភាក្សាបញ្ហានានាជាមួយក្រុមប្រឹក្សាកុមារ។ | ដារ៉ា | | |
| 9. | ជួបប្រជុំដើម្បីពិនិត្យផែនការឡើងវិញ ពិភាក្សាបញ្ហា និងដំណោះស្រាយ និងធ្វើផែនការសម្រាប់សកម្មភាពខែបន្ទាប់។ | ដារ៉ា (ត្រូវចូលរួមទាំងអស់គ្នា) | 24 ធ្នូ | |
| 10. | បញ្ជូនផែនការចាស់ទៅកាន់អ្នកប្រឹក្សាអាជីព និងសរសេរផែនការថ្មី២ច្បាប់ និងឱ្យមួយច្បាប់ទៅកាន់អ្នកប្រឹក្សាអាជីព។ | ដារ៉ា | 26 ធ្នូ | |
| បំពេញដោយ | | ពិនិត្យដោយ | | |
| ថាន ដារ៉ា - (ក្រុមប្រឹក្សាកុមារ) | | ជ័យ សុជាតិ - (អ្នកប្រឹក្សាអាជីព) | | |

ប្រាប់ពួកគេថា អ្នកនឹងធ្វើការបណ្តុះបណ្តាលបន្ថែមទៀតដើម្បីធ្វើផែនការសកម្មភាពបន្ថែម ប្រហែលជា ១ ឬ២សប្តាហ៍មុនពេលបញ្ចប់វគ្គបំណិនជីវិត ដូចនេះពួកគេដឹងពីរបៀបក្នុងការគាំទ្រសិស្សថ្នាក់ទី៨ ដែលត្រូវការជំនួយបន្ថែម ក្នុងការស្វែងរកអាជីពរបស់ពួកគេ និងអាចរៀបចំជាក្លឹបអាជីពមួយ។

## សម្រាប់ឪពុកម្តាយរបស់អ្នក

កូនរបស់អ្នកកំពុងសិក្សាកម្រិតមធ្យមសិក្សា។ ដោយការធ្វើរបៀបនេះ ឱកាសសម្រាប់ការងារល្អមួយគឺមានការកើនឡើង។

ជាផ្នែកមួយនៃសកម្មភាពបំណិនជីវិត សាលារបស់យើងអញ្ជើញសិស្សថ្នាក់ទី៩ទាំងអស់ឱ្យគិត និងរៀនអំពីអាជីពក្នុងពេលអនាគតរបស់កូនគេ។ យើងនឹងរៀបចំផែនការជីវិត និងព័ត៌មាននៅសាលារៀន។

ក្រុមប្រឹក្សាក្រុមយើងផ្តល់ព័ត៌មានបន្ថែមទៅកាន់អ្នកដែលមិនច្បាស់អំពីការសិក្សា និងការបណ្តុះបណ្តាលអ្វីដែលកូនគេចង់ធ្វើ បន្ទាប់ពីបញ្ចប់ថ្នាក់ទី៩។ អ្នកប្រឹក្សាអាជីពក្នុងសាលារៀនអាចនឹងធ្វើការសម្ភាសជាមួយសិស្សដែលអាចត្រូវការជំនួយបន្ថែម។ ប្រសិនបើអ្នកចាប់អារម្មណ៍ចង់ដឹងបន្ថែមទៀតអំពីកិច្ចការនេះ សូមធ្វើដំណើរមកកាន់សាលា ឬសួរសិស្សរបស់អ្នកអំពីវា។

យើងចង់ដឹងពីគំនិតរបស់អ្នកពីអនាគតរបស់កូនអ្នក។ សូមបំពេញក្នុងទម្រង់សំណួរដែលមានភ្ជាប់ និងបញ្ជូនវាត្រឡប់មកកាន់សាលារៀនវិញ។

ខិត្តប័ណ្ណនេះត្រូវផ្តល់ទៅឱ្យអ្នកដោយក្រុមប្រឹក្សាសិស្ស ដែលជាផ្នែកមួយនៃកម្មវិធីបំណិនជីវិត ប្រព័ន្ធក្នុងសាលារបស់យើង។ ប្រសិនបើអ្នកមានសំណួរបន្ថែមទៀត សូមទាក់ទងអ្នកប្រឹក្សាអាជីព។

USAID ជំនួយពីពលរដ្ឋអាមេរិក
អង្គការអប់រំពិភពលោក WORLD EDUCATION

បន្ទាប់ពីថ្នាក់ទី៩ មានផ្លូវពីរ ដើម្បីបន្តការសិក្សារបស់អ្នក។



1. បន្តការសិក្សាទៅថ្នាក់ទី ១០-១២។ បន្ទាប់ពីនេះ អ្នកអាចចូលរៀនមហាវិទ្យាល័យ ឬ សាលាផ្សេងៗដើម្បីក្លាយជាវិស្វករ គិលានុបដ្ឋាក៍ គ្រូបង្រៀន អ្នកគ្រប់គ្រង ទន្តពេទ្យ អ្នកប្រឹក្សា...
2. សិក្សានៅវិទ្យាស្ថានបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីក្លាយជាជាងកាត់សក់ ជាងសំណង់ អ្នកថែទាំ ជាងកាត់ដេរ ជាងអគ្គិសនី ជាងទឹក ឬ...

# សូមមកមើលវេទិកាក្រុមការងាររបស់យើង!



## គិតអំពីអាជីពរបស់អ្នក ក្នុងសាលារៀនរបស់យើង



ខិត្តប័ណ្ណនេះគឺសម្រាប់អ្នក និងគ្រួសាររបស់អ្នក ដើម្បី និយាយ អនាគតរបស់អ្នក។



ក្នុងថ្នាក់ទី៩ យើងនឹងនិយាយ គិត អំពីអាជីពដែលអាចមាន និងវិធីដើម្បីទទួលបានពួកវា។

តើអ្នកបានដឹងហើយឬនៅថាតើអ្វីដែលអ្នកចង់ធ្វើនៅពេលបញ្ចប់ការសិក្សា?
ហើយតើអ្នកដឹងពីរបៀបត្រៀមសម្រាប់វាដែរឬទេ?
ខិត្តប័ណ្ណនេះ និងអ្នកប្រឹក្សាអាជីព អាចជួយអ្នកបាន....

## ខ្ញុំមិនដឹង



អ្នកមិនដឹងពីអ្វីដែលអ្នកចង់ធ្វើ ប្រសិនបើអ្នកបញ្ចប់ការសិក្សា? វាមិនអ្វីទេ។ សិស្សជាច្រើនមិនទាន់ដឹងនៅឡើយ។

ប៉ុន្តែ

**ឥឡូវនេះ** គឺជាពេលវេលាដើម្បីចាប់ផ្តើមការគិតអំពីវា។ អ្នកស្ថិតក្នុងថ្នាក់ទី៨ហើយ។ តើអ្នកបន្តការសិក្សារបស់អ្នករហូតដល់បញ្ចប់ថ្នាក់ទី១២ ឬបន្តដល់មហាវិទ្យាល័យ ឬជំនាញវិជ្ជាជីវៈ?

**ហើយ** តើអ្នកអាចក្លាយជាអ្វី?

តើអ្នកដឹងថាការងារអ្វីខ្លះដែលមានក្នុងតំបន់របស់អ្នក?

វគ្គបំណិនជីវិត ការជ្រើសរើសផ្លូវសិក្សា និងអាជីពនឹងជួយអ្នកឱ្យគិតអំពីវា។ បន្ថែមពីនេះ ក្រុមប្រឹក្សាសិស្ស និងអ្នកប្រឹក្សាអាជីពអាចជួយអ្នកបាន។ យើងនឹង៖

- បង្កើតជាបញ្ជីនៃសាលារៀន មហាវិទ្យាល័យ និងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងសហគមន៍របស់អ្នក។
- ចងក្រងជាផែនទីនៃអាជីពដែលមានក្នុងតំបន់របស់អ្នក។
- តើមានករណីសិក្សា និងធនធានការងារដែលផ្តល់គំនិតល្អដល់អ្នកអំពីតម្រូវការ និងកិច្ចការសម្រាប់ការងារផ្សេងៗ...

## ខ្ញុំដឹង...



ប្រហែលជាអ្នកបានដឹងរួចហើយថាអ្នកចង់ក្លាយជាជាងជួសជុល ដូចក្មេងប្រុសក្នុងរូបភាព។ វាជាការងារល្អមួយ។

ប៉ុន្តែ...

តើអ្នករៀបចំសម្រាប់វាដោយរបៀបណា? មានជាងជួសជុលជាច្រើន... តើអ្នកនឹងធ្វើឱ្យលេចធ្លោដោយរបៀបណា?

តើអ្នកចង់ក្លាយជាអ្នកពូកែជាងគេដែលអតិថិជននឹងមករកអ្នក? ការទទួលបានការអប់រំគឺជាវិធីល្អបំផុតក្នុងការសិក្សាពីជំនាញ និងចំណេះដឹង។ ប៉ុន្តែ **នៅឯណា និងរបៀបណា**... នេះគឺជាអ្វីដែលត្រូវស្រាវជ្រាវ និងពិភាក្សាក្នុងថ្នាក់បំណិនជីវិតជាមួយមិត្តភ័ក្ក គ្រូ ឪពុកម្តាយ និងអ្នកជិតខាងរបស់អ្នក។

## តើអ្នកចង់ក្លាយជាអ្វី?

## ៧ជំហាន

### អ្វីដែលយើងនឹងធ្វើជាមួយនឹងអ្នក

1. **ផ្តល់**និក្ខប័ណ្ណទៅឪពុកម្តាយរបស់អ្នក
2. **និយាយ**ជាមួយឪពុកម្តាយរបស់អ្នកអំពីគំនិតរបស់ពួកគេសម្រាប់ អាជីពនាពេលអនាគតរបស់អ្នក និងសួរពួកគេអំពីហេតុផល។
3. **មើល**ធនធានអាជីពក្នុងបណ្ណាល័យ និងអ្វីមួយដែលអ្នកនឹងធ្វើនៅក្នុងថ្នាក់រៀនរបស់អ្នក។
4. **សរសេរ** ពីគំនិតណាមួយដែលអ្នកមានអំពីទេពកោសល្យ និងចំណាប់អារម្មណ៍ក្នុងបញ្ជីសំណួរដែលអ្នកប្រឹក្សាអាជីពនឹងផ្តល់ឱ្យអ្នក។
5. **គិត**ថាតើអ្នកត្រូវការជំនួយក្នុងការស្វែងរកសាលាសមរម្យ ឬអាជីពពីអ្នកប្រឹក្សាអាជីព ឬក្រុមប្រឹក្សាសិស្ស។
6. **ពិភាក្សា** ជាមួយក្រុមប្រឹក្សាសិស្ស ប្រសិនបើអ្នកជួបប្រទះភាពលំបាកក្នុងការបន្តការសិក្សា។
7. **សម្រេច** ថាតើជំហានណាមួយដែលអ្នកត្រូវធ្វើដើម្បីសម្រេចគោលដៅរបស់អ្នក - ហើយ**ធ្វើវា!**

# វគ្គបណ្ដុះបណ្ដាលលើកទី ២ ជាមួយក្រុមប្រឹក្សាកុមារ

ចំនួនម៉ោងបង្រៀន - ១៥០នាទី

☑ ដំណាក់កាលត្រៀមរៀបចំរបស់គ្រូ

- រៀបចំពេលវេលា និងទីកន្លែងសមរម្យដើម្បីជួបប្រជុំជាមួយក្រុមប្រឹក្សាកុមារ យ៉ាងតិចណាស់ ១ ឬ ២ សប្ដាហ៍មុនពេលអ្នកចាប់ផ្ដើមបង្រៀនវគ្គបំណិនជីវិតនេះ - ក្នុងកំឡុងសប្ដាហ៍ដូចគ្នានឹងមេរៀនបំណិនជីវិតទី៩ គឺល្អប្រសើរបំផុត។
- រៀបចំតារាងកំណត់ត្រាការងារគោលដៅ (មើលទំព័រទី៣០ មេរៀនទី១០)។ អានមេរៀនទី១០ ដូច្នេះអ្នកយល់ច្បាស់ពីរបៀបប្រើប្រាស់តារាងការងារគោលដៅ និងកម្រងសំណួរអាជីពអនាគត។
- រៀបចំផ្ទាំងក្រដាសធំអំពីគំរូនៃកម្រងសំណួររបស់ឪពុកម្ដាយ

សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារសកម្មភាពបន្ថែម៖ តួនាទី និងទំនួលខុសត្រូវ
- ឯកសារទី៤ ចែកសិស្ស ៖ កម្រងសំណួរអាជីពអនាគត (រកបានក្នុងមេរៀនទី១០)
- តារាងកំណត់ត្រាការងារគោលដៅ
- គំរូនៃកម្រងសំណួររបស់ឪពុកម្ដាយ
- តារាងសកម្មភាពក្លឹបដែលបានផ្ដល់ជាយោបល់
- ក្រដាស់វាម ហ្វឺត និងស្កុត

☼ វត្ថុបំណង: នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាចៈ

- បង្ហាញពីរបៀបក្នុងការធ្វើផែនការផ្ដល់ការគាំទ្របន្ថែមសម្រាប់សិស្សអាទិភាពក្នុងថ្នាក់ទី៨
- សិក្សាពីការរៀបចំផែនការ និងអនុវត្តក្លឹបសិក្សាពីអាជីព

## សេចក្ដីផ្ដើមៈ រំឭកពីតួនាទី និងទំនួលខុសត្រូវ — ១៥ នាទី

ស្វាគមន៍ក្រុមប្រឹក្សាកុមារ និងពន្យល់ថា អ្នកចង់រំឭកជាមួយពួកគេអំពីទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាកុមារក្នុងការផ្ដល់សកម្មភាពណែនាំពីអាជីព។ សួរពួកគេថាតើពួកគេអាចចងចាំពីតួនាទី និងទំនួលខុសត្រូវរបស់ពួកគេដែរឬទេ។ ឱ្យពួកគេឆ្លើយ ហើយបន្ទាប់មកឱ្យពួកគេពិនិត្យមើលក្នុងឯកសារសកម្មភាពបន្ថែម៖ តួនាទី និងទំនួលខុសត្រូវថាតើពួកគេឆ្លើយខុស ឬត្រូវ។

## ការជួបជាមួយសិស្សអាទិភាព — ៤០ នាទី

ពន្យល់ថា អ្នកនឹងបញ្ចប់វគ្គបំណិនជីវិត ការជ្រើសរើសអនាគតរបស់អ្នកជាមួយសិស្សថ្នាក់ទី៨ក្នុងពេលឆាប់ៗនេះ ដូច្នេះហើយសិស្សមួយចំនួនត្រូវការជំនួយដើម្បីឱ្យពួកគេធ្វើការសម្រេចចិត្តបានត្រឹមត្រូវនៅពេលពួកគេបញ្ចប់ថ្នាក់ទី៩ ឬទី១២។ ក្រុមប្រឹក្សាសិស្សអាចជួយពួកគេដោយស្វែងរកនូវបញ្ហាលំបាកៗដែលពួកគេជួបប្រទះ។

ចែកពួកគេនូវឯកសារចែកសិស្ស៤៖ កម្រងសំណួរអាជីពអនាគត និងពន្យល់ថា ពួកគេនឹងជួបជាមួយសិស្សដែលមានពិន្ទុទាបជាង១៣។ ពន្យល់ថា សិស្សដែលទទួលបានពិន្ទុ៨ ឬទាបជាងនេះគឺប្រឈមជាមួយនឹងការបោះបង់ចោលការសិក្សា បន្ទាប់ពីថ្នាក់ទី៩។

ប្រាប់ពួកគេថា បន្ទាប់ពីបញ្ចប់មេរៀននេះ អ្នកនឹងផ្ដល់ឱ្យពួកគេនូវបញ្ជីឈ្មោះសិស្សអាទិភាព ហើយក្រុមប្រឹក្សាសិស្សគួររៀបចំពេលវេលាជួបជាមួយពួកគេដើម្បីស្វែងរកមើលពីបញ្ហាសំខាន់ៗដែលសិស្សទាំងនោះបានជួបប្រទះ និងវិធីដោះស្រាយបញ្ហាទាំងនេះរបស់ក្រុមប្រឹក្សាកុមារ។

ចំពោះបញ្ហាលំបាកដែលក្រុមប្រឹក្សាកុមារមិនអាចដោះស្រាយបាន ឬក៏សិស្សមិនចង់ពិភាក្សាជាមួយពួកគេ ក្រុមប្រឹក្សាសិស្សគួរសរសេរនូវបញ្ជីឈ្មោះសិស្ស និងធ្វើកំណត់សម្គាល់នៅក្បែរឈ្មោះរបស់ពួកគេអំពីបញ្ហាសំខាន់ៗ ដូច្នេះអ្នកអាចជួយពួកគេរៀងៗខ្លួន ឬបញ្ជូនពួកគេទៅរកអ្នកសមស្របក្នុងសាលាដែលអាចជួយពួកគេបាន។

សិស្សភាគច្រើន នៅតែមិនមិនអាចធ្វើការសម្រេចចិត្តបានច្បាស់លាស់បន្ទាប់ពីបញ្ចប់ថ្នាក់ទី៩។ ដូច្នេះ ក្រុមប្រឹក្សាកុមារអាចដាក់បញ្ចូលសិស្សដែលមានពិន្ទុទាបទាំងអស់ ជាពិសេសអ្នកដែលបានពិន្ទុ ៨ ឬតិចជាងនេះទៅក្នុងក្លឹបអាជីពដើម្បីបន្តស្វែងរកបញ្ហាអាជីពបន្ថែមទៀត។

ក្នុងកំឡុងពេលប្រជុំផងដែរ ក្រុមប្រឹក្សាកុមារគួរផ្តល់ឱ្យសិស្សនូវបញ្ជីសំណួរ ឬឱ្យពួកគេសរសេរវាដើម្បីពិភាក្សាជាមួយឪពុកម្តាយឬអាណាព្យាបាលរបស់ពួកគេ។វាមានសារៈសំខាន់ណាស់ដែលសិស្សទាំងអស់ត្រូវព្យាយាមពិភាក្សាពីអនាគតរបស់ពួកគេជាមួយមនុស្សជាច្រើនតាមតែអាចធ្វើបាន នេះរួមបញ្ចូលទាំងឪពុកម្តាយរបស់ពួកគេ។ ជាពិសេស វាមានសារៈសំខាន់ណាស់សម្រាប់សិស្សអាទិភាព ដូច្នេះពួកគេអាចព្យាយាមដោះស្រាយបញ្ហាលំបាកនានាដែលពួកគេមាន។ ដោយប្រើកម្រងសំណួរពីសាលាជួយសិស្សឱ្យលើកបញ្ហាជាមួយឪពុកម្តាយរបស់ពួកគេ។

ឧទាហរណ៍នៃកម្រងសំណួរមានបង្ហាញនៅខាងក្រោម។ សរសេរវានៅលើក្តារខៀនដើម្បីឱ្យសិស្សកត់ត្រាទុក។ ក្រុមប្រឹក្សាសិស្សអាចពិភាក្សាជាមួយសិស្សនៅក្នុងការប្រជុំលើកទី១ ប្រសិនបើពួកគេគិតថា ពួកគេត្រូវការបន្ថែមសំណួរថែមទៀត។

## គំរូកម្រងសំណួរសម្រាប់ឪពុកម្តាយ

ឈ្មោះសិស្ស:........................................................ ថ្នាក់ទី: ៨

ឈ្មោះឪពុកម្តាយ:...............................................................

១. តើមុខវិជ្ជាអ្វីខ្លះដែលកូនរបស់អ្នកចូលចិត្តរៀននៅសាលា?
២. តើមុខវិជ្ជាណាខ្លះដែលពួកគេរៀនពូកែ?
៣. តើអាជីពអ្វីដែលអ្នកគិតថាកូនរបស់អ្នកគួរធ្វើ?
៤. តើកូនរបស់អ្នកយល់យ៉ាងណាអំពីគំនិតអាជីពនេះ?
៥. តើមុខរបររបស់អ្នកជាអ្វី?
៦. តើកូនរបស់អ្នកចង់បន្តការសិក្សាបន្ទាប់ពីបញ្ចប់ថ្នាក់ទី៩ដែរឬទេ?
៧. តើអ្នកនឹងអនុញ្ញាតឱ្យកូនរបស់អ្នកបន្តការសិក្សាបន្ទាប់ពីបញ្ចប់ថ្នាក់ទី៩ដែរឬទេ?
ប្រសិនបើ “ទេ” តើផលលំបាកអ្វីខ្លះដែលអ្នកជួបប្រទះក្នុងការអនុញ្ញាតឱ្យកូនរបស់អ្នកបន្តការសិក្សា?
៨. តើអ្នកចង់ទទួលបានព័ត៌មានអំពីការសិក្សាបន្តទៀត អាជីព និងជំនួយដែលមាននៅសាលាដែរឬទេ?

កំណត់កាលបរិច្ឆេទសម្រាប់ក្រុមប្រឹក្សាកុមារដើម្បីជួបជាមួយសិស្សអាទិភាព។ កិច្ចការនេះគួរធ្វើឡើង ៤ ឬ ៥ថ្ងៃបន្ទាប់ពីមេរៀនបំណិនជីវិតចុងក្រោយ (មេរៀនទី១០)។

◈ សួរសមាជិកក្រុមប្រឹក្សាកុមារ តើពួកគេត្រូវធ្វើសកម្មភាពអ្វីខ្លះ ជាមួយសិស្សអាទិភាពដើម្បីឱ្យដំណើរការប្រជុំបានជោគជ័យ?

ចម្លើយគួររួមមាន៖ រៀបចំរបៀបវារៈច្បាស់លាស់។ ដឹងថានរណាទទួលខុសត្រូវធ្វើសកម្មភាពអ្វី បញ្ជាក់ថាធនធាននានាត្រូវបានរៀបចំទុកដាក់សមរម្យ ដឹងថានរណានឹងជាប្រធាន ហើយនរណានឹងធ្វើជាអ្នកកត់ត្រាក្នុងអង្គប្រជុំ។ ត្រូវចងចាំក្នុងការប្រាប់អ្នកចូលរួមទាំងអស់ឱ្យដឹងពីទីកន្លែងដែលកិច្ចប្រជុំនឹងប្រារព្ធ និងពេលវេលាដែលនឹងចាប់ផ្តើម។ ព្យាយាមគោរពពេលវេលាដែលបានកំណត់។

✋ ឱ្យសិស្សចំណាយពេល ១០ ឬ១៥នាទីដើម្បីរៀបចំរបៀវារៈសម្រាប់កិច្ចប្រជុំលើកដំបូងជាមួយសិស្សអាទិភាព។ នៅពេលពួកគេបានបញ្ចប់ ពិនិត្យមើលរបៀបវារៈរបស់ពួកគេ និងធ្វើការសម្របសម្រួលក្នុងការកែតម្រូវដែលអ្នកអាចមានដើម្បីកែលម្អ។ ទម្រង់របៀបវារៈដែលស្នើត្រូវបានបង្ហាញខាងក្រោម។

របៀបវារៈគំរូសម្រាប់កិច្ចប្រជុំលើកដំបូងសម្រាប់សមាជិកក្រុមប្រឹក្សាសិស្សជាមួយសិស្សអាទិភាពថ្នាក់ទី៨។

## របៀបវារៈក្នុងការប្រជុំជាមួយសិស្សអាទិភាព

ថ្ងៃ_____ ខែ____________ ឆ្នាំ_________ ម៉ោងចាប់ផ្តើមៈ______ម៉ោងបញ្ចប់ៈ_______

ប្រធាន____________________ ឈ្មោះអ្នកកត់ត្រា__________________

១. សេចក្តីណែនាំ និងការពិនិត្យវត្តមានរបស់សិក្ខាកាមទាំងអស់ (៥នាទី - ដារ៉ា)
២. គោលបំណងនៃការប្រជុំ (៥នាទី - ដារ៉ា)
៣. ការពិភាក្សាក្រុមតូចអំពីភាពលំបាកដែលសិស្សបានជួបក្នុងការសម្រេចពីអនាគតរបស់ពួកគេ (២០នាទី - ដារ៉ា សារ៉ាន រំដួល លីន សុខា)
៤. សេចក្តីពន្យល់ពីកម្រងសំណួររបស់ឪពុកម្តាយ ដែលត្រូវបំពេញមុនពេលការប្រជុំក្លឹប (១០នាទី - រំដួល)
៥. គោលបំណងនៃក្លឹបការងារ (១០នាទី - ដារ៉ា និង សុខា)
៦. បិទការប្រជុំ និងកំណត់កាលបរិច្ឆេទសម្រាប់ធ្វើក្លឹបអាជីពក្នុងពេលអនាគត (១០នាទី)

## ការងារគោលដៅ ◷ ២៥ នាទី

✋ បង្ហាញក្រុមប្រឹក្សាកុមារនូវតារាងកំណត់ត្រាការងារគោលដៅ។ ពន្យល់ថា សិស្សថ្នាក់ទី៨ជាច្រើននឹងបំពេញតារាងនេះក្នុងកំឡុងពេលនៃមេរៀនចុងក្រោយ ប៉ុន្តែវាអាចនឹងមានភាពលំបាកខ្លះសម្រាប់សិស្សអាទិភាពមួយចំនួនដើម្បីបំពេញតារាងនេះ។ ពន្យល់ពីរបៀបក្នុងការបំពេញវា។

◈ សួរក្រុមប្រឹក្សាកុមារថាតើពួកគេដឹងថាធនធានអ្វីខ្លះដែលមានក្នុងសាលារៀន ហើយអាចជួយពួកគេឱ្យយល់ថាតើការងារមួយណាត្រូវនឹងមុខវិជ្ជាណា?

ចម្លើយដែលអាចមាន៖ តារាងផ្គូផ្គងការងារទៅនឹងមុខវិជ្ជាដែលបង្កើតឡើងដោយសិស្សថ្នាក់ទី៨ ក្នុងមេរៀនទី៦ នៃមេរៀនបំណិនជីវិត ប្រហែលជាធនធានដ៏ល្អបំផុតមួយ។ កិច្ចសម្ភាសករណីសិក្សាក៏អាចជួយបានដែរ។ ប្រសិនបើចាំបាច់ បង្ហាញធនធានទាំងនោះទៅកាន់ក្រុមប្រឹក្សាសិស្ស ដូចនេះពួកគេយល់ច្បាស់ថាពួកវាជាអ្វី។

ប្រាប់សមាជិកក្រុមប្រឹក្សាកុមារឱ្យធ្វើការជាដៃគូដើម្បីព្យាយាមបំពេញតារាងការងារគោលដៅគម្រូ តាមគំនិតផ្ទាល់ខ្លួនរបស់ពួកគេអំពីអនាគត។

នៅពេលពួកគេបញ្ចប់ ពួកគេគួរប្រៀបធៀបចម្លើយជាមួយដៃគូដទៃទៀត។ ដើរត្រួតពិនិត្យដោយយកចិត្តទុកដាក់ និងជួយពួកគេក្នុងការពិភាក្សា និង កែកំហុសរបស់ពួកគេ។ ឱ្យក្រុមប្រឹក្សាកុមារយកទម្រង់កំណត់ត្រាការងារគោលដៅចេញមក នឹងបំពេញវាបន្ទាប់ពីវគ្គបណ្តុះបណ្តាលដោយប្រើគំនិតការងារផ្ទាល់ខ្លួនរបស់ពួកគេ ដូច្នេះពួកគេអាចប្រើវាជាឯកសារយោងដើម្បីជួយសិស្សអាទិភាពនៅពេលក្រោយ។

ប្រាប់ក្រុមប្រឹក្សាថា បន្ទាប់ពីមេរៀនបំណិនជីវិតចុងក្រោយ អ្នកនឹងផ្តល់ឱ្យពួកគេនូវទម្រង់ការងារគោលដៅដែលបានបំពេញរួច ហើយអ្នកនឹងបំពេញជាមួយសិស្សថ្នាក់ទី៨។

ក្រុមប្រឹក្សាកុមារនឹងធ្វើការក្នុងកំឡុងពេលកិច្ចប្រជុំក្លឹបមួយរបស់ពួកគេ ជាមួយសិស្សអាទិភាពដែលមិនអាចបំពេញតារាងទាំងអស់នេះបាន - ពួកគេត្រូវរង់ចាំរហូតដល់ពួកគេបានធ្វើកិច្ចប្រជុំក្លឹបយ៉ាងតិចណាស់ ៣ ឬ៤ដង មុនពេលពួកគេព្យាយាមជួយសិស្សអាទិភាពក្នុងការបំពេញតារាងដែលពួកគេទុកនៅទំនេរ។ សិស្សខ្លះប្រហែលជាត្រូវការពេលវេលាយូរជាងនេះ ដូច្នេះសម្រាប់សិស្សទាំងអស់នេះអាចរង់ចាំរហូតដល់ពួកគេមានអារម្មណ៍ថាពួកគេអាចធ្វើវាបាន ប៉ុន្តែវាត្រូវបានបំពេញយ៉ាងយូរបំផុតត្រឹមខែមិថុនា។

ឱ្យសមាជិកក្រុមប្រឹក្សាកុមារម្នាក់ទទួលខុសត្រូវបញ្ជីការងារគោលដៅ និងចងចាំក្នុងការតាមដានជាមួយសិស្សអាទិភាពទាំងអស់ដើម្បីបំពេញទម្រង់គោលដៅ។ នៅពេលបញ្ចប់ ពួកគេគួរឱ្យវាមកអ្នកវិញ។

## ការធ្វើផែនការក្លឹបអាជីព និងសកម្មភាពពីអាជីព ៧០ នាទី

នៅពេលក្រុមប្រឹក្សាសិស្សជួបជាមួយសិស្សអាទិភាពថ្នាក់ទី៨ ពួកគេគួរអញ្ជើញឱ្យចូលរួមក្នុងក្លឹបអាជីព។ គោលបំណងរបស់ក្លឹបនេះគឺផ្តល់ឱកាសបន្ថែមទៀតដល់សិស្សទាំងអស់នោះ ក្នុងការនិយាយពីភាពលំបាកដែលពួកគេជួបប្រទះ ព្រមទាំងឱ្យពួកគេរៀបចំសកម្មភាពបន្ថែមដើម្បីសិស្សសាលា ឪពុកម្តាយ និងសហគមន៍មូលដ្ឋានទាំងអស់ចូលរួមក្នុងការជួយគាំទ្រសិស្សឱ្យគិតអំពីឱកាសអនាគតរបស់ពួកគេក្នុងការសិក្សា ការបណ្តុះបណ្តាល និងជាចុងក្រោយគឺអាជីពរបស់ពួកគេ។

ពន្យល់ទៅកាន់សមាជិកក្រុមប្រឹក្សាកុមារថា ពួកគេគួរនៅតែមានកិច្ចប្រជុំប្រចាំខែទាក់ទងនឹងការណែនាំពីអាជីព ដើម្បីធ្វើផែនការសកម្មភាព និងលើកពីបញ្ហានានា ប៉ុន្តែនៅពេលពួកគេចាប់ផ្តើមដំណើរការក្លឹបណែនាំពីអាជីព ផែនការសកម្មភាពភាគច្រើននឹងត្រូវធ្វើឡើងក្នុងក្លឹបអាជីព។ ពួកគេអាចប្រើទម្រង់ដូចគ្នានឹងទម្រង់ដែលពួកគេប្រើក្នុងការប្រជុំប្រចាំខែ។ ក្លឹបអាចធ្វើបានក្នុងមួយសប្តាហ៍ម្តង។

សួរសមាជិកក្រុមប្រឹក្សាកុមារ “១. តើសកម្មភាពណាខ្លះដែលអ្នកអាចធ្វើបានក្នុងក្លឹបណែនាំពីអាជីពដើម្បីជួយសិស្សអាទិភាពឱ្យគិតអំពីអនាគតរបស់ពួកគេ? ២. តើអ្នកអាចធ្វើឱ្យឪពុកម្តាយ និងសហគមន៍ចូលរួមក្នុងការសិក្សាបន្ថែមទៀតអំពីជម្រើសសិក្សា និងការបណ្តុះបណ្តាលសម្រាប់ពេលអនាគតដោយរបៀបណា ដើម្បីឱ្យពួកគេអាចពិភាក្សាបន្ថែមទៀតជាមួយសិស្សរបស់ពួកគេ? ៣. តើអ្នកអាចបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវរបស់សិស្សថ្នាក់ទី៨ ទៅកាន់សិស្សទាំងអស់ក្នុងសាលា និងសហគមន៍បានដែរឬទេ?”

ទុកពេល២០នាទីឱ្យសមាជិកក្រុមប្រឹក្សាសិស្សដើម្បីពិភាក្សាក្នុងក្រុម។ នៅពេលពួកគេបញ្ចប់ ឱ្យក្រុមមួយឡើងចែករំលែកចម្លើយរបស់ពួកគេបន្ទាប់មក ឱ្យក្រុមដទៃទៀតបន្ថែមចម្លើយ។ ទន្ទឹមនឹងនោះ ក៏ចែករំលែកចម្លើយបន្ថែមទៀតពីក្នុងតារាងសកម្មភាពក្លឹបដែលបានស្នើខាងក្រោម។

ពន្យល់ថា ពួកគេអាចធ្វើសកម្មភាពដូចគ្នាជាមួយនឹងសិស្សអាទិភាពដើម្បីទទួលបានគំនិតរបស់ពួកគេក្នុងកំឡុងពេលប្រជុំក្លឹប។ បន្ទាប់មក ពួកគេអាចចាត់អាទិភាពថាតើសកម្មភាពណាមួយដែលពួកគេធ្វើក្នុងសប្តាហ៍នីមួយៗ។ វានឹងមានភាពល្អប្រសើរក្នុងការរៀបចំសម្ភារៈដើម្បីដាក់បង្ហាញក្នុងសាលានៅចុងឆ្នាំសិក្សា និងអញ្ជើញឪពុកម្តាយ និងសហគមន៍ឱ្យមកទស្សនា។ នេះអាចជាផ្នែកមួយនៃព្រឹត្តិការណ៍ទីផ្សាគំរូ សាលាធ្វើព្រឹត្តិការណ៍ ឬព្រឹត្តិការណ៍អាជីពពិសេសដែលមានការអញ្ជើញប្រជាជនក្នុងមូលដ្ឋានមកនិយាយទៅកាន់សិស្សអំពីការងាររបស់ពួកគេ ឬសិស្សធ្វើការសម្តែងតួដោយផ្អែកតាមករណីសិក្សារបស់ពួកគេ។

☞ ឱ្យសិស្សបង្កើតជារបៀបវារៈសម្រាប់ការប្រជុំក្លឹបជាលើកដំបូងដែលពួកគេនឹងប្រារព្ធធ្វើ។

១៥ ឬ២០នាទីក្រោយ ពិនិត្យមើលរបៀបវារៈ និងជួយបន្ថែម ឬស្នើធ្វើការផ្លាស់ប្តូរ ប្រសិនបើចាំបាច់។ របៀបវារៈដែលបានស្នើគឺមានដូចខាងក្រោម៖

## របៀបវារៈសម្រាប់ក្លឹបណែនាំពីអាជីព

ថ្ងៃ____ ខែ____________ ឆ្នាំ________ ម៉ោងចាប់ផ្តើម៖______ម៉ោងបញ្ចប់៖_______

ប្រធាន____________________ ឈ្មោះអ្នកកត់ត្រា__________________

១. សេចក្តីណែនាំ និងការពិនិត្យវត្តមានរបស់សិក្ខាកាមទាំងអស់ (៥នាទី - ដារ៉ា)

២. ពិភាក្សាក្នុងក្រុមតូចអំពីលទ្ធផលនៃកម្រងសំណួររបស់ឪពុកម្តាយ ហើយប្រសិនជាត្រូវធ្វើសកម្មភាពផ្សេងៗដើម្បីជួយដោះស្រាយបញ្ហានេះ ត្រូវលើកឡើង (២០នាទី - ដារ៉ា សារ៉ាន់ វំដួល លីន សុខា)

៣. ពិភាក្សាក្នុងក្រុមតូចអំពីសកម្មភាពអ្វីខ្លះដែលក្លឹបអាជីពអាចធ្វើបាន(២០នាទី - ដារ៉ាសារ៉ាន វំដួល លីន សុខា)

៤. សម្រេចថាតើសកម្មភាពណាមួយដែលគួរត្រូវបានអនុវត្តក្នុងកិច្ចប្រជុំក្លឹបលើកក្រោយ និងធ្វើផែនការសកម្មភាពដែលត្រូវធ្វើ មុនពេលកិច្ចប្រជុំលើកក្រោយ (១៥នាទី - ដារ៉ា និង សុខា)

៥. បិទការប្រជុំ និងកំណត់កាលបរិច្ឆេទសម្រាប់ធ្វើក្លឹបអាជីពក្នុងពេលអនាគត (១០នាទី - ដារ៉ា)

ប្រាប់ក្រុមប្រឹក្សាកុមារថា នេះគឺជាការណ្តុះបណ្តាលចុងក្រោយដែលអ្នកធ្វើឡើងជាមួយពួកគេ ប៉ុន្តែអ្នកនឹងបន្តត្រួតពិនិត្យមើលផែនការរបស់ពួកគេ ហើយប្រសិនបើចាំបាច់ ត្រូវជួបប្រជុំម្នាក់ទល់ម្នាក់ជាមួយសិស្សអាទិភាពដែលពួកគេណែនាំមកដើម្បីទទួលយកការគាំទ្របន្ថែមពីអ្នកប្រឹក្សាអាជីព។

## ឧទាហរណ៍នៃសកម្មភាពក្លឹប

### ក្នុងកិច្ចប្រជុំក្លឹប

- រៀបចំការដាក់តាំងក្នុងបណ្ណាល័យ ឬសម្រាប់ព្រឹត្តិការណ៍
- ធ្វើជាផ្ទាំងរូបភាពនៃព័ត៌មានសំខាន់ ដូចជា ឱកាសសិក្សា និងបណ្តុះបណ្តាលក្នុងតំបន់
- សរសេរអត្ថបទសម្រាប់ព្រឹត្តិបត្រសាលា ប្រសិនបើមាន
- បង្កើតល្បែងកំសាន្តបែបអប់រំអំពីអាជីព
- បង្កើត ឬប្រើប្រាស់សន្លឹកប័ណ្ណអំពីការងារដើម្បីបង្កើតជាល្បែងស្វាគមន៍ឱ្យកក់ក្តៅ
- អញ្ជើញអតីតសិស្សពីសាលារបស់អ្នកដើម្បីធ្វើបទបង្ហាញពីអ្វីដែលអ្នកកំពុងធ្វើឥឡូវនេះ
- បង្កើតជាការសម្តែងអំពីអាជីព
- ស្រាវជ្រាវជម្រើសអាជីពបន្ថែមទៀតដែលទាក់ទងនឹងមុខវិជ្ជាដែលសិស្សចូលចិត្ត
- ពិភាក្សាជម្រើសអាជីពផ្អែកតាមមុខវិជ្ជាបំណិនជីវិតដែលសិស្សចូលចិត្ត

### ព្រឹត្តិការណ៍ពិសេស

- ធ្វើការដាក់បង្ហាញដែលគួរឱ្យចាប់អារម្មណ៍អំពីករណីសិក្សាដែលជាផ្នែកមួយនៃព្រឹត្តិការណ៍បញ្ចប់ឆ្នាំសិក្សា ដូចជាការធ្វើជាផ្សារតំរូ ឬព្រឹត្តិការណ៍សាលាដទៃទៀត
- បង្កើតជាព្រឹត្តិការណ៍អាជីពពិសេស... អញ្ជើញអតីតសិស្ស ឬឪពុកម្តាយដើម្បីនិយាយអំពីការងាររបស់ពួកគេ បង្កើតជាការសម្តែងតួ ដាក់តាំងបង្ហាញ ល្បែងកំសាន្ត... អញ្ជើញអ្នកផ្តល់ការអប់រំ ឬការបណ្តុះបណ្តាលក្នុងតំបន់។ល។

## ឪពុកម្ដាយ និងសហគមន៍ចូលរួមបន្ថែមទៀតក្នុងសកម្មភាពអាជីព

- អញ្ជើញឪពុកម្ដាយចូលរួមក្នុងព្រឹត្តិការណ៍ - មើលព្រឹត្តិការណ៍ពិសេសខាងលើ
- សួរមេឃុំរបស់អ្នក ថាតើអ្នកអាចបិទកំណត់សម្គាល់ ឬផ្ទាំងរូបភាពនៅលើក្ដារបិទប្រកាសព័ត៌មានរបស់ពួកគេ - សួរអ្នកប្រឹក្សាអាជីព ឬនាយកសាលាថាតើពួកគេនឹងអាចមកជាមួយអ្នក។ ផ្លាស់ប្ដូរកំណត់សម្គាល់ជាទៀងទាត់។
- បង្កើតជាផ្ទាំងរូបភាព ឬកំណត់សម្គាល់ដែលគួរឱ្យទាក់ទាញអំពីសារៈសំខាន់នៃការអប់រំដើម្បីឱ្យមានអនាគតល្អ និងបង្កើត ឱកាសអាជីព - ប្រើរូបភាពឱ្យបានច្រើន ដូច្នេះវាគួរឱ្យចាប់អារម្មណ៍សម្រាប់សមាជិកសហគមន៍ដែលមិនអាចអានបានល្អ។
- បង្កើតជាផ្ទាំងរូបភាពនៃអាជីពផ្សេងៗដើម្បីបិទក្នុងការិយាល័យឃុំ។
- ស្នើឱ្យមេឃុំផ្សព្វផ្សាយអំពីសារៈសំខាន់របស់ការអប់រំសម្រាប់អាជីពនាពេលអនាគត
- បង្កើត និងបិទផ្ទាំងរូបភាពស្រដៀងគ្នានៅក្ដារបិទប្រកាសព័ត៌មានក្នុងសាលារៀនរបស់អ្នក ដូច្នេះឪពុកម្ដាយអាចមើលឃើញពួកវា។

## ការផ្សព្វផ្សាយព័ត៌មានមានប្រយោជន៍

- សួរអ្នកប្រឹក្សាអាជីពរបស់អ្នក និងនាយកសាលា តើពួកគេអាចធ្វើកិច្ចប្រជុំក្នុងកម្រងសាលា ថ្នាក់ស្រុក ឬថ្នាក់ខេត្តបានដែរឬទេ ប្រសិនបើអាចដើម្បីចែករំលែក និងប្រមូលករណីសិក្សាល្អ ឬព័ត៌មានលម្អិតនៃឱកាសសិក្សា និងការបណ្ដុះបណ្ដាលដើម្បីចែករំលែកទៅកាន់សាលារៀន។ ជ្រើសរើសព័ត៌មានដែលល្អបំផុតរបស់អ្នកដើម្បីចែករំលែក។
- ស្នើឱ្យនាយកសាលារបស់អ្នកសួរមន្ត្រីអប់រំស្រុក និងមន្ត្រីអប់រំខេត្តថាតើពួកគេអាចជួយក្នុងការប្រមូលព័ត៌មានអំពីឱកាសសិក្សាក្នុងខេត្ត និងយកពួកវាមកទុកក្នុងបណ្ណាល័យរបស់សាលារៀន។

**នៅមានអ្វីផ្សេងៗជាច្រើនទៀតដែលអ្នកអាចធ្វើបាន....**
**ធ្វើការពិភាក្សាជាញឹកញាប់ ហើយអ្នកនឹងរកបានគំនិតថ្មីៗ!**

## ធនធានបណ្ណាល័យដែលជាការណែនាំ

### ធនធានសៀវភៅបំណិនជីវិត ‘ពិភពការងារ’

- សៀវភៅបំណិនជីវិត ‘ពិភពការងារ’
- ផ្ទាំងរូបភាពដែលមានជាមួយសៀវភៅបំណិនជីវិត “ពិភពការងារ”
- ទម្រង់គំរូនៃជីវប្រវត្តិសង្ខេប (ពីក្នុងសៀវភៅ ពិភពការងារ)
- ទម្រង់គំរូនៃសំបុត្របង្ហាញចំណាប់អារម្មណ៍ (ពីក្នុងសៀវភៅ ពិភពការងារ)

### ធនធានពីក្នុងសៀវភៅនេះ

- គំរូខិត្តប័ណ្ណសម្រាប់សិស្សថ្នាក់ទី៨ដើម្បីប្រើក្នុងការពិភាក្សាជាមួយឪពុកម្ដាយរបស់ពួកគេ
- បញ្ជីនៃវិទ្យាស្ថានអប់រំជាន់ខ្ពស់សំខាន់ៗ

### សម្ភារៈដែលផ្អែកលើការស្រាវជ្រាវបំណិនជីវិតរបស់សិស្សថ្នាក់ទី៨

- ផ្ទាំងរូបភាព ឬតារាងអំពីការងារដែលមានក្នុងតំបន់ ក្នុងខេត្ត និងក្នុងប្រទេសកម្ពុជា (ដោយការប្រើប្រាស់ការស្រាវជ្រាវរបស់សិស្សថ្នាក់ទី៨)
- ផែនទីឱកាសការងារក្នុងតំបន់ (និងការបណ្ដុះបណ្ដាល) (ប្រើការស្រាវជ្រាវថ្នាក់ទី៨)
- ករណីសិក្សាអំពីអ្នកដែលធ្វើការក្នុងសហគមន៍មូលដ្ឋាន (ប្រើការស្រាវជ្រាវថ្នាក់ទី៨)
- ព័ត៌មានអំពីទីកន្លែងដែលត្រូវស្រាវជ្រាវអំពីឱកាសការងារ (បង្កើតឡើងដោយ ក្លឹបអាជីព)
- វចនានុក្រមអាជីព (បង្កើតឡើងដោយស៊ីប៉ា) - ឬក៏ស្រដៀងគ្នានេះ
- សន្លឹកប័ណ្ណអំពីមុខរបរ

| គ្រឹះស្ថានឧត្តមសិក្សាសាធារណៈសំខាន់ៗក្នុងប្រទេសកម្ពុជា | |
|---|---|
| **ពន្យបណ្ឌិតសភាកម្ពុជា (RAC), ភ្នំពេញ**<br>ទូរស័ព្ទ៖ ០២៣ ៨៩០ ១៨០, អ៊ីម៉ែល៖ info@rac-academy.edu.kh<br>គេហទំព័រ៖ www.rac-academy.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម វិទ្យាស្ថានវិចិត្រសិល្បៈ វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម វិទ្យាស្ថានភាសាជាតិ វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា . | **វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC), ភ្នំពេញ**<br>ទូរស័ព្ទ: 855 23 880 370/982 404, អ៊ីម៉ែល: info@itc.edu.kh,<br>គេហទំព័រ៖ www.itc.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ ការអប់រំ និងបណ្តុះបណ្តាល វិស្វកម្មអគ្គិសនី វិទ្យាសាស្ត្រកុំព្យូទ័រ វិស្វកម្មគីមីវិទ្យា និងអាហារ វិស្វកម្មស៊ីវិល វិស្វកម្មជនបទ វិស្វកម្មឧស្សាហកម្ម និងគ្រឿងយន្ត |
| **សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA), ភ្នំពេញ**<br>ទូរស័ព្ទ៖ 023 219 753, អ៊ីម៉ែល៖ info@rua.edu.kh,<br>គេហទំព័រ៖ www.rua.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ កសិរុក្ខវិទ្យា រុក្ខសាស្ត្រ ការគ្រប់គ្រង និងបច្ចេកទេសកសិកម្ម សេដ្ឋកសិកម្ម និងការអភិវឌ្ឍជនបទ ឧស្សាហកម្មកសិរុក្ខវិទ្យា ការគ្រប់គ្រងដី និងរដ្ឋបាលដីធ្លី | **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច (RULE), ភ្នំពេញ,**<br>ទូរស័ព្ទ៖ 023 36 26 07/21 47 03 អ៊ីម៉ែល៖ info@rule.edu.kh,<br>គេហទំព័រ៖ www.rule.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ ច្បាប់ រដ្ឋបាលសាធារណៈ ទំនាក់ទំនងអន្តរជាតិ សេដ្ឋកិច្ច និងការគ្រប់គ្រង បរិញ្ញាបត្រគណនេយ្យ ធនាគារ និងហិរញ្ញវត្ថុ ការគ្រប់គ្រងទេសចរណ៍ និងធុរៈកិច្ច សេដ្ឋកិច្ចព័ត៌មានវិទ្យា |
| **សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP), ភ្នំពេញ,**<br>ទូរស័ព្ទ៖ 023-883-640, អ៊ីម៉ែល secretary@rupp.edu.kh<br>គេហទំព័រ៖ www.rupp.edu.kh/<br>មហាវិទ្យាល័យសំខាន់ៗ៖ វិទ្យាសាស្ត្រ មនុស្សសាស្ត្រ សង្គមសាស្ត្រ ភាសា សិក្សាអន្តរជាតិ | **សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (RUFA), ភ្នំពេញ,**<br>ទូរស័ព្ទ: 023 986 417 អ៊ីម៉ែល៖ rufa@camnet.com.kh,<br>គេហទំព័រ៖ www.rufa.edu.kh/<br>មហាវិទ្យាល័យសំខាន់ៗ៖ បុរាណវត្ថុវិទ្យា ស្ថាបត្យកម្ម និងនគរូបនីយកម្ម សិល្បៈប្លាស្ទិក តន្ត្រី និងរបាំ |
| **វិទ្យាស្ថានជាតិអប់រំ (NIE), ភ្នំពេញ**<br>ទូរស័ព្ទ៖ 023 332 342, អ៊ីម៉ែល៖ nieimkoch@yahoo.com,<br>គេហទំព័រ៖ www.moeys.gov.kh/nie<br>មុខវិជ្ជា៖ មណ្ឌលបណ្តុះបណ្តាលគ្រូវិទ្យាល័យ | **វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ (NIB), ភ្នំពេញ,**<br>ទូរស័ព្ទ៖ 023 424 591 អ៊ីម៉ែល៖ nib@camnet.com.kh,<br>គេហទំព័រ៖ www.nib.edu.kh.<br>មហាវិទ្យាល័យ៖ ជំនាញគណនេយ្យ ធនាគារ និងហិរញ្ញវត្ថុ ទីផ្សារ និងការលក់ គ្រប់គ្រង ភាសាអង់គ្លេស |
| **វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា(NPIC), ភ្នំពេញ**<br>ទូរស័ព្ទ៖ 023-6915193, អ៊ីម៉ែល៖ npicinfo@gmail.com,<br>គេហទំព័រ៖ www.npic.edu.kh/<br>មហាវិទ្យាល័យសំខាន់ៗ៖ វិស្វកម្ម CAD/CAM វិស្វកម្មស៊ីវិល សូទវិជ្ជា ( ការផលិតនំ និងធ្វើម្ហូប ) | **សាកលវិទ្យាល័យជាស៊ីមកំចាយមារ/សាកលវិទ្យាល័យ មហាឫស្សីវង្ស,**<br>**ព្រៃវែង និងកំពង់ចាម**<br>ការិយាល័យភ្នំពេញ៖ ទូរស័ព្ទ៖ 011 204 323<br>អ៊ីម៉ែល៖ info@csuk.edu, www.csuk.edu.kh |
| **វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI), ភ្នំពេញ**<br>ទូរស័ព្ទ៖ 023 883 039, អ៊ីម៉ែល៖ info@ntti.edu.kh,<br>គេហទំព័រ៖ www.ntti.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ វិស្វកម្មស៊ីវិល បច្ចេកទេស និងព័ត៌មានវិទ្យា វិស្វកម្មអគ្គិសនី ស្ថាបត្យកម្ម | **សាលាជាតិកសិកម្មព្រែកលាប (PNSA),**<br>ទូរស័ព្ទ៖ 023 6905-154, អ៊ីម៉ែល: info@pnsa.edu.kh,<br>គេហទំព័រ៖ www.pnsa.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ និងពេទ្យសត្វ ការគ្រប់គ្រងធនធានជលផល និងជលវប្បកម្ម វិទ្យាសាស្ត្ររុក្ខសាស្ត្រ សាកវប្បកម្ម បច្ចេកទេសអាហារ |
| **វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម (ITI), ភ្នំពេញ**<br>ទូរស័ព្ទ៖ 023 368 156, អ៊ីម៉ែល៖ o_dara1259@yahoo.com.<br>មហាវិទ្យាល័យសំខាន់ៗ៖ ចេនាវេបសាយ ស្វ័យយន្ត ជួសជុលម៉ាស៊ីនត្រជាក់ អគ្គិសនី | **សាកលវិទ្យាល័យស្វាយរៀង, ខេត្តស្វាយរៀង,**<br>ទូរស័ព្ទ៖ 44 715 778, អ៊ីម៉ែល: info@sru.edu.kh, www.sru.edu.kh/<br>មហាវិទ្យាល័យសំខាន់ៗ៖ មនុស្សសាស្ត្រ និងភាសាបរទេស វិទ្យាសាស្ត្រ និងបច្ចេកទេស កសិកម្ម វិទ្យាសាស្ត្រសង្គម រដ្ឋបាលពាណិជ្ជសាស្ត្រ |
| **វិទ្យាស្ថានជាតិគ្រប់គ្រង (NUM), ភ្នំពេញ,**<br>ទូរស័ព្ទ៖ 023-428120, អ៊ីម៉ែល៖ sengbunthoeun@num.edu.kh,<br>គេហទំព័រ៖ www.num.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ គ្រប់គ្រង សេដ្ឋកិច្ច ទេសចរណ៍ គណនេយ្យ និងហិរញ្ញវត្ថុ ច្បាប់ ព័ត៌មានវិទ្យា | **សាកលវិទ្យាល័យបាត់ដំបង (UBB), បាត់ដំបង**<br>ទូរស័ព្ទ៖ 053 952 905 អ៊ីម៉ែល៖ info@ubb.edu.kh ,<br>គេហទំព័រ៖ www.ubb.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ រដ្ឋបាលពាណិជ្ជសាស្ត្រ និងទេសចរណ៍ វិទ្យាសាស្ត្រ និងបច្ចេកទេស កសិកម្ម និងការធ្វើម្ហូប សង្គមវិទ្យា និងការអភិវឌ្ឍសហគមន៍ សិល្បៈ មនុស្សសាស្ត្រ និងការអប់រំ វិទ្យាស្ថានភាសាបរទេស |
| **សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS), ភ្នំពេញ**<br>ទូរស័ព្ទ៖ 023 430 732, អ៊ីម៉ែល៖ USS.CF@online.com.kh,<br>គេហទំព័រ៖ www.univ-sante.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ ពេទ្យ ឱសថសាស្ត្រ ទន្តសាស្ត្រ | **សាកលវិទ្យាល័យមានជ័យ (MUC), ខេត្តបន្ទាយមានជ័យ**<br>អ៊ីម៉ែល: info@mcu.edu.kh, គេហទំព័រ៖ www.mcu.edu.kh<br>មហាវិទ្យាល័យសំខាន់ៗ៖ កសិកម្ម និងការធ្វើម្ហូប វិទ្យាសាស្ត្រ និងបច្ចេកទេស មនុស្សសាស្ត្រ សិល្បៈ និងភាសា សង្គមសាស្ត្រ |

## ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

# ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ......................... សាលា...................... . ខេត្ត.............. ស្រុក................. ថ្នាក់ទី ........ ប្រធានបទ................

| | ចំណុចត្រូវដាក់ពិន្ទុ | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | | |
| | **សង្កេតឥរិយាបថសិស្ស** | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មភាពពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរ ជាមួយក្រុម ។ សិស្សស្ដាប់គ្នាទៅវិញទៅមក និងផ្ដល់យោបល់គ្នាទៅវិញទៅមក ។ | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្ដល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ ។ | | |
| ៣ | **ការធ្វើសេចក្ដីសម្រេចចិត្តដោយខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្ដីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ ។ | | |
| ៤ | **ទំនុកចិត្តលើខ្លួនឯង :** កំឡុងពេលធ្វើបទបង្ហាញនិងពិភាក្សាក្រុម សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួមក្នុងក្រុម | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីប្រធានបទនេះ ហើយយល់ច្បាស់ខ្លឹមសារក្នុង ប្រធានបទ និងការអនុវត្តផ្ទាល់ ។ | | |
| ៦ | **ចរិត : សិស្ស**មានចិត្តអំណត់និងអារម្មណ៍ល្អនៅក្នុងការសិក្សា ។ | | |
| ៧ | **ការបង្កើតថ្មី :** សិស្សបង្ហាញនូវភាពច្នៃប្រឌិតក្នុងការរៀបចំការធ្វើបទបង្ហាញផលិតផល នៅកំឡុងពេលសិក្សា ដោយបង្ហាញចេញនូវគំនិតជាច្រើន ។ | | |
| | **សរុបសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥0=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបរបាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត .......................... ស្រុក ........................សាលា .............................. ថ្នាក់ទី .......... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| ការអង្កេតថ្នាក់រៀន | | | | | ការវាយតម្លៃគ្រូបំណិនជីវិត |
|---|---|---|---|---|---|
| សាលារៀន | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្តើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិតៈ |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្តាប់ធ្នាប់ ហើយ ត្រៀមសម្ភារៈរួចជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន | 1-2-3-4-5 | |
| លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស... | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
| មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេដែរឬទេ? | 1-2-3-4-5 | |
| ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀនដោយមានតួនាទីក្រុមច្បាស់លាស់ | 1-2-3-4-5 | |
| រីករាយជាមួយមេរៀនដែលគ្រូបង្រៀន | 1-2-3-4-5 | |
| បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន | 1-2-3-4-5 | |
| លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
| អនុវត្តតាមកិច្ចតែងការបង្រៀនដែលមានឬទេ? | 1-2-3-4-5 | *សូមបញ្ជាក់ធាតុណាមួយដែលត្រូវបានប្រើ* |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង? | 1-2-3-4-5 | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម/សកម្ម ឧ.ផែនទីគំនិត, ករណីសិក្សា, ការសម្តែងតួ, ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេលវេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តដល់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ។ **សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន** ហើយស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំង។ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្ភាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខា និងឈ្មោះរបស់អ្នកវាយតម្លៃ ......................

ហត្ថលេខា និងឈ្មោះរបស់គ្រូ ....................................

ក្រសួងកិច្ចការនារី

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by giz

aecid